**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការប្រៀបធៀប
# បទឃាតកម្ម និងបទរាជឃាតកម្ម

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ទេព សុវណ្ណនីដែន**

សាស្រ្តាចារ្យណែនាំ
លោក **ហោ សុភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ទេព សុវណ្ណនីដែន** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ១៩ ក្រុម L4B1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៥-២០១៩។

## សូមគោរពកិច្ច និងកតញ្ញូតាធម៌ចំពោះ

លោកឪពុកឈ្មោះ **ទេព សុខុម** អ្នកម្តាយឈ្មោះ **ម៉ក់ វណ្ណនី** ដែលមានគុណយ៉ាងធំធេងមិនអាចកាត់ថ្លៃបានចំពោះរូបកូនដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូបកូនប្រកបដោយព្រហ្មវិហារធម៌ និងបានបញ្ជូនកូនឲ្យទៅ សាលារៀនទទួលការសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹង ដើម្បីរស់នៅក្នុងសង្គមប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ ចេះបែងចែកទង្វើល្អ ឬ អាក្រក់ នឹង ចេះតស៊ូជំនះគ្រប់ឧបសគ្គក្នុងជីវិត។ បន្ថែមពីនេះសូមអរព្រះគុណលោកឪពុក ដែលចំណាយពេលវេលា សម្រាប់ការកែរសម្រួលនៅអក្ខរាវិរុទ្ធក្នុងសារណាបញ្ចប់ការសិក្សារបស់កូនមួយនេះ។

លោកយាយ **កែ ច័ន្ទដួង** ដែលមានគុណឥតឧបមាចំពោះរូបចៅស្រីដែលបានផ្តល់នូវឋវិកាសម្រាប់ផ្គត់ផ្គង់ក្នុងការរៀនសូត្រពីរដើមដល់ចប់ ការរស់នៅ អាហារហូបចុក ការចាយវាយប្រចាំថ្ងៃ និងសម្ភារៈប្រើប្រាស់គ្រប់យ៉ាងទាំងអស់ បន្ថែមពីនេះលោកបានតម្រង់ទិសសម្រាប់ជីវិតនាងខ្ញុំក្នុងវិស័យការសិស្សា និង បែបបទរស់នៅក្នុងសង្គមថ្លៃថ្នូយ៉ាងប្រសើរបំផុត។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ និងសាលកវិទ្យាការរង លោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់។

ជាពិសេសលោកសាស្ត្រាចារ្យ **ហោ សុភ័ណ្ឌ** ដែលជាសាស្ត្រចារ្យណែនាំរបស់នាងខ្ញុំក្នុងការសរសេរសារណាបញ្ចាប់ការសិក្សាដែលលោកបានជួយជ្រោមជ្រែង និងចំណាយពេលដ៏មានតម្លៃក្នុងការត្រួតពិនិត្យផ្តល់ជាមតិយោលបល់ និងផ្តល់ការពិភាក្សាជាប់ជាប្រចាំ។ មិនតែប៉ុណ្ណោះលោកសាស្ត្រចារ្យថែមទាំងជួយយ៉ាងពេញទំហឹងក្នុងការបង្ហាត់បង្រៀនទូន្មានប្រៀនប្រដៅ បង្ហាញទិស និងផ្តល់ជាអនុសាសន៍ ពន្យល់នឹងណែនាំនាងខ្ញុំអស់ពីកម្លាំងកាយចិត្ត។

នាងខ្ញុំសូមថ្លែងអំណរគុណ នឹងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ឱ្យជួមតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

រយៈពេលបួនឆ្នាំ នៅក្នុងការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានកន្លងផុតទៅយ៉ាងឆាប់រហ័សណាស់។ នៅក្នុងរយៈពេលតែមួយនេះបានផ្តល់ឱ្យ ការសិក្សាក៏បានឱ្យនិស្សិតគ្រប់រូបទទួលបាននូវចំណេះដឹងថ្មីៗជាច្រើន ក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកគ្រូសាស្ត្រាចារ្យ និង អ្នកគ្រូសាស្ត្រាចារ្យ ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកបានជួយបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍប្រទេសជាតិ ពីមួយថ្ងៃទៅមួយថ្ងៃមនុស្សជាតិ តែងតែមានការអភិវឌ្ឍន៍ផ្នែកគំនិតស្មារតីក្នុងការសិក្សាស្រាវជ្រាវបង្កើតនូវអ្វីដែលថ្មី អ្វីដែលជាគុណប្រយោជន៍សម្រាប់មនុស្សជាតិនាពេលបច្ចុប្បន្ននិងអនាគត។ ហើយយោងតាមតម្រូវការជាក់ស្តែងនៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ក្នុងនាមនាងខ្ញុំគឺជា និស្សិតបរិញ្ញាបត្រ មានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការបង្កើត និង សរសេរសារណាបញ្ចាប់ការសិក្សា នេះឡើងមកក្នុងគោលបំណងចែករំលែកចំណេះដឹងដែលបានសិក្សាកន្លងមកក្នុងថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ហើយជាពិសេសគឺដើម្បីបង្ហាញពីសម្ថតភាព និងលទ្ធភាពនៃការយល់ដឹងទាក់ទងទៅនឹងប្រធានបទ **"ការប្រៀបធៀបរវាងបទឃាតកម្ម និង បទរាជឃាតកម្ម"** ជាផ្នែកមួយនៃមុខវិជ្ជា ព្រហ្មទណ្ឌទូទៅ។

តាមរយៈប្រធានបទដោយមានសារៈសំខាន់ខាងលើនេះ នាងខ្ញុំសង្ឃឹមថាសារណាបញ្ចាប់ការសិក្សាមួយនេះ ពិតជាអាចផ្តល់ចំណេះដឹងមួយផ្នែកដល់ បណ្តាលអ្នកស្រាវជ្រាវ សិស្ស និស្សិតដែរចង់ស្វែងយល់ ឬចង់សិក្សាឱ្យបានស៊ីជម្រៅអំពី ការប្រៀបធៀបរវាងបទឃាតកម្ម និង បទរាជឃាតកម្ម និងជាស្ពានចម្លងសម្រាប់បណ្តាអ្នកសិក្សាស្រាវជ្រាវ និងសិស្ស និស្សិត ជំនាន់ក្រោយបន្តធ្វើការសិក្សាបន្ថែមទៀត។

ជាទីបញ្ចប់នាងខ្ញុំ សូមធ្វើការអភ័យទោសទុកជាមុន នូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា តាមរយៈកំហុសអក្ខរាវិរុទ្ធ ការបកស្រាយ និងការប្រើប្រាសពាក្យពេចន៍មិនសមស្រប ក៏ដូចជាការខ្វះខាតនូវអត្ថន័យក្តី។ ជាពិសេសនាងខ្ញុំសង្ឃឹមថា នឹងទទួលបានការយោគយល់ អធ្យាស្រ័យ ហើយក៏រង់ចាំទទួលរាល់ការកែលម្អរពីសំណាក់សាស្ត្រាចារ្យ សិស្ស និស្សិតមិត្តអ្នកអានដោយក្តីអនុគ្រោះផង។

# មាតិកា

**សេចក្ដីផ្ដើម**....................................................................................................................១

## ជំពូកទី១

## បទឃាតកម្ម

**កថាខណ្ឌទី១ និយមន័យនៃបទឃាតកម្ម**..........................................................................៥
**កថាខណ្ឌទី២ ធាតុផ្សំនៃបទឃាតកម្ម**................................................................................៦
**១ ធាតុនីត្យានុកូលនៃបទឃាតកម្ម**.................................................................................៦
១.១. ក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ..........................................៧
១.២. ច្បាប់ព្រហ្មអន្តរកាល..............................................................................................៧
**២ ធាតុសត្យានុម័តនៃបទឃាតកម្ម** .................................................................................៨
២.១ អំពើសម្លាប់ ឬអំពើផ្ដាច់ជីវិត ឬអំពើប្រល័យជីវិតរបស់មនុស្ស.....................៨
២.២ លក្ខណៈសម្បត្តិនៃជនរងគ្រោះ .................................................................................៨
**៣. ធាតុអត្តនោម័តិនៃបទឃាតកម្ម** ...............................................................................១១
៣.១ ករណីមានចេតនាចង់ផ្ដាច់យកជីវិតជនរងគ្រោះ.........................................១១
៣.២ ករណីមានការយល់ព្រមពីជនរងគ្រោះ.....................................................................១២
៣.៣ ករណីនៃការការពារស្របច្បាប់ និងករណីមានការភ័ន្តច្រឡំ.......................១២
**កថាខណ្ឌទី៣ ទោសដែលត្រូវទទួលរងនៃបទឃាតកម្ម**.............................................................១៣
**១ ករណីគ្មានស្ថានទម្ងន់ទោស**......................................................................................១៣
**២ ករណីមានស្ថានទម្ងន់ទោស**.......................................................................................១៣
២.១ បទឃាតកម្មគិតទុកជាមុន (មាត្រា ២០០) ...........................................................១៣
២.២. បទឃាតកម្មដោយការប្រើថ្នាំពុល (មាត្រា ២០១).................................... ១៥
២.៣. បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ........... ១៦
២.៤. បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ ................ ២០
២.៥. បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ..................................២៣

២.៦. បទល្មើសឃាតកម្មដោយមានអំពើទារុណកម្មអំពើឃោឃៅ ឬអំពើរំលោភសេពសន្ថវៈ.......... ២៤
**៣. ទោសបន្ថែមនៃបទឃាតកម្មៈ ប្រភេទ និង រយៈពេល**.......... ២៦

# ជំពូកទី២

# បទរាជឃាតកម្ម

**កថាខណ្ឌទី១ និយមន័យនៃបទរាជឃាតកម្ម**.......... ២៧
**កថាខណ្ឌទី២ ធាតុផ្សំនៃបទរាជឃាតកម្ម**.......... ២៧
**១ ធាតុនីត្យានុកូលនៃបទរាជឃាតកម្ម**.......... ២៨
**២ ធាតុសត្យានុម័តនៃបទរាជឃាតកម្ម**.......... ២៨
២.១ អំពើដែលអាចធ្វើឱ្យបាត់នូវអត្ថិភាពនៃជីវិតរបស់អង្គព្រះមហាក្សត្រ.......... ២៨
២.២ លក្ខណៈសម្បត្តិរបស់ជនរងគ្រោះ.......... ២៩
**៣ ធាតុអន្តនោម័តនៃបទរាជឃាតកម្ម**.......... ៣០
**កថាខណ្ឌទី៣ ទោសដែលត្រូវអនុវត្តចំពោះបទរាជឃាតកម្ម**
**១ មូលទោស**.......... ៣០
១.១ ករណីចូលក្នុងបទរាជឃាតកម្ម.......... ៣០
១.២ ករណីចូលក្នុងបទធ្វើទារុណកម្ម ឬអំពើឃោឃៅចំពោះព្រះមហាក្សត្រ.......... ៣០
១.៣ ករណីចូលក្នុងបទហិង្សាចំពោះអង្គព្រះមហាក្សត្រ.......... ៣១
**២ ទោសបន្ថែម ៖ ប្រភេទទោស និង រយៈពេល**.......... ៣២

# ជំពូកទី៣

# ការប្រៀបធៀបបទល្មើសទាំង២ (បទឃាតកម្ម និងរាជឃាតកម្ម)

**កថាខណ្ឌទី១ ចំណុចដូចគ្នា**.......... ៣៣
**១ ប្រភេទនៃបទល្មើស**.......... ៣៣
**២ បុគ្គលដែលពាក់ព័ន្ធទៅនឹងបទល្មើស**.......... ៣៤
២.១ ជនល្មើស.......... ៣៥

៣ អំពើ និង បច្ច័យ ............................................................ ៣៥
៤ អាជ្ញាយុកាល ............................................................ ៣៦
៤.១ អាជ្ញាយុកាលនៃបទល្មើស ............................................................ ៣៦
៤.២ អាជ្ញាយុកាលនៃទោស ............................................................ ៣៧
៥ ទោសបន្ថែម និងការប៉ុនប៉ង ............................................................ ៣៧
**កថាខណ្ឌទី២ ចំណុចខុសគ្នា** ............................................................ ៣៨
១ ការបែងចែកក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ............................................................ ៣៨
១.១ ការបែងចែកនៅក្នុងគន្ថី ............................................................ ៣៨
១.២ ការបែងចែកនៅក្នុងមាតិកា ............................................................ ៣៩
១.៣ ការបែងចែកក្នុងជំពូក ............................................................ ៣៩
១.៤ ការបែងចែកនៅក្នុងផ្នែក ............................................................ ៤០
២ បុគ្គលដែលពាក់ព័ន្ធនឹងបទល្មើស ............................................................ ៤០
២.១ ជនរងគ្រោះ ............................................................ ៤០
៣ និយមន័យនៃបទល្មើសទាំងពី ............................................................ ៤២
៤ ធាតុផ្សំនៃបទល្មើសទាំងពី ............................................................ ៤៣
៤.១ ធាតុនីត្យានុកូល ............................................................ ៤៣
៤.២ ធាតុសត្យានុម័ត ............................................................ ៤៣
៤.៣ ធាតុអត្តនោម័តិ ............................................................ ៤៦
៥ ទោសដែលត្រូវអនុវត្ត ............................................................ ៤៦
៥.១ មូលទោស ............................................................ ៤៦
៥.២ ស្ថានទម្ងន់ទោស ............................................................ ៤៧
**សេចក្តីសន្និដ្ឋាន** ............................................................ ៤៨
**អនុសាសន៍** ............................................................ ៤៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

តាំងពីសម័យបុរាណកាលមករហូតដល់បច្ចុប្បន្នកាលនេះ សង្គមនីមួយៗតែងតែមានការផ្លាស់ប្តូរ មិនថានៅក្នុងសង្គមដែលមានការរីកចម្រើនខ្លាំង ឬសង្គមដែលមានការអភិវឌ្ឍបន្តិចបន្តួចក៏ដោយ គឺតែងតែមានការប្រែប្រួល និងអភិវឌ្ឍន៍ទោះតិចក្តី ឬច្រើនក្តី។ ទន្ទឹមនឹងគ្នានេះដែរសង្គមនីមួយៗ តែងតែមានបទល្មើសកើតឡើង បង្កឱ្យមានភាពល្អក់កករ និងមានការផ្លាស់ប្តូររូបរាងសង្គមមួយបែបទៀត ក៏ដូចជាការបង្កើតឱ្យមានបទល្មើសថ្មីៗបន្ថែមទៀត។

ជាការពិតណាស់សព្វថ្ងៃនេះប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ ក៏កំពុងតែមានការប្រែប្រួលផងដែរ។ ហេតុដូច្នេះហើយក៏មានអំពើខុសច្បាប់ផ្សេងៗ ក៏កើតមានផងដែរដែលជាហេតុធ្វើឱ្យមានការប៉ះពាល់ទៅដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់ទ្រព្យសម្បត្តិ កិត្តិយស និងសេចក្តីថ្លៃថ្នូ និងជាពិសេស គឺប៉ះពាល់ដល់អាយុជីវិតមនុស្សដែលរស់នៅក្នុងសង្គមថែមទៀតផង។ បទល្មើសទាំងអស់វាអាចកើតមានឡើងនូវគ្រប់ទីកន្លែង មិនថានៅទីក្រុង តាមជនបទ តំបន់ទីប្រជុំជន ឬ តំបន់ដាច់ស្រយាលក្តី គឺគ្រាន់តែមានលក្ខណៈខុសគ្នាពាក់ព័ន្ធទៅនឹងចំនួន និងស្ថានភាពនៃបទល្មើសតែប៉ុណ្ណោះ។

យោងតាមការសង្កេតយ៉ាងយកចិត្តទុកដាក់ យើងនឹងបានឃើញនូវផលវិបាកដែលមានឥទ្ធិពលអាក្រក់ដល់ប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំសង្គមជាតិ ឬ អង្គព្រះមហាក្សត្រ បែបនេះហើយទើបប្រទេសកម្ពុជា និង បណ្តាលប្រទេសផ្សេងៗដែលបានបង្កើតច្បាប់ឡើង និងការដាក់ទណ្ឌកម្មទៅលើជនដែលបានប្រព្រឹត្តបទល្មើសដោយបានកំណត់ទៅតាមកម្រិតនៃអំពើល្មើសនោះ។ ច្បាប់ត្រូវបានបង្កើតក្នុងគោលបំណងគ្រប់គ្រងមិនឱ្យមានបទល្មើសកើតឡើងឬ ជាវិធានការសម្រាប់ដាក់ទោសជនល្មើសពេលមានបទល្មើសកើតឡើងដែលផ្ទុយពីច្បាប់។

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយធ្វើការបែងចែកជាប្រាំមួយគន្ថី ក្នុងគន្ថីទាំងអស់ មានគន្ថីចំនួន៣ ដែលបានកំណត់ពីបទល្មើស។ បទល្មើសដែលបានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ត្រូវបានបែងចែកជា៣ គឺបទល្មើសប្រឆាំងនឹងបុគ្គល បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងបទល្មើសប្រឆាំងនិងជាតិ បន្ថែមពីនេះទៀត នៅក្នុងចំណោមបទល្មើសទាំងបីនេះគឺសុទ្ធតែមានសារៈសំខាន់ទាំងអស់។

យើងសូមលើកយកគន្ថី២ ដែលមានចំណុចគួរឱ្យចាប់អារម្មណ៍ច្រើន គឺគន្ថីដែលមានចែងពីបទល្មើសប្រឆាំងនឹងបុគ្គល និង គន្ថីដែលមានចែងពីបទល្មើសប្រឆាំង នឹង ជាតិពីព្រោះ បទល្មើស

ទាំងពីរនេះមានផលប៉ះពាល់ខ្លាំងទៅដល់បុគ្គលដោយផ្ទាល់ និងជាតិទាំងមូលថែមទៀតផង។ បទល្មើសប្រឆាំងទៅនឹងបុគ្គល និងបទល្មើសប្រឆាំងទៅនឹងជាតិបានកំណត់នូវបទល្មើសជាច្រើនដែលត្រូវបានដាក់ទណ្ឌកម្មតាមក្រមព្រហ្មទណ្ឌ ប៉ុន្តែនៅក្នុងចំណោមបទល្មើសទាំងនោះ មានបទល្មើសពីរដែលប៉ះពាល់ដល់បុគ្គលនឹងសង្គមជាតិធ្ងន់ធ្ងរជាងគេគឺបទឃាតកម្ម និងបទរាជឃាតកម្ម។ ដោយហេតុបទល្មើសទាំងពីរ នេះមានផលប៉ះពាល់ធ្ងន់ធ្ងរបែបនេះទើបក្នុងក្រមព្រហ្មទណ្ឌមានចែងនឹង កំណត់ពីទោសយ៉ាងច្បាស់លាស់ដែលពាក់ព័ន្ធទៅនឹងបទល្មើសទាំងពីរនេះ។

នៅក្នុងសារណានេះដែរ នាងខ្ញុំបានលើកយកនូវ បទឃាតកម្ម និងបទរាជឃាតកម្ម មកធ្វើការប្រៀបធៀបគ្នាពីព្រោះតែ វាមានលក្ខណៈស្រដៀងគ្នាច្រើនដែលអាចធ្វើឱ្យមានភាពច្រឡំទៅលើចំណុចមួយចំនួនរវាងបទល្មើសទាំងពីរ។ រាល់ភាពមន្ទិលសង្ស័យទាំងឡាយដែលពាក់ព័ន្ធទៅនឹងបទល្មើសទាំងពីរនេះនាងខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងសារណាមួយនេះ ដែលនៅក្នុងប្រធានបទថា **ការប្រៀបធៀបបទឃាតកម្ម និង បទរាជឃាតកម្ម**។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មកដល់ពេលបច្ចុប្បន្ននេះ ចំណុចដែលមកបកស្រាយអំពីប្រភេទនៃបទល្មើសទាំងពីរ នឹងការប្រៀបធៀបបានក្លាយជាចម្ងល់ដ៏សំខាន់មួយសម្រាប់អ្នកស្រាវជ្រាវ ដោយចោទឡើងជាសំណួរថា "តើបទឃាតកម្ម និងបទរាជឃាតកម្មមានលក្ខណៈដូចគ្នា នឹងលក្ខណៈខុសគ្នាយ៉ាងដូចម្ដេចខ្លះ?"

## ៣. កម្មវត្ថុនៃការស្រាវជ្រាវ

កម្មវត្ថុនៃការស្រាវជ្រាវរួមមានដូចដែលបានបង្ហាញនៅខាងក្រោមនេះ៖

- ស្វែងយល់អំពីលក្ខណៈនៃបទឃាតកម្ម ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌមាត្រា ១៩៩
- ស្វែងយល់អំពីលក្ខណៈនៃបទរាជឃាតកម្ម ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌមាត្រា ៤៣៣
- ស្វែងយល់អំពីលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នានៃបទល្មើសទាំង២
- ធ្វើសេចក្ដីសន្និដ្ឋាន និងផ្ដល់ជាអនុសាសន៍ ដើម្បីចូលរួមកែលម្អរ

## ៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការបកស្រាយទៅលើប្រធានបទនេះ នាងខ្ញុំសូមលើកយកមកបកស្រាយតែលក្ខណៈនៃបទល្មើសទាំងពីរតែប៉ុណ្ណោះ។ លក្ខណៈនៃបទល្មើសទាំងពីរ គឺបកស្រាយដោយសង្កត់ធ្ងន់ទៅលើនិយមន័យ ធាតុផ្សំនៃបទល្មើសនីមួយៗ និងទោសដែលត្រូវអនុវត្តទៅលើបទល្មើសនោះ។ បន្ទាប់មកនាងខ្ញុំនឹងធ្វើការប្រៀបធៀបរវាងបទល្មើសទាំងពីរដែលមានចំណុចដូចគ្នា និងចំណុច

ខុសគ្នា។ នាងខ្ញុំនឹងមិនធ្វើការបកស្រាយទៅលើចំណុចផ្សេងទៀតដែលមិនពាក់ព័ន្ធឡើយ ដូចជាការប្រកាសទោសចំពោះបទល្មើសទាំងពីរនេះ។

## ៥. គម្រោងនៃការស្រាវជ្រាវ

គម្រោងនៃការស្រាវជ្រាវនេះបានបែងចែកដូចខាងក្រោម៖

- ចំណុចដំបូង ស្វែងយល់អំពីលក្ខណៈនៃបទល្មើសនីមួយៗ តាមរយៈការសិស្សាទៅតាមរយៈឯកសារដែលធ្លាប់បានសិក្សាកន្លងមក និងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។
- ចំណុចបន្ទាប់ ធ្វើការវិភាគទៅលើការបកស្រាយចំពោះលក្ខណៈនៃបទល្មើសទាំងពីរហើយស្វែងរកនូវចំណុចដូច នឹងចំណុចខុសគ្នាមកបង្ហាញ។
- ចំណុចបញ្ចប់ គឺធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់ជាអនុសាសន៍ ដើម្បីរួមចំណែកនៅក្នុងការកែលម្អរទៅលើបទល្មើសនីមួយៗ និងការផ្តល់យោបល់ខ្លះៗចំពោះការអនុវត្តនូវទោសព្រហ្មទណ្ឌចំពោះបទល្មើសទាំងពីរនៅក្នុងពេលបច្ចុប្បន្ន។

## ៦. វិធីសាស្ត្រនៃការស្រាយជ្រាវ

ដើម្បីជំរុញឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ គឺចាំបាច់ទាមទារនូវការសិក្សាស្រាវជ្រាវទៅលើឯកសារដែលពាក់ព័ន្ធជាច្រើន និងការប្រមូលព័ត៌មានដែលពាក់ព័ន្ធសម្រាប់ធ្វើជាមូលដ្ឋានការស្រាវជ្រាវប្រធានបទខាងលើ។ ដូច្នេះការសិក្សាស្រាវជ្រាវនេះត្រូវបានប្រមូលពីប្រភពឯកសារពីរប្រភេទ គឺឯកសារចម្បង និងឯកសារបន្ទាប់បន្សំ។ តាមលទ្ធភាពជាក់ស្តែងនៃការសិក្សាស្រាវជ្រាវយើងមានវិធីសាស្ត្រប្រមូលព័ត៌មានដូចខាងក្រោម៖

- ឯកសារចំបង
  - ឯកសារដែលបានមកពីច្បាប់ដែលពាក់ព័ន្ធសំខាន់ៗគឺ ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ និងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល។
  - ឯកសារដែលបានមកពី នីតិរដ្ឋធម្មនុញ្ញ
- ឯកសារបន្ទាប់បន្សំ
  - ឯកសារដែលបានមកពី មេរៀនដែលធ្លាប់បានសិក្សាកន្លងមក
  - ឯកសារដែលបានមកពីសៀវភៅច្បាប់នានា
  - ឯកសារដែលបានពីសៀវភៅព្រហ្មទណ្ឌទូទៅ
  - ឯកសារដែលបានមកពីការណែនាំរបស់សាស្ត្រាចារ្យដឹកនាំ
  - ឯកសារដែលបានមកពីបណ្ណាល័យ
  - ឯកសារដែលបានមកពីការណែនាំរបស់សិស្សច្បង

- ឯកសារដែលបានមកពីការស្រាវជ្រាវតាមអ៊ិនធឺណែត
- ឯកសារដែលបានមកពីការណែនាំ និងពិភាក្សាពីមិត្តរួមជំនាន់

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវចែកចេញជា៣ ជំពូកដូចជា៖

- សេចក្តីផ្តើម
- ជំពូកទី១ បទឃាតកម្ម
- ជំពូកទី២ បទរាជឃាតកម្ម
- ជំពូកទី៣ ការប្រៀបធៀបបទល្មើសទាំងពីរ
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឧបសម្ព័ន្ធ
- ឯកសារយោង

# ជំពូកទី១

# បន្យាគកម្ម

# ជំពូកទី១

# បទឃាតកម្ម

បទឃាតកម្មគឺ ជាបទល្មើសមួយដែលធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិដាច់ខាតរបស់មនុស្សគឺ "សិទ្ធិរស់រានមានជីវិត"។ សិទ្ធិជាសារវត្តនេះមានចែង និងការពារដោយ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងដោយអត្ថបទអន្តរជាតិដទៃផ្សេងទៀតជាពិសេស គឺសេចក្ដីថ្លែងការជាសកលស្ដីពី សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី១០ ធ្នូ ឆ្នាំ១៩៤៨។ ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិតមានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន[1]។ សិទ្ធិរស់រានមាន ជីវិតនេះមិនត្រឹមតែបានទទួលស្គាល់ទៅដល់ប្រជាពលរដ្ឋគ្រប់រូបនេះទេសូម្បីតែបទឧក្រិដ្ឋធ្ងន់ធ្ងរ ក៏ទទួលបាននូវសិទ្ធិនេះដែរ។ ដូច្នេះហើយបានជាទោសប្រហារជីវិតនេះត្រូវបានលុបចោល[2]។ បទឃាតកម្មត្រូវបានច្បាប់ចាត់ទុកជាប្រភេទនៃបទឧក្រិដ្ឋដែលត្រូវផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរ។

## កថាខណ្ឌទី១ និយមន័យនៃបទឃាតកម្ម

បទឃាតកម្មគឺជាអំពើសម្លាប់មនុស្សដោយចេតនាតាមគ្រប់មធ្យោបាយ ទោះដោយប្រើអាវុធក្ដី ឬមិនប្រើអាវុធក្ដី[3]។ ពាក្យថាសម្លាប់ នេះមានន័យថាធ្វើឱ្យស្លាប់ (អស់ជីវិត) បំបាត់ជីវិតឬផ្ដាច់ជីវិត [4] ។ ដូច្នេះយើងអាចយល់បានថាបទឃាតកម្មគឺជាអំពើដែលធ្វើឱ្យមនុស្សបាត់បង់ជីវិតដោយ ចេតនាឬអំពើផ្ដាច់ជីវិតមនុស្សដោយអចេតនា ទោះបីជាធ្វើឡើងដោយមានប្រើអាវុធក្ដី ឬមិនប្រើអាវុធក៏ដោយ។

ម្យ៉ាងវិញទៀត បទឃាតកម្មគឺជាអំពើដែលសម្លាប់មនុស្សឬជាអំពើផ្ដាច់ជីវិតជនរងគ្រោះទោះបីជាធ្វើឡើងដោយមានអាវុធ ឬគ្មានអាវុធក្ដី គឺស្ដែងចេញតាមរូបភាព និងតាមគ្រប់មធ្យោបាយរីឯអ្នកខ្លះទៀតគឺបានប្រព្រឹត្តអំពើដោយដៃទទេ អត់មានប្រើអាវុធទេ និងអ្នកខ្លះប្រើអាវុធ។ តើពាក្យអាវុធសំដៅទៅលើអ្វី? បើយើងពិនិត្យទៅលើមាត្រា៨១ នៃក្រមព្រហ្មទណ្ឌគឺមានចែងនូវពាក្យអាវុធដូចខាងក្រោម៖

១. វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឲ្យរបួស ឬ គំរាមកំហែង។

២. វត្ថុមានទិសដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬ គំរាមកំហែង។

---

[1] មាត្រា៣២ នៃរដ្ឋធម្មនុញ្ញ ១៩៩៣

[2] ដូចលេខ១

[3] សន្ទានុក្រមពាក្យច្បាប់ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី, ២០១១, ៦៨

[4] វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួនណាត

ការប្រើប្រាស់សត្វដើម្បីសម្លាប់មនុស្ស ធ្វើឱ្យមានរបួស ឬគំរាមកំហែងត្រូវចាត់ទុកដូច បានប្រើប្រាស់អាវុធដែរ។

វត្ថុនៅក្នុងមាត្រានេះអាចជា វត្ថុរឹង វត្ថុរាវ ឬ ឧស្ម័ន។ តើអ្វីទៅគឺជា វត្ថុរាវ?

វត្ថុរាវគឺមានដូចជាថ្នាំពុល ទឹកអាស៊ីត ឬឧស្ម័នពុល ដូចជាថ្នាំបាញ់មូស យកទៅបាញ់ចូលច្រមុះរហូតទាល់តែពុលស្លាប់។ វត្ថុរាវទាំងអស់នេះ គឺអាចចាត់ចូលជាអាវុធដូចគ្នា។ ដូច្នេះអាវុធនេះគឺទាក់ទងជាមួយនឹងវត្ថុទាំងអស់។ ហើយមួយវិញទៀតគឺសត្វ បើអ្នកដែលអាចប្រើសត្វទៅសម្លាប់ដូចជាបញ្ជាសត្វខ្លា ឬ សត្វឆ្កែឱ្យទៅខាំគេរហូតដល់ស្លាប់។

**ចំណាំ៖** សូមកុំយល់ច្រឡំថាអ្នកដែលបញ្ជាឆ្កែហ្នឹងគឺជា អ្នកផ្តើមគំនិត ទោះបើតាមក្រមព្រហ្មទណ្ឌគឺមានអ្នកណាដែលបញ្ជាគឺជាអ្នកផ្តើមគំនិត ហើយអ្នកប្រព្រឹត្តដោយផ្ទាល់គឺចារី។ ករណីស្រាប់តែដាក់ថាឆ្កែជាចារីនៅក្នុង បទល្មើសឃាតកម្មឯមនុស្សជាអ្នកបញ្ជាឆ្កែគឺជាអ្នកផ្តើមគំនិតនៅក្នុងបទឃាតកម្ម។ នៅក្នុងករណីនេះមិនមែនដូច្នេះទេ បើយោងតាមមាត្រា៨១ ខាងលើនេះផ្ទុយទៅវិញគឺ៖ អ្នកដែលបញ្ជាឆ្កែនៅទីនេះគឺជាចារី នៅក្នុងករណីនេះឆ្កែដែលទៅខាំគេឱ្យស្លាប់ហ្នឹងគឺជាអាវុធដែលរាប់ចូលជាបទល្មើសឃាតកម្មដោយប្រើអាវុធ។

ម្យ៉ាងវិញទៀតការធ្វើឡើងដោយប្រើថ្នាំពុល ឬអំពើឃាតកម្មមានការពួនស្ទាក់ដោយមានការរៀបចំគម្រោងគិតទុកជាមុន។ ដូច្នេះហើយសកម្មភាពជាសត្យានុម័តនេះគឺថាអាចធ្វើឡើងដោយមានការរៀបចំគម្រោងគិតទុកជាមុន ឬក៏មានការពួនស្ទាក់។

## កថាខណ្ឌទី២ ធាតុផ្សំនៃបទឃាតកម្ម

នៅក្នុងធាតុផ្សំនៃបទល្មើសនេះយើងនឹងលើកនូវធាតុផ្សំសំខាន់ៗទាំងបីនៃបទល្មើសឃាតកម្មគឺ៖

1. ធាតុនីត្យានុកូលនៃបទឃាតកម្ម
2. ធាតុសត្យានុម័តនៃបទឃាតកម្ម
3. ធាតុអត្តនោម័តិនៃបទឃាតកម្ម

ធាតុផ្សំទាំង៣នេះយើងនឹងធ្វើការបកស្រាយឱ្យបានក្បោះក្បាយ និងលម្អិតទាំងស្រុងនៅចំណុច ដូចខាងក្រោម៖

### ១ ធាតុនីត្យានុកូលនៃបទឃាតកម្ម

ខាងក្រោមនេះគឺជាលក្ខខណ្ឌបឋមនៃការកំណត់អំពីបទឃាតកម្មតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

### ១.១ ក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

បទឃាតកម្មមានចែងនៅក្នុងមាត្រា១៩៩ ឥឡូវយើងសូមពិនិត្យទាំងអស់គ្នាទៅលើ ក្រមព្រហ្មទណ្ឌថ្មី។ យោងទៅតាមមាត្រា ១៩៩ គេឱ្យនិយមន័យនៃការធ្វើឃាតកម្មនេះថាជា "អំពើសម្លាប់មនុស្សដោយចេតនាដោយប្រើអាវុធ ឬមិនបានប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ទោសណាមួយដូចបានកំណត់ ក្នុងមាត្រា២០០ (បទឃាតកម្មគិតទុកជាមុន) ដល់មាត្រា២០៥ (បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ) នៃក្រមនេះជា បទឃាតកម្ម។ បទឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ (ដប់)ឆ្នាំ ទៅដល់១៥ (ដប់ប្រាំ)ឆ្នាំ"។ ដោយឡែកក្នុងក្រមយើងថ្មីនេះបានប្រើពាក្យថាឃាតកម្មគឺ សំដៅទៅលើអំពើ សម្លាប់មនុស្សដោយចេតនា។ ពីមុនក្រមយើងមានចែងពី "មនុស្សឃាតដោយចេតនាប៉ុនប៉ងសម្លាប់ សម្លាប់ដោយចេតនា បទឃាតកម្មគិតទុកជាមុន" តែឥឡូវទាក់ទងជាមួយអំពើសម្លាប់មនុស្សដោយ ចេតនាគឺប្រើពាក្យឃាតកម្មទាំងអស់។ អត់មានពាក្យឃាតកម្មផ្សេង ឯសម្លាប់មនុស្សផ្សេង ឬក៏មនុស្សឃាតដោយចេតនាផ្សេងនោះទេ សរុបមកគឺ យើងមិនប្រើពាក្យនេះទៀតទេគឺយើងប្រើតែពាក្យឃាតកម្មហ្នឹង ដែលសំដៅទៅលើអំពើសម្លាប់មនុស្សដោយចេតនា។ អត្ថន័យរបស់វាគឺ អំពើសម្លាប់មនុស្សដោយចេតនាតាមគ្រប់មធ្យោបាយ ទោះបីជាប្រើអាវុធក៏ដោយ ឬមិនប្រើអាវុធ ក៏ដោយ ឱ្យតែសម្លាប់មនុស្សតាមឆន្ទៈរបស់ជនល្មើសគឺ គាត់ចង់ផ្តាច់ជីវិតរបស់មនុស្សដូច្នេះគាត់ត្រូវបានចាត់និង កំណត់ក្នុងបទល្មើសឃាតកម្មទាំងអស់។

### ១.២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល

នៅមុនពេលក្រមព្រហ្មទណ្ឌត្រូវបានអនុវត្តទាំងស្រុងនោះ បទល្មើសឃាតកម្មឬអំពើមនុស្សឃាតដោយចេតនាត្រូវបានចែងផ្តន្ទាទោសដោយមាត្រា ៣២ ក្នុងមាតិកាទី៤ស្តីពីបទឧក្រិដ្ឋនៃច្បាប់ ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩២ ដែលមាត្រានេះ ត្រូវបានកែប្រែដោយច្បាប់ស្តីពី "ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ" ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២។ មាត្រា៤ នៃច្បាប់សោធនកម្មបានចែងថា "ជនណាដែលបានសម្លាប់មនុស្សដោយចេតនា ឬ ប៉ុនប៉ងសម្លាប់ដោយចេតនាដោយគ្មានស្ថាន ទម្ងន់ទោសដែលមានចែងក្នុងមាត្រា៣២ ដោយបានប្រើអាវុធ ឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងតម្រូវឱ្យធ្វើការក្នុងពន្ធនាគារពី ១០ឆ្នាំ (ដប់) ១៥ឆ្នាំ (ដប់ប្រាំ)"។

ទាំងអស់ដែលបានបកស្រាយខាងលើគឺជា ធាតុផ្សំនីត្យានុកូល ឬ ជាធាតុច្បាប់ដែរយើងមើលឃើញនិងព្យាយាមបង្ហាញទាំងនៅក្នុងច្បាប់ចាស់និងច្បាប់ថ្មី។ ប៉ុន្តែចាប់ពីពេលនេះទៅ សូម

អ្នកអាន និងអ្នកដែលកំពុងសិក្សាទាំងអស់មេត្តាផ្តោតអារម្មណ៍ សិក្សាភាគច្រើនតែលើក្រមព្រហ្មទណ្ឌថ្មីត្រង់មាត្រា ១៩៩ ទៅបានហើយ។

### ២ ធាតុសត្យានុម័តនៃបទឃាតកម្ម

ឥឡូវយើងពិនិត្យមើលអំពើធាតុសត្យានុម័ត ឬ ធាតុសម្ភារៈនៃបទល្មើសឃាតកម្ម និងលក្ខខណ្ឌសំខាន់ៗនៃធាតុសត្យានុម័ត ឬ ធាតុសម្ភារៈនៅក្នុងបទល្មើសនេះដូចតទៅ៖

#### ២.១ អំពើសម្លាប់ ឬអំពើផ្តាច់ជីវិត ឬអំពើប្រល័យជីវិតរបស់មនុស្ស

បទឃាតកម្ម ឬបទល្មើសមនុស្សឃាតដោយចេតនា គឺជាប្រភេទបទល្មើសសកម្ម ដែលជាអំពើសម្ភារៈនៃបទល្មើសនេះត្រូវស្តែងឡើងក្រោមរូបភាពជាអំពើសម្ភារៈជាវិជ្ជមាន និយាយបានម្យ៉ាងទៀតថា អំពើសម្លាប់មនុស្សនេះត្រូវស្តែងឡើងជាកាយវិការបង្ហាញមកខាងក្រៅតាមរយៈអំពើជាសម្ភារៈមួយ ឬច្រើន។ អំពើសម្ភារៈនេះអាចជាអំពើដាច់ដោយឡែក ឬជាអំពើសម្ភារៈច្រើនរួមគ្នាដែលបណ្តាលឱ្យជនដទៃស្លាប់ ឬ ក៏អាចត្រឹមតែបណ្តាលឱ្យជនដទៃរបួសធ្ងន់ធ្ងរប៉ុណ្ណេះព្រោះថាអំពើមនុស្សឃាតដោយចេតនា គឺជាបទឧក្រិដ្ឋដែលការប៉ុនប៉ងប្រព្រឹត្តអំពើនេះក៏ត្រូវផ្តន្ទាទោសដូចគ្នានឹងបទល្មើសបានសម្រេចដែរ។ អំពើសម្ភារៈនេះអាចស្តែងឡើងតាមគ្រប់មធ្យោបាយទាំងអស់ដូចជា ការវាយរហូតដល់ស្លាប់ ការសម្លាប់ដោយបំពុល ដោយការប្រើប្រាស់អាវុធដោយការប្រើខ្សែរឹតក ដោយឆក់នឹងចរន្តអគ្គីសនី ឬដោយការប្រើប្រាស់រថយន្តជាដើម។ល។ ប៉ុន្តែប្រសិនបើការប្រព្រឹត្តអំពើសម្លាប់មនុស្សដោយចេតនា ធ្វើឡើងក្រោមរូបភាពមួយឃោរឃៅ ឬក្រោមរូបភាពជាទារុណកម្មនោះ អំពើទាំងនោះនឹងក្លាយជាស្ថានទម្ងន់ទោសនៃអំពើឃាតកម្មដោយចេតនានោះផងដែរ។

#### ២.២ លក្ខណៈសម្បត្តិនៃជនរងគ្រោះ

ទាក់ទងនឹងជនរងគ្រោះយើងអាចសាកល្បងបង្ហាញនូវលក្ខណៈសម្បត្តិ៣គឺ

- ជនរងគ្រោះត្រូវកើតចេញពីផ្ទៃម្តាយមកហើយនៅមានជីវិត
- ជនរងគ្រោះត្រូវតែជាអ្នកដទៃយ៉ាងដាច់ខាត និងក្រៅពីជនល្មើស
- ជនរងគ្រោះត្រូវតែជាជនដែលរស់រានមានជីវិត។

យើងនឹងធ្វើការបកស្រាយនូវចំណុចលម្អិតទាំង៣ខាងលើនេះឱ្យបានក្បោះក្បាយដូចខាងក្រោម៖

– ជនរងគ្រោះត្រូវកើតចេញពីផ្ទៃម្តាយមកហើយមានជីវិត៖

ដើម្បីឱ្យចូលក្នុងធាតុផ្សំនៃអំពើឃាតកម្ម គឺត្រូវតែមានជនរងគ្រោះ មានន័យថាជនរងគ្រោះគឺមនុស្សដែលកើតចេញពីផ្ទៃម្តាយមកហើយមានជីវិតគឺ លុះត្រាតែកើតចេញមកភ្លាមទៅជាមនុស្ស

ជាមុនសិនទោះបីជាកើតមកភ្លាមគេហៅគាត់ជាទារកក៏ដោយ។ ដូច្នេះទាល់តែមានកើតចេញពីផ្ទៃម្ដាយមកហើយ គាត់នៅរស់គឺមានជីវិតហើយយើងទៅសម្លាប់ អំពើបែបនឹងបានយើងហៅថាការប្រព្រឹត្តនូវអំពើឃាតកម្មដូចជា កើតមកទារកនោះនៅរស់តែមានអ្នកទៅច្របាច់កទារកនោះ ឬ ទៅជ្រមុចទឹកទារកនោះឱ្យស្លាប់នេះគឺជា ឃាតកម្ម។ ហេតុនេះលក្ខខណ្ឌទី១ គឺត្រូវមានជនរងគ្រោះដែលកើតចេញពីផ្ទៃម្ដាយមកមានជីវិត។

**ចំណាំ៖** តែបើមិនទាន់ចេញមកពីផ្ទៃម្ដាយផងនោះការរំលូតទារកក្នុងផ្ទៃមិនមែនជាបទឃាតកម្មទេ។ ត្រង់ចំណុចនេះគឺយើងត្រូវទៅអនុវត្តតាមច្បាប់ព្រហ្មទណ្ឌពិសេសគឺ ច្បាប់ស្ដីពីការរំលូតកូនវិញ។

– ត្រូវតែជាអ្នកដទៃ ក្រៅពីជនល្មើសជាដាច់ខាត អ្នកដទៃនៅទីនេះ គឺមិនមែនខ្លួនឯងនោះ ប្រសិនបើធ្វើការសម្លាប់ខ្លួនឯង ឬមួយធ្វើអត្តឃាតខ្លួនឯង គឺមិនចូលជាបទឃាតកម្មទេ។

ឧទាហរណ៍៖ ឈ្មោះ "ក" យល់ឃើញថាខ្លួនឯងអស់សង្ឃឹមក្នុងជីវិតហើយមិនដឹងថារស់នៅធ្វើអីទៀតរួចក៏យកថ្នាំពុលមកផឹកសម្លាប់ខ្លួនឯងទៅ។ ដល់ពេលគាត់អត់ស្លាប់ ស្រាប់តែយើងទៅចាប់គាត់ដោយចោទពីបទ ប៉ុនប៉ងធ្វើឃាតកម្ម បើយោងតាមមាត្រាលើនេះគឺមិនមែនជាបទឃាតកម្មទេ ពីព្រោះវាគឺ ជាជីវិតរបស់ខ្លួនឯង។ ដូច្នេះនៅក្នុងការដែលសម្លាប់ជនរងគ្រោះនេះគឺលុះត្រាតែជនរងគ្រោះនោះគឺជាអ្នកដទៃ។ ហើយពាក្យថាជនរងគ្រោះជាអ្នកដទៃហ្នឹងគឺសំដៅទៅលើអ្នកណាដែលក្រៅពីរខ្លួនឯង តែសូមកុំទៅច្រឡំថាក្រៅពីសាច់ញាតិ មិនមែនទេអ្នកណាក៏ដោយ ជីដូនជីតាក៏ដោយ ឪពុកម្ដាយក៏ដោយ សហព័ទ្ធក៏ដោយ កូនចៅក៏ដោយ។ល។ ឱ្យតែមិនមែនជាខ្លួនឯង ឬ ក្រៅពីខ្លួនឯង គឺជាអ្នកដទៃទាំងអស់ហើយដែលនៅក្នុងអត្ថន័យច្បាប់គឺជនរងគ្រោះជាអ្នកដទៃដាច់ខាត។ ជាងនេះទៅទៀតប្រសិនបើជនរងគ្រោះប្រភេទនេះគឺជាស្ថានភាពទូទៅ ដែលចៅក្រមតែងតែលើកយកមកធ្វើការពិចារណាដើម្បីធ្វើការកំណត់អំពីទណ្ឌកម្ម ដែលត្រូវផ្ដន្ទាទោសលើជនល្មើសនោះ ។

– ត្រូវតែជាមនុស្សដែលរស់រានមានជីវិត

ចុះហេតុដូចម្ដេចបានជា ខ្ញុំលើកពីបញ្ហារស់រានមានជីវិត? ឧបមាថាជាសាក សពជនម្នាក់ស្លាប់ហើយ ម៉្យាងទៀតជនល្មើសដឹងថាស្លាប់ហើយពោលថា "មកមិនទាន់ អានេះងាប់បាត់" រួចគាត់ក៏ទាញកាំភ្លើងទៅដល់បាញ់ជនដែលជាសាកសពនោះចំនួន២ គ្រាប់ទៅ សួរថាតើអំពើដែលគាត់បាញ់សាកសពនេះជាអំពើឃាតកម្មដែរឬទេ? ជាចម្លើយគឺ អត់ទេពីព្រោះឃាតកម្មចេតនារបស់ជនល្មើសចង់ផ្ដាច់ជីវិតជនរងគ្រោះ ចុះបើជនរងគ្រោះដាច់ជីវិតទៅហើយ ឥឡូវទៅធ្វើឃាតកម្មយ៉ាងម៉េចទៀត? តែអំពើនេះគឺចូលបទល្មើសផ្សេងមួយទៀតគឺ "បទប៉ះពាល់ដល់បូរណភាពសាកសព" វិញពីព្រោះវាទាក់ទងជាមួយនឹងការគោរពបូជានិង ជាអំពើមួយដែលប៉ះពាល់ដល់

ស្មារតីរបស់ជនទាំងឡាយណាដែលនៅរស់។ អីចឹងអំពើនេះមិនមែនជាអំពើឃាតកម្មទេ។ ប៉ុន្តែរឿងមួយទៀតយើងលើកជាឧទាហរណ៍ថា៖ ជនឈ្មោះ "ក" ចង់ស្លាប់ ជនឈ្មោះ "ខ" ហើយគាត់ ដឹងថា "ខ" នៅផ្ទះថ្ងៃហ្នឹងគាត់ឡើងទៅដល់ក៏បាញ់ "ខ" ប៉ុន្តែ "ខ" មុននឹង "ក" បាញ់ហ្នឹងគឺ "ខ" ដាច់ខ្យល់ស្លាប់ដោយសារខ្យល់គរមុនប្រហែលជា១ម៉ោងរួចហើយប៉ុន្តែ "ក" អត់ដឹងថា "ខ" ស្លាប់ទេ ដោយឡើងទៅដល់បានបាញ់ទៅកាន់ "ខ" ស្លាប់បាត់ទៅហើយ និងស្លាប់តាំងពីមុនពេលដែល "ក" ទៅបាញ់នោះទៀត។ សំណួរសួរថាតើអំពើនេះយ៉ាងម៉េចដែរ? ពីព្រោះក្រោយធ្វើកោសល្យវិច័យឃើញថាការស្លាប់របស់ "ខ" ហ្នឹងមិនមែនដោយសារតែការបាញ់របស់ "ក" ទេ គឺដោយសារខ្យល់គរ ឬដោយសារស្ថានភាពកាលៈទេសៈផ្សេងទៀត។ តើអំពើដែល "ក" បាញ់ "ខ" នេះជាអំពើឃាតកម្មដែរឬទេ? ចម្លើយពិតប្រាកដនោះ គឺជាអំពើ "ប៉ុនប៉ងឃាតកម្ម" ព្រោះការប្រព្រឹត្តបទល្មើសរបស់ "ក" មិនបានសម្រេច ដោយសារកត្តាក្រៅឆន្ទៈផ្សេងទៀតមករារាំង មានន័យថា "ក" ទៅសម្លាប់ "ខ" គាត់អត់ដឹងថា "ខ" ស្លាប់ ទៅហើយទេតែបើដឹងថា "ខ" ស្លាប់គាត់នៅតែបាញ់ នេះគឺជាអំពើប៉ះពាល់ដល់បូរណភាពសាកសពវិញ ប៉ុន្តែរឿងនេះ "ក" នៅតែគិតថា "ខ" នៅរស់ ដូច្នេះអំពើគាត់បាញ់នេះគឺជាអំពើឃាតកម្មនេះគឺ អាស្រ័យទៅលើធាតុផ្សំអត្តនោម័តិ ឬធាតុចេតនាមួយទៀត។ សួរថា តើគាត់ដឹងទេនៅអំពើរបស់ គាត់ថានៅពេលដែលគាត់បាញ់ តើជននោះស្លាប់ឬនៅ? ក្នុងចិត្តគាត់គឺនៅតែគិតថាជននោះអត់ទាន់ស្លាប់ ឬជាជនដែលនៅមានជីវិត។ អំពើនេះនៅតែជាអំពើឃាតកម្មដដែល។

ជនរងគ្រោះអាចជាមនុស្សគ្រប់ប្រភេទ ហើយជនរងគ្រោះអាចនឹងមិនត្រូវបានគេស្គាល់ អត្តសញ្ញាណ ឬមួយក៏សាកសពរបស់ជនរងគ្រោះអាចមិនត្រូវបានគេរកឃើញ។ ប៉ុន្តែអ្វីដែលសំខាន់ដើម្បីឱ្យអំពើនោះត្រូវបានចាត់ទុកថាជាអំពើមនុស្សឃាតដោយចេតនាបាននោះគឺ ត្រូវបង្ហាញឱ្យឃើញថាជនរងគ្រោះគឺជនរងគ្រោះជាមនុស្សដែលនៅរស់រានមានជីវិតនៅពេល ដែលមានអំពើសម្លាប់ ឬ ប្រល័យជីវិតមនុស្សកើតឡើង។ ការផ្តល់សេចក្តីស្លាប់ដល់ជនរងគ្រោះទោះ បីជាជនរងគ្រោះកំពុងទទួលរងនូវការឈឺចាប់ ហើយអាចរស់នៅមានជីវិតបានតែប៉ុន្មាននាទីទៀត ក៏ដោយ ក៏គេចាត់ទុកថាអំពើនោះជាអំពើមនុស្សឃាតដោយចេតនាដែលត្រូវផ្តន្ទាទោសផងដែរ។

ដូច្នេះហើយពេលខ្លះការតម្រូវឱ្យជនរងគ្រោះមានជីវិតនៅពេលដែល មានអំពើសម្លាប់មនុស្សគឺ ពុំមែនជាលក្ខខណ្ឌចាំបាច់ដាច់ខាត ដើម្បីផ្តន្ទាទោសជនល្មើសឡើយ។ ជាគោលការណ៍ គេធ្វើការផ្តន្ទាទោសចំពោះអំពើសម្លាប់ ឬ ប្រល័យជីវិតមនុស្សដែលធ្វើទៅលើសាកសព (ដូចជាការបាញ់ប្រហារទៅលើសាកសពដោយស្មានថាជនរងគ្រោះនោះនៅរស់រានមានជីវិត) ប៉ុន្តែពុំមែនឈរលើមូលដ្ឋាននៃការប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាទៅវិញ។ យោងទៅតាមទ្រឹស្តីនេះ គេមិន

អាចចាត់ទុកថាមានអំពើមនុស្សឃាតបានសម្រេចកើតនោះទេ ពីព្រោះថានៅពេលមានអំពើសម្លាប់ ឬ បានប្រល័យជីវិតមនុស្សជនរងគ្រោះពុំមែនជាមនុស្សមានជីវិតទេ ប៉ុន្តែជាសាកសពទៅវិញ។ ការស្លាប់មុនអំពើប្រល័យជីវិតមនុស្សគឺ ជាកាលៈទេសៈមួយដែលស្ថិតនៅក្រៅឆន្ទៈរបស់ចារីនៃបទល្មើស ហើយអំពើសម្លាប់ ឬ ប្រល័យជីវិតមនុស្សនោះគឺជាអំពើដែលត្រូវបានគេចាត់ទុកថាជាការចាប់ផ្ដើមប្រព្រឹត្តបទល្មើស ដែលជាលក្ខខណ្ឌមួយនាំឱ្យអំពើនោះក្លាយទៅជាអំពើប៉ុនប៉ងដែលមានទោស ឬ (បទល្មើសប៉ុនប៉ង)។[5]

កំណត់សម្គាល់៖ នៅក្នុងធាតុផ្សំសត្យានុម័តនេះ ចំពោះអំពើជាសម្ភារៈគឺត្រូវមានទំនាក់ទំនងពិតប្រាកដ និងច្បាស់លាស់ជាមួយនឹងមរណភាពរបស់ជនរងគ្រោះដែលគេហៅទំនាក់ទំនងរវាងហេតុ និងផលនេះបើយោងតាមទ្រឹស្ដីនៃ "នីតិព្រហ្មទណ្ឌទូទៅ"។

### ៣. ធាតុអត្តនោម័តិនៃបទឃាតកម្ម

បើយោងទៅតាមក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៩ យើងឃើញថាធាតុអត្តនោម័តិនៃបទឃាតកម្មមានករណីបីចម្បងៗគឺករណីទី១ មានចេតនាចង់ផ្ដាច់យកជីវិតរបស់ជនរងគ្រោះ ករណីទី២ មានការយល់ព្រមពីជនរងគ្រោះ និងការការពារស្របច្បាប់ និងច្រឡំ។

#### ៣.១ ករណីមានចេតនាចង់ផ្ដាច់យកជីវិតជនរងគ្រោះ

ចំពោះធាតុចេតនានៃអំពើឃាតកម្មគឺ ជនល្មើសចង់ផ្ដាច់ជីវិតរបស់ជនរងគ្រោះមានន័យថាចង់ឱ្យជនរងគ្រោះស្លាប់បាត់បង់ជីវិតពីលើលោកនេះតែម្ដង។ យើងអាចបន្ថែមទៀតថា ធាតុអត្តនោម័តិនៃអំពើមនុស្សឃាតដោយចេតនាគឺ សំដៅលើចេតនារបស់ចារីនៃបទល្មើសក្នុងការផ្ដល់សេចក្ដីស្លាប់ដល់ជនរងគ្រោះ។ ធាតុចេតនាសម្លាប់មនុស្សនេះ គឺជាធាតុសំខាន់បំផុតនោះ គឺអាចឱ្យមានការបែងចែកអំពើមនុស្សឃាតដោយចេតនាចេញពីបទល្មើសផ្សេងៗទៀតផងដែរ។ វាអាចបណ្ដាលឱ្យមានលទ្ធផលដូចគ្នា គឺការបាត់បង់ជីវិតមនុស្សដូចគ្នា ដូចជាអំពើមនុស្សឃាត ដោយអចេតនាជាដើម។ ម្យ៉ាងទៀតចម្លើយសារភាពរបស់ចារីដែលជាទូទៅកម្រមាននេះគឺគ្រាន់តែអាចជាតម្រុយក្នុងការកំណត់ចេតនាទុច្ចរិតចង់សម្លាប់ជនរងគ្រោះ។ ដូចនេះជាទូទៅចៅក្រមត្រូវធ្វើសេចក្ដីសន្និដ្ឋានថា នូវធាតុចេតនាទុច្ចរិតនេះដោយធ្វើការពិចារណាទៅលើមូលហេតុនៃការប្រព្រឹត្តរបស់ជនល្មើស ឬធ្វើការវាយតម្លៃទៅលើកាលៈទេសៈផ្សេងៗ ដែលនៅជុំវិញសកម្មភាពជនល្មើស ឬ មរណភាពរបស់ជនរងគ្រោះដូចជា៖

- អាវុធប្រើប្រាស់៖ កាំភ្លើង គ្រាប់បែក

---

[5] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៧

- ពហុភាពនៃការកាប់ ចាក់ វាយដំ
- ពហុភាពនៃរបួសចំកន្លែងស្លាប់
- មូលហេតុនៃការប្រព្រឹត្តបទល្មើសជាដើម។ល។

ម្យ៉ាងវិញទៀត ការកំណត់ធាតុចេតនារបស់ជនល្មើសតាមរយៈការសន្មត់ ឬសច្ចធារណ៍ទាំងអស់នេះគឺជាអំណាចឆន្ទានុសិទ្ធិរបស់ចៅក្រមទាំងស្រុង។ ដូចនេះចៅក្រមអាចសន្មតថាមានចេតនាសម្លាប់មនុស្សហើយ នៅពេលដែលចារីនៃបទល្មើសបានដឹងថាអំពើរបស់ ខ្លួននោះនឹងបណ្ដាលឱ្យជនរងគ្រោះស្លាប់។ ប៉ុន្តែបញ្ហាអាចចោទឡើង ព្រោះថាការសន្មត់ដូច្នេះអាចនាំឱ្យយើងធ្វើការបែងចែករវាងចេតនា ឬក៏ឆន្ទៈសម្លាប់មនុស្ស និងការដឹងរបស់ជនល្មើសអំពីផលវិបាកនៃអំពើរបស់ខ្លួនថា នឹងបណ្ដាលឱ្យមានការបាត់បង់ជីវិតរបស់ជនរងគ្រោះ។ ជាគោលការណ៍ចេតនាសម្លាប់មនុស្សគឺមិនត្រឹមតែទាញចេញពីឆន្ទៈ របស់ជនល្មើសក្នុងការចង់ទទួលលទ្ធផលនៃអំពើរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាញចេញពីការដឹងជាមុនរបស់ជនល្មើសអំពើផលវិបាក ដែលនឹងកើតមានឡើងដោយសារអំពើររបស់ខ្លួនទៀតផង។

### ៣.២. ករណីមានការយល់ព្រមពីជនរងគ្រោះ

ការយល់ព្រមពីជនរងគ្រោះ ពុំមែនជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ លើកលែងតែច្បាប់ចែងផ្សេងពីនេះ។ ដូច្នេះ វេជ្ជបណ្ឌិត ដែលព្រមចាក់ថ្នាំសម្លាប់តាមការទទូចស្នើសុំរបស់អ្នកជំងឺ ដែលទទួលរងការឈឺចាប់យ៉ាងខ្លាំងបណ្ដាលមកពីជំងឺមហារីករាំរ៉ៃរបស់គាត់ដែលមិនអាចព្យាបាលបាន មិនអាចរួចផុតពីការចោទប្រកាន់ និង ផ្ដន្ទាទោសព្រហ្មទណ្ឌពីតុលាការឡើយ ប៉ុន្តែចៅក្រមក៏អាចធ្វើការពិចារណាទៅលើកាលៈទេសៈនេះដែរ ដើម្បីផ្ដល់ការសម្រាលទោសដល់ជនល្មើសបានផងដែរ។ ដូចនេះវាលែងមានបទប្បញ្ញត្តិចែងផ្សេងពីនេះមូលហេតុនៃបទល្មើសគឺពុំអាចលុបចោលនូវចេតនាសម្លាប់មនុស្ស និងអំពើមនុស្សឃាតដោយចេតនាបានឡើយ។

### ៣.៣ ករណីនៃការការពារស្របច្បាប់ និងករណីមានការភ័ន្តច្រឡំ

ការសម្លាប់មនុស្សដោយការពារស្របច្បាប់ ឬការពារធម្មានរូបដោយមានលក្ខខណ្ឌគ្រប់គ្រាន់តាមការកំណត់របស់ច្បាប់ គឺអាចជាមូលហេតុនៃការមិនទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌ។ ប៉ុន្តែការភ័ន្តច្រឡំលើជនរងគ្រោះ ពុំមែនជាមូលហេតុនៃការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ លើកលែងតែការភ័ន្តច្រឡំមួយចំនួនប៉ុណ្ណោះ ដែលអាចនាំឱ្យជនល្មើសរួច ផុតពីការចោទប្រកាន់ និងការផ្ដន្ទាទោសពីបទឃាតកម្ម ឬមនុស្សឃាតដោយចេតនាដែលជំនួស ដោយអំពើមនុស្សឃាតដោយអចេតនាវិញ ដូចជាជនម្នាក់បានបាញ់សំដៅសត្វដោយគិតថាជាសត្វ តែ

បែរជាទៅបាញ់ត្រូវជនម្នាក់បណ្តាលឱ្យស្លាប់ទៅវិញ (ចេតនាទុច្ចរិតនៅក្នុងអំពើនេះគេឱ្យឈ្មោះថា គឺជាចេតនាទុច្ចរិតដោយជាយថាហេតុ នៅក្នុងករណីនេះជនល្មើសត្រូវទទួលខុសត្រូវចំពោះកំហុសអចេតនាតែប៉ុណ្ណោះ)។ ដូច្នេះនៅក្នុងបទឃាតកម្មនេះធាតុផ្សំសំខាន់ៗរបស់វាគឺខ្ញុំសូមសម្រាយជូនប៉ុណ្ណឹង។

**កថាខណ្ឌទី៣ ទោសដែលត្រូវទទួលរងនៃបទឃាតកម្ម**

ទោសដែលត្រូវទទួលរងនៃបទឃាតកម្ម មានពីរករណី (ក) ករណីគ្មានស្ថានទម្ងន់ ទោស និង (ខ) ករណីមានស្ថានទម្ងន់ទោស។

**១ ករណីគ្មានស្ថានទម្ងន់ទោស**

សម្រាប់អំពើឃាតកម្មនេះប្រសិនគ្មានស្ថានទម្ងន់ណាមួយទេ គឺត្រូវតែទទួលទោស និង (ខ) ករណីមានស្ថានទម្ងន់ទោស។

**២ ករណីមានស្ថានទម្ងន់ទោស**

ប្រសិនបើប្រព្រឹត្តបទឃាតកម្មរួចហើយថែមទាំងបានបំពេញនូវលក្ខខណ្ឌណាមួយដែលមានចែងចាប់ពីមាត្រា ២០០ ដល់មាត្រា ២០៥ នោះជនល្មើសនឹងត្រូវទទួល នូវស្ថានទម្ងន់ទោសដូចខាងក្រោម៖

**២.១ បទឃាតកម្មគិតទុកជាមុន (មាត្រា ២០០)**

ក្នុងករណីឃាតកម្មធ្វើឡើងដោយមានការគិតទុកជាមុន ឬមានការពួនស្ទាក់ ដូច្នេះ ឃាតកម្មនេះមានឈ្មោះថា "ឃាតកម្មដោយគិតទុកជាមុន" ។ បញ្ញត្តិមាត្រា ២០០ចែងថា "ឃាតកម្ម គិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុនឬ ដោយការ ពួនស្ទាក់[6]។ យើងធ្វើការបក ស្រាយពាក្យគន្លឹះខាងក្រោម៖

- ការគិតទុកជាមុន គឺជាគម្រោងដែលបានបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។
- ការពួនស្ទាក់គឺជា អំពើឃ្លាំងចាំបុគ្គលណាម្នាក់ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។

ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។[7]

អ្វីទៅជាអំពើនៃការគិតទុកជាមុន?

---

[6] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០វិច្ឆិកា ២០០៩, មាត្រា២០០

[7] ដូចលេខ៦

"ការគិតទុកជាមុន" នេះយើងនឹងលើកឧទាហរណ៍មកវិភាគទាំងអស់គ្នាថាតើវាគឺជាអំពើឃាតកម្មគិតទុកជាមុនឬ ក៏មិនមែននោះទេ?

ឧទាហរណ៍១៖ នៅក្នុងស្ថានភាពបច្ចុប្បន្ន អ្នកខ្លះមានគ្រោះថ្នាក់ចរាចរណ៍បន្តិចបន្តួចពេលចុះពីលើឡានមកមិនជួយដោះស្រាយតាមផ្លូវច្បាប់ បែរជាទៅជជែកយកឈ្នះរៀងខ្លួនក៏ប៉ះសំដី និង គ្នារួចវាយគ្នារហូតដល់មានម្នាក់ស្លាប់។

ឧទាហរណ៍ទី២៖ នៅក្នុងករណីមួយទៀតគឺស្រដៀងគ្នាដែរពីព្រោះ "ក" និង "ខ" មានគ្រោះថ្នាក់ចរាចរណ៍រួចឈ្លោះគ្នាតឹងសរសៃក ហើយចង្អុលមុខគ្នាមួយសន្ទុះ ពួកគាត់ក៏ដើរចេញទៅបើកឡានរៀងៗខ្លួនបាត់ទៅ។ លុះក្រោយមក "ក" គិតថាតាំងពីកើតមកមិនដែលឃើញអ្នកណាប្រហើនដូចអាមួយហ្នឹងទេហ៊ានមកចង្អុលមុខឯង យើងគិតថាលែងចង់ឱ្យឃើញមុខវាតទៅទៀតនៅលើផែនដីនេះហើយ ទុកឱ្យរស់នៅក្នុងលោកទៀតមិនកើតទេ។ គ្រាន់តែជិះឡានបានប្រហែលជា ៤ ទៅ ៥ រយម៉ែត្រក៏បត់ឡានតាមទៅរក "ខ" វិញដល់ពេលឃើញ "ខ" ក៏ទាញកាំភ្លើងបាញ់ជាច្រើនគ្រាប់រហូតដល់ស្លាប់។

សំណួរ ៖ តើឧទាហរណ៍ទី១ និងទី ២ មួយណាគឺជាឃាតកម្មគិតទុកជាមុន?

ចម្លើយ៖ ភាពត្រឹមត្រូវគឺនៅក្នុងឧទាហរណ៍ទី២ព្រោះថាជាឃាតកម្មគិតទុកជាមុនដោយសារតែមានគម្រោងបើទោះបីជាគម្រោងគិតរៀបចំនៅក្នុងការធ្វើអំពើឃាតកម្មនេះរយៈពេលខ្លី ឬក៏រយៈពេលវែងប៉ុនណាក៏ដោយ។ មិនមែនមានន័យថាទាល់តែមានការរៀបចំនូវប្លង់សកម្មភាពដូចយើងធ្វើគម្រោងការងារនៅតាមស្ថាប័នអីនោះទេ គឺអត់ចាំបាច់ដល់ប៉ុណ្ណឹងទេគឺឱ្យតែគម្រោងគិតក្នុងចិត្តដើម្បីធ្វើយ៉ាងណាទៅសម្លាប់ជនរងគ្រោះ ទៅផ្តាច់ជីវិតជនរងគ្រោះទោះបីជារយៈពេលនៃការគិតទុកនេះមានរយៈពេលវែងឬ ខ្លីប៉ុនណាក៏ដោយ។

តើការពួនស្ទាក់សំដៅទៅលើអ្វី?

ករណីមួយទៀតគឺ "ការពួនស្ទាក់" គឺមានន័យថាទៅឃ្លាំចាំមើលជនរងគ្រោះនៅកន្លែងណាមួយក្នុងគោលដៅផ្តាច់ជីវិតជនរងគ្រោះ។ បើកាលណាមានការឃ្លាំចាំដើម្បីទៅផ្តាច់ ជីវិតជនរងគ្រោះបែបនេះអំពើដែលធ្វើឡើងទៅលើជនរងគ្រោះនោះគេហៅថា "ឃាតកម្មគិតទុកជាមុន" ទោះបីជាមានការភ័ន្តច្រឡំទៅលើជនរងគ្រោះក៏ដោយ។

ឧទាហរណ៍៖ "ក" រង់ចាំដើម្បីសម្លាប់ "ខ" ហើយដឹងថា "ខ" ជារៀងរាល់ថ្ងៃដល់ម៉ោងប៉ុណ្ណឹងគឺដឹងថាដើរមកតាមផ្លូវហ្នឹងហើយ រួចខ្លួនក៏ទៅរង់ចាំនៅផ្លូវហ្នឹងដែរទៅស្រាប់តែ "ខ" មកដល់ "ក" បានឃើញក៏ដកកាំភ្លើងបាញ់ "ខ" រហូតដល់ស្លាប់បាត់ទៅនេះគឺជាឃាតកម្មគិតទុកជាមុន។ ចុះបើថៃដន្យអី នៅថ្ងៃហ្នឹងស្រាប់តែមានអ្នកដែលស្លៀកពាក់សំលៀកបំពាក់ និងរាងរៅគឺវាស្រដៀងនឹង

"ខ" ដែរ តែ "ខ" អត់បានមកទេ គ្រាន់តែអ្នកផ្សេងដែលស្រដៀងហ្នឹងគាត់ដើរមកតាមផ្លូវនិងដែរ ស្រាប់តែ "ខ" ក៏បាញ់យកតែម្តងដោយគ្មានបានចាំមើលមុខ "ខ" ឬមិន "ខ" ទេដោយគិតថាអាហ្នឹងហើយ សម្បុរហ្នឹងហើយ ខោអាវនិងហើយក៏បាញ់ជាច្រើនគ្រាប់បាត់ស្លាប់ទៅ ។

សំនួរៈ សួរថាតើនេះគឺជាអំពើឃាតកម្មគិតទុកជាមុនដែរឬទេ?

ចម្លើយៈ នេះគឺនៅតែជាឃាតកម្មគិតទុកជាមុនដដែល ទោះបីជាគោលដៅជនរងគ្រោះនេះច្រឡំក៏ដោយ ព្រោះមានការពួនស្ទាក់ជនរងគ្រោះរួចហើយ ដូច្នេះនៅតែជាឃាតកម្មគិតទុកជាមុនដដែល។

នៅក្នុងអំពើនេះគឺត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា ២០០ គឺត្រូវដាក់ពន្ធនាគារអស់មួយជីវិតតែម្តង[8]។

## ២.២. បទឃាតកម្មដោយការប្រើថ្នាំពុល (មាត្រា ២០១)

បទឃាតកម្មដោយការប្រើប្រាស់ថ្នាំពុល ក៏ជាបទល្មើសដែលមានស្ថានទម្ងន់ទោសមួយដែរ។ "ឃាតកម្មដែលប្រព្រឹត្តដោយការប្រើថ្នាំពុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០ (សាមសិប) ឆ្នាំ[9]"។

ឧទាហរណ៍ ៖ មានបុគ្គលពីរនាក់បានឈ្លោះគ្នា ស្រាប់តែម្នាក់បានឃើញថានៅក្បែរហ្នឹងគឺ គ្មានអ្វីក៏ចាប់បានថ្នាំបាញ់មូសមក រួចក៏កៀកកជនរងគ្រោះដាប់ ហើយយកថ្នាំបាញ់មូសនោះបាញ់ ដាក់ច្រមុះជនរងគ្រោះរហូតដល់ស្លាប់។ នេះគឺជាឃាតកម្មដោយប្រើប្រាស់ថ្នាំពុល ពីព្រោះអត់មានបានប្រើមធ្យោបាយអ្វីផ្សេងទៀតទេ គឺយកថ្នាំពុលមកប្រើដើម្បីផ្តាច់ជីវិតជនរងគ្រោះ។

អ្នកខ្លះបានចោទសួរថា តើនេះមិនមែនជាឃាតកម្មគិតទុកជាមុនទេឬ? សូមកុំច្រឡំចំពោះរឿងរៀបចំគម្រោងដើម្បីដាក់ថ្នាំបំពុលជនរងគ្រោះឱ្យស្លាប់ នោះទើបយើងហៅថាជា"ឃាតកម្មគិតទុកជាមុន" ចំណែកបញ្ហានេះ អត់បានរៀបគម្រោងឡើយ។ ឧបមាថាមកដល់គាត់អត់បានគិតនិងរៀបចំគម្រោង ក្នុងការសម្លាប់ជនហ្នឹងពីមុនទេ ស្រាប់តែថ្ងៃហ្នឹងក៏មានរឿងទាល់ទែងគ្នា ហើយឃើញថ្នាំពុលនៅក្បែរហ្នឹងហើយ ក៏ស្ទុះទៅទាញបានថ្នាំពុលនោះយកមកធ្វើជាមធ្យោបាយ ដើម្បីសម្លាប់ជនរងគ្រោះ។ ហើយសូមកុំយល់ច្រឡំ ! ប្រយ័ត្នទៅឃើញមាត្រា ២០១ យកទៅប្រើចំពោះអ្នកដែលរៀបចំគម្រោងដាក់ថ្នាំពុលឱ្យគេស្លាប់នោះថាចូលក្នុងមាត្រានេះហើយ, គឺមិនមែនទេ។

ឧទាហរណ៍ៈ ក មានគំនុំគុំគួនជាមួយ ខ រួចក៏ចង់សម្លាប់។ ក ក៏បានអញ្ជើញ ខ ឱ្យទៅញ៉ាំបាយជាមួយខ្លួន។

---

[8] ដូចលេខ៦

[9] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០១

ពេលទៅដល់គាត់បានរៀបគម្រោងដាក់ថ្នាំពុលនៅក្នុងបាយដើម្បីឱ្យ ខ បានហូបបាយនោះទៅត្រូវស្លាប់ហើយ។

សួរថាតើអំពើនេះត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រាមួយណា? (បទឃាតកម្មគិតទុកជាមុន មាត្រ ២០០ ឬ បទឃាតកម្មដោយការប្រើថ្នាំពុល មាត្រា ២០១) ចម្លើយៈ គឺតាមមាត្រា ២០០ "ឃាតកម្មគិតទុកជាមុន" ព្រោះវានៅតែជាអំពើដែលបានគិតទុកជាមុនដដែល។ ហើយសូមកុំយល់ច្រឡំ ! ប្រយ័ត្នយើងមើលឃើញមាត្រា ២០១ "បទឃាតកម្មដោយការប្រើថ្នាំបំពុល" ដោយភ្លេចគិតទៅដល់ថាមានការរៀបចំគម្រោងទុកជាមុនឱ្យសោះ។

ការប្រើប្រាស់ថ្នាំពុលនៅទីនេះ គឺចង់បញ្ជាក់ឱ្យឃើញថាយកថ្នាំពុលជាមធ្យោបាយក្នុការធ្វើឃាតកម្មដែលមិនចូលធាតុផ្សំនៃឃាតកម្មគិតទុកជាមុន គឺមិនបានរៀបចំគម្រោងអ្វីមុននោះទេ។ ចំពោះឃាតកម្មដោយប្រើថ្នាំពុលនេះគឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬដាក់គុក ពី ១៥ (ដប់ប្រាំ) ឆ្នាំទៅដល់ ៣០ (សាមសិប) ឆ្នាំ[10]។

## ២.៣ បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ គឺជាឃាតកម្មទៅលើជនរងគ្រោះមួយចំនួនដែលច្បាប់កំណត់ថាត្រូវតែទទួលស្ថានទម្ងន់ទោស នៅក្នុងបញ្ញត្តិនេះបានតែងអំពីជនរងគ្រោះទាំងនោះថាៈ "ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ[11]ៈ

- បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ។
- នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែងឬ កាលបើជនល្មើសបានដឹង។
- បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃការដែលមានជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។
- អ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារដែលជារបស់ខ្លួន។"[12]

យើងនឹងធ្វើការបកស្រាយរាល់ចំណុចនីមួយៗឱ្យបានក្បោះក្បាយ នឹងលើកឧទាហរណ៍បន្ថែមៈ

- បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃអាយុ

[10] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០១

[11] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០២

[12] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០២

នូវរាល់ត្រង់ចំណុចទី១នេះដែរ គឺច្បាប់ចង់ផ្តោតសំខាន់ទៅលើបុគ្គលដែលទន់ខ្សោយ តើការដែលទន់ខ្សោយនោះដោយសារកត្តាអ្វី? ចម្លើយ៖ នៅត្រង់ចំណុចទី១នេះគឺចង់សំដៅទៅលើបុគ្គលដែលទន់ខ្សោយពិសេសដោយមូលហេតុអាយុនៃបុគ្គល។

ដូច្នេះយើងសូមលើកយក ឧទារណ៍មកបញ្ជាក់និង បកស្រាយខាងក្រោមនេះឱ្យបានក្បោះក្បាយ៖

ឧទាហរណ៍៖ ការធ្វើឃាតមនុស្សដែលមានវ័យក្មេងពេក ហើយខ្វះលទ្ធភាពទប់ទល់ និងការពារខ្លួន ឬក៏អ្នកដែកមានវ័យចាស់ពេក បើមើលទៅវ័យមនុស្សចាស់គឺមានភាពទន់ខ្សោយទៅហើយដោយដើរទ្រេតទ្រូតៗ ពីព្រោះមានអាយុ ៧០-៩០ ឆ្នាំទៅហើយគ្រាន់តែថាក្មេងរត់ប៉ះក៏ដួលដែរទាំងនេះគឺជាឃាតកម្មទៅលើបុគ្គលដែលមានសភាពទន់ខ្សោយនោះដោយមូលហេតុនៃអាយុ។

ចំណាំ ៖ មិនមែនឱ្យតែអាយុគឺទន់ខ្សោយទេណា អត់យកមូលដ្ឋានមកមុននោះទេទោះគេថា បុគ្គលហ្នឹង ទន់ខ្សោយពិសេសដោយមូលហេតុអាយុក្តីក៏ដោយ។

ដូច្នេះយើងត្រូវតែពិនិត្យមើលស្ថានភាព ថាតើជននោះទន់ខ្សោយដែរឬអត់ បើមានអាយុប៉ុណ្ណឹង? បើសិនគាត់មានអាយុប៉ុណ្ណឹង គាត់មានស្ថានភាពទន់ខ្សោយទៅហើយនោះគឺការចោទប្រកាន់ដើម្បីផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ៣០(សាមសិប) ឆ្នាំការបើប្រព្រឹត្តអំពើនេះ[13]។ ដូចជាករណីប្រព្រឹត្តទៅលើក្មេងអាយុ ៤ ឆ្នាំ ៥ឆ្នាំ ជាដើមនោះគឺ១០០% ដែលហៅថាទន់ខ្សោយតិចទៅថាក្មេងហ្នឹងឃើញម៉ាប់ៗវាខ្លាំងដែរ អត់មែនខ្សោយទេគឺមិនមែនបែបណ្ណឹងឡើយពីព្រោះ ឃាតកម្មទៅលើក្មេងអាយុ ៣ ទៅ ១០ ឆ្នាំចុះមកក្រោមនេះគឺទន់ខ្សោយហើយ។ ចុះបើវាមានអាយុ ១៦ ទៅ ១៧ ឆ្នាំវិញ តើអាចទន់ខ្សោយដែរឬទេ? គឺអាចដែលក្នុងករណីដូចជាមនុស្សដែលបាក់ទឹកដោះតាំងពីក្មេងមករហូតធ្វើឱ្យស្គមស្គាំងតៃល្វៃៗ ដើរវីញរញ៉ែរៗដូច្នេះមនុស្សប្រភេទនេះហើយគឺជាមនុស្សដែលទន់ខ្សោយពិសេសនោះ។

- ករណីបុគ្គលដែលជានារីមានគត៌

នូវត្រង់ចំណុចទី២នេះដែរ គឺការប្រព្រឹត្តទៅលើនារីមានគត៌ ដូច្នេះឃាតកម្មចំពោះនារីមានគត៌ក៏ច្បាប់បានកំណត់ចូលទៅក្នុងស្ថានទម្ងន់ទោសផងដែរ។ បើសិនជាមានគត៌នោះមើលឃើញជាក់ស្តែងគឺចូលទៅក្នុងចំណុចនេះហើយ។ ករណីមួយទៀត គឺជនល្មើសដឹងថានាងមានគត៌ហើយនៅតែធ្វើឃាតកម្មទៅលើនារីម្នាក់នោះទៀត នោះនឹងចូលជាស្ថានទម្ងន់ទោស ឮតាមបញ្ញត្តិនៃមាត្រា ២០២ ចំណុចទី២ នេះដែរ។[14] នេះយើងនិយាយអំពីឃាតកម្មគ្មានការគិតទុកជាមុនទេ

---

[13] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០២

[14] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០២

ដែលត្រូវទទួលស្គាល់ស្ថានទម្ងន់ទោសបែបនេះ។ តែបើសិនជា បានគិតទុកជាមុនគឺចូលទៅក្នុង មាត្រា២០០ (បទឃាតកម្មគិតទុកជាមុន) ទាំងអស់។

ចំណាំ៖ សូមកុំយល់ច្រឡំថាប្រព្រឹត្តទៅលើនារីមានគភ៌ និងមានការគិតទុកជាមុន បែរជាទៅយក មាត្រា២០២ មកប្រើវិញ គឺខុសនឹងស្មារតីនៃក្រមព្រហ្មទណ្ឌនេះហើយ។ ចំពោះបញ្ហានៃការគិតទុក ជាមុនទោះបីជាបុគ្គលប្រភេទហ្នឹងជាមនុស្សទន់ខ្សោយក៏ដោយ ជានារីមានគភ៌ក៏ដោយ គឺត្រូវប្រើ មាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ទាំងអស់ ឱ្យតែមានការគិតទុកជាមុន។ តែផ្ទុយទៅវិញ ប្រសិនឥតមានការគិតទុកជាមុនទេនោះ ឱ្យតែប្រព្រឹត្តទៅលើប្រភេទបុគ្គលបែបនេះគឺត្រូវទទួល ស្ថានទម្ងន់ទោសតាមបញ្ញត្តិមាត្រា ២០២ (បទឃាតកម្មដែលមានស្ថានទម្ងន់ទោទាក់ទងនឹងជនរង គ្រោះ)។

- បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព

នូវត្រង់ចំណុចទី៣នេះដែរ គឺជាមនុស្សដែលទន់ខ្សោយពិសេស ដោយសារតែមូល ហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬប្រសិនបើ ជន ល្មើសបានដឹង។ សួរថាតើជំងឺដល់កម្រិតមួយណាដែលធ្វើឱ្យគាត់ទន់ខ្សោយ? ឬក៏ពិការភាពបែប ណាដែលធ្វើឱ្យគាត់ទន់ខ្សោយ? ចម្លើយ៖ មិនមែនគ្រាន់តែក្អកឬក៏ផ្តាសាយ ហើយមានឃាតកម្ម ទៅលើគាត់គឺចូលក្នុងចំណុចទី៣នេះទេ ឬគិតថាជាស្ថានភាពទន់ខ្សោយហើយគឺត្រូវប្រើមាត្រា ២០២ នោះឡើយ។ ក៏ប៉ុន្តែប្រសិនបើគាត់ឈឺធ្ងន់ធ្ងរមែនទែនហើយរហូតដល់ងើបពីលើគ្រែមិនចង់ រួចដើរ រញ៊ីរញ៉ូវៗទៅហើយ នៅពេលដែលមានឃាតកម្មទៅលើបុគ្គលប្រភេទនេះ គឺចូលទៅក្នុង បញ្ញត្តិ មាត្រា ២០២ (ឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ) ដែលជាមូល ហេតុនៃ ស្ថានទម្ងន់ទោស។ ដូច្នេះសូមញែកឱ្យច្បាស់ ប្រយ័ត្នយល់ច្រឡំថាឱ្យតែមានជម្ងឺគឺចូលទៅ ក្នុងស្ថានទម្ងន់ទោសទាំងអស់ គឺមិនមែនបែបនឹងទេ។ ឬមួយវិញទៀតគឺ ពិការភាព ចំពោះពាក្យថា ពិការភាពនេះក៏ត្រូវពិនិត្យទៅតាមស្ថានភាពមួយៗដែរ។មិនមែនពិការភាពដែលគ្រាន់តែកុតស្លឹក ត្រចៀកមួយជំហៀងទេ ពីព្រោះបើនិយាយពីពិការភាពជនប្រភេទនេះគឺពិការភាពហើយ ក៏ប៉ុន្តែសួរ ថាតើកម្រិតត្រឹមតែប៉ុណ្ណឹងទន់ខ្សោយឬក៏អត់? គឺអត់មែននោះទេ មានអ្វីដែលត្រូវទន់ខ្សោយត្រឹមតែ សភាពបែបនឹង ហើយមានអ្វីដែលត្រូវថមថយនូវលទ្ធភាពទប់ទល់របស់គាត់។ ចុះបើកុតដៃកុតជើង គឺចូលទៅក្នុងចំណុចទី៣នេះហើយបើគាត់ពិការភាពដៃម្ខាង និងមិនសូវមានកម្លាំង ក៏អាចចូលក្នុង រឿងយើងដែរ ដោយសារតែគាត់ថមថយកម្លាំងដែរហើយ ពីព្រោះមិនដូចអ្នកមានដៃពីរនោះទេ។

ចំណាំ៖ មាត្រានេះគឺមិនយកមូលហេតុស្រវឹងស្រា ឬញៀនគ្រឿងញៀន ថាចាត់ចូលទៅជាមូល ហេតុទន់ខ្សោយពិសេសនោះឡើយ។ ដូច្នេះ៖ ច្បាប់មិនលើកលែងករណីនេះទេ។

- បុគ្គលដែលជាអ្នករាជការសាធារណៈ

នៅត្រង់ចំណុចទី៤នេះ គឺប្រព្រឹត្តទៅលើអ្នករាជការសាធារណ៍ នៅក្នុងក្រមខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។ តើអ្នកណាគឺជាអ្នករាជការសាធារណៈ? អត្ថន័យលម្អិតគឺមានចែងក្នុងបញ្ញត្តិមាត្រា ៣០ នៃក្រមព្រហ្មទណ្ឌដើម្បីបញ្ជាក់ពីអត្ថន័យនៃអ្នករាជការសាធារណៈច្បាស់លាស់ និង រួមបញ្ចូលទាំងពលរដ្ឋដែលបានទទួលអាណត្តិ សាធារណៈដោយការបោះឆ្នោតផងដែរទាំងអស់នេះគឺសុទ្ធតែអ្នករាជការសាធារណៈទាំងអស់។ ដូច្នេះ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការសិក្សា ក្រោមប្រធានបទនេះយើងសូមលើកយកមាត្រា៣០ នៃក្រមព្រហ្មទណ្ឌមកបកស្រាយទាំងស្រុងខាងក្រោមនេះ៖

- អ្នករាជការសាធារណៈមានន័យថា[15]៖

១. បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការ ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិន គិតពីឋានៈ អាយុរបស់បុគ្គល នោះឡើយ។

២. បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬ សហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅ ក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

- ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតមានន័យថា៖

១. ពលរដ្ឋនោះគឺជាសមាជិករបស់ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងព្រមទាំងប្រជាពលរដ្ឋទាំងអស់ដែលទទួលបាននូវអាណត្តិសាធារណៈ ដោយការបោះឆ្នោតដើម្បីការបំពេញមុខងារសាធារណៈផ្សេងដទៃទៀត។

សរុបមក ប្រសិនបើជាប្រព្រឹត្តិអំពីឃាតកម្មទៅលើអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃការបំពេញមុខងាររបស់គាត់ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់គាត់គឺត្រូវទទួលនូវស្ថានទម្ងន់ទោសតាមចំណុចទី៤នៃមាត្រា២០២ ឃាតកម្មដែលស្ថានទម្ងន់ទោសទាក់ទងនិងជនរងគ្រោះ។

[15] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០២

សំណួរ៖ តើនៅក្នុងក្របខណ្ឌនៃការបំពេញមុខងារ និងនៅក្នុងឱកាសនៃការបំពេញមុខងារគឺខុសគ្នាដោយរបៀបណាទៅ?

ចម្លើយ៖ ចំពោះពាក្យថា នៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន គឺសំដៅទៅលើបុគ្គលដែលមានមុខងារ ហើយទៅធ្វើកិច្ចការ គឺជាកិច្ចការរបស់បុគ្គលនោះ។

ឧទាហរណ៍៖ ខាងមន្ត្រីនគរបាលយុត្តិធម៌ ចុះទៅធ្វើការត្រួតពិនិត្យបទល្មើស ស្រាប់តែនៅពេលឃើញជនល្មើសគាត់ក៏ដេញតាមជនល្មើសនោះ នៅខណៈពេលនោះជនល្មើសបានប្រព្រឹត្តអំពើឃាតកម្មទៅលើមន្ត្រីនគរបាលយុត្តិធម៌ នេះគឺហៅថា "អំពើឃាតកម្មទៅលើអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃមុខងារ"។

ចំណែកឯ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន គឺគាត់អត់មានមុខងារនៅកន្លែងនោះទេ ក៏ប៉ុន្តែគាត់នៅសហការជួយគេ។ ដូច្នេះអ្នកដែលទៅចូលរួមសហការជួយគេ ហើយគាត់គឺជាអ្នក រាជការសាធារណៈដែរ តែគាត់មានមុខងារគ្រាន់តែទៅចូលរួមសហការជួយគេ ដោយមិនមែនស្ថិតនៅក្នុងក្របខណ្ឌនៃមុខងាររបស់គាត់បែបនេះ គឺគេហៅថាអ្នករាជការសាធារណៈនៅក្នុងឱកាសនៃ ការបំពេញមុខងាររបស់ខ្លួន។

ឧទាហរណ៍៖ ដូចជាមន្ត្រីផ្សេងទៀតដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ហើយគាត់ទៅជួយសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលមានអំពើឃាតកម្មមកលើគាត់នោះ គឺគេហៅថា "អំពើឃាតកម្មលើអ្នករាជការសាធារណៈក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន"។ ដូច្នេះ ឃាតកម្មទៅលើអ្នករាជការសាធារណៈនេះ ទោះបីជានៅក្នុងក្របខណ្ឌនៃការបំពេញមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារក៏ដោយ គឺត្រូវទទួលនូវស្ថានទម្ងន់ទោសទៅតាមចំណុចទី៤នៃមាត្រា ២០២ (បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ)។

## ២.៤. បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ

"បទឃាតកម្មដោយមានស្ថានទម្ងន់ទោសដោយសារមានគោលដៅ ត្រូវតែផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំទៅ៣០(សាមសិប) ឆ្នាំ កាលបើប្រព្រឹត្តិអំពើបែបនេះ៖[16]

- ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរាំងជននោះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម។
- ជនរងគ្រោះ ជាសាក្សី ដើម្បីរារាំងកុំឱ្យផ្តល់សក្ខីកម្ម ឬផ្តល់ភស្តុតាងនៅពេល ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃពាក្យបណ្តឹងផ្សេងទៀត។

[16] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៣

- ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឱ្យ ជួសជុលព្យសនកម្ម។
- សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលដែលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត។"[17]

នៅក្នុងឃាតកម្មដោយមានគោលដៅនេះ គឺគោលដៅរបស់ជនល្មើសចង់ធ្វើឃាតកម្មទៅលើបុគ្គលមួយចំនួនដូចខាងលើដែលយើងបានដៅជាចំណុចនេះ ដើម្បីបញ្ចៀសនូវការស្វែងរកភាពយុត្តិធម៌។ ដើម្បីឱ្យយល់កាន់តែច្បាស់ចំពោះចំណុចខាងលើនេះ យើងសូមធ្វើការបកស្រាយរាល់ចំណុចទាំង៤ឱ្យបានលម្អិតនៅខាងក្រោមនេះ៖

- ករណីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមិនទាន់ប្តឹង

ចំណុចទី១៖ គឺឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីដើម្បីរាំងជននេះកុំឱ្យទៅប្តឹងបរិហារពីបទល្មើស ឬកុំឱ្យសុំធ្វើការជួសជុលព្យសនកម្ម។

ឧទាហរណ៍៖ មានបទល្មើសណាមួយកើតឡើង ជនល្មើសគិតថាធ្វើយ៉ាងម៉េចកុំឱ្យជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីនេះ ទៅប្តឹងបរិហារគាត់បាន ក៏ទៅសម្លាប់ផ្តាច់ជីវិតជនរងគ្រោះឬ ដើម បណ្តឹងរដ្ឋប្បវេណីបំបិទដានតែម្តង ក្នុងគោលបំណងកុំឱ្យមានអ្នកដឹងច្រើនពេកពីព្រោះបើគាត់នៅរស់ប្រាកដជាទៅប្តឹងហើយ ហេតុដូច្នេះក៏ធ្វើឃាតកម្មទៅលើគាត់។ នេះគឺជាឃាតកម្មដោយមានគោលដៅ ដូច្នេះត្រូវទទួលស្ថានទម្ងន់ទោសតាមបញ្ញត្តិមាត្រា ២០៣ ( បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ )។

- ករណីសាក្សី មិនទាន់ផ្តល់សក្ខីកម្ម

នៅត្រង់ចំណុចទី២៖ គឺឃាតកម្មទៅលើជនរងគ្រោះដែលជាសាក្សី គឺដើម្បីបញ្ចៀសកុំ ឱ្យរកយុត្តិធម៌បាន គាត់ក៏ទៅធ្វើឃាតកម្មទៅលើសាក្សីនោះ។ នេះគឺជាករណីអត់មានគម្រោងទេ តែប្រសិនជាមានគម្រោងគិតទុកជាមុនវិញគឺចូលទៅក្នុងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ (បទឃាតកម្មគិតទុកជាមុន)។ បញ្ហានេះគឺដោយសារតែគាត់ខឹងថាអ្នកដែលជាសាក្សីនោះបានដឹងរឿងដែលគាត់មិនចង់ឱ្យមានអ្នកដឹងច្បាស់ ម្ល៉េះហើយភ្លាមៗហ្នឹងគាត់ក៏ប្រាប់ដល់សាក្សីថាបើគេសួរអ្វីកុំឆ្លើយឱ្យសោះណា! ប្រសិនតុលាការហៅអីអ្នកឯងទៅធ្វើសាក្សីឱ្យគេប្រយ័ត្នត្រូវហាំ។ សាក្សីក៏តបថាបើគេហៅគឺត្រូវតែទៅធ្វើ និងនិយាយការពិតទាំងអស់។ ពេលនេះជនល្មើសក៏ដាក់មួយដំបង ឬសម្លាប់សាក្សីចោលទៅ ដែលទង្វើនេះគឺ សម្លាប់ផ្តាច់ជីវិតដើម្បីកុំឱ្យសាក្សីទៅផ្តល់សក្ខីកម្មជូនដល់ស្ថាប័ន

[17] ដូចលេខ១៥

ដែលមានសមត្ថកិច្ច។ នេះហើយគឺជាឃាតកម្មដោយមានគោលដៅ ត្រូវមានស្ថានទម្ងន់ទោសក្នុងមាត្រានេះ។

- ករណីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងរួចហើយ

នៅត្រង់ចំណុចទី៣៖ គឺឃាតកម្មទៅលើជនរងគ្រោះឬដើមប្តឹងរដ្ឋប្បវេណីពីព្រោះជន នេះបានបរិហារពីបទល្មើស ឬសុំឱ្យជួសជុលព្យាសនកម្មមានន័យថា គឺដោយសារតែជននោះទៅប្តឹងរួចហើយ ។ ជនល្មើសអត់មានគម្រោងគិតទុកជាមុនទេស្រាប់តែទៅដល់សួរថាម៉េចហើយរឿងហ្នឹងចប់គ្នាបានទេ អ្នកនោះក៏ឆ្លើយថាយើងបានប្តឹងរួចបាត់ទៅហើយមិនចាំបាច់ចប់គ្នាអីទេចាំតែទៅឆ្លើយនៅមុខតុលាការរួចសងសំណងយើងទៅបានហើយ ។ គ្រាន់តែជនល្មើសបានឮតែថាប្តឹងរួចហើយក៏តបទៅវិញថាស្អីគ្រាន់តែរឿងប៉ុណ្ណឹងសម្រួលគ្នាមិនបានដែរមែនទេឬ?ចាំបាច់អីដល់ថ្នាក់ប្តឹងអ្នកឯងបានប្តឹងរួចទៅហើយមែនទេ? ជនល្មើសគ្រាន់តែបានឮថា ប្តឹងរួចទៅហើយជនល្មើសក៏ខឹងសម្បារយ៉ាងខ្លាំងក៏យកដំបងនៅជិតដៃវាយយ៉ាងខ្លាំងហើយក៏ស្លាប់បាត់ទៅ។

នេះគឺជាឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានប្តឹងរួចហើយ។

- ករណីសាក្សី បានផ្តល់សក្ខីកម្មរួចហើយ

នៅត្រង់ចំណុចទី ៤៖ គឺឃាតកម្មទៅលើសក្សីដែលបានទៅផ្តល់សក្ខីកម្មរួចហើយនៅ មុខស្ថាប័នដែលមានសមត្ថកិច្ចណាមួយដូចជានៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ឬក៏នៅក្នុង ដំណាក់កាលនៃការស៊ើបសួរ ឬដំណាក់កាលនៃការជំនុំជម្រះ ឬក៏នៅក្នុងដំណាក់កាលនៃនីតិវិធី បណ្តឹងផ្សេងទៀត ស្រាប់តែជនល្មើសបានសម្លាប់សាក្សីនោះចោល នេះគឺជាស្ថានទម្ងន់ទោសដែរ សម្រាប់មាត្រា ២០៣ ប្រសិនបើគ្មានការគិតទុកជាមុនដូចបានចែងក្នុងមាត្រា ២០០ (បទឃាតកម្ម គិតទុកជាមុន) ។[18]

ចំនាំ៖ ចំណុចទី១ និង ចំណុចទី៣ គឺឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីដូចតែគ្នាទេ។ ប៉ុន្តែខុសគ្នាត្រង់ថា ចំណុចទី១ គឺជាជនរងគ្រោះឬដើមបណ្តឹងរដ្ឋប្បវេណីអត់ទាន់បានទៅប្តឹងទេ ឯចំណុចទី៣ គឺសក្សីបានទៅប្តឹងរួចទៅហើយ ។ ចំណែកឯចំណុចទី២ និងចំណុចទី៤ វិញម្តង គឺឃាតកម្មទៅលើសក្សីដូចគ្នា។ គ្រាន់តែខុសគ្នាត្រង់ថាចំណុចទី២ គឺសក្សីអត់ទាន់បានទៅ ផ្តល់ឆ្លើយ ឬផ្តល់សក្ខីកម្មនោះទេ ចំណែកឯចំណុចទី៤ វិញគឺសាក្សីបានផ្តល់ភស្តុតាងជូនតុលាការរួចហើយ ឬទៅផ្តល់ភស្តុតាងនៅចំពោះនីតិវិធីនៃបណ្តឹងណារួចហើយ ក្រោយមកជន

[18] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៣

ល្មើសក៏បានធ្វើឃាតកម្មទៅលើជនរងគ្រោះនោះ ។ យើងសូមបញ្ជាក់ឡើងវិញថាក្នុងករណីនេះដែលអត់មានគិតទុកមុន។ ដូច្នេះត្រូវផ្តន្ទាទោសពី ១៥(ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ[19]។

**២.៥. បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ**

"បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈត្រូវបាន ផ្តន្ទាទោសដាក់ពន្ធនាគាពី ១៥ (ដប់ប្រាំ) ឆ្នាំទៅ ៣០ (សាមសិប)ឆ្នាំ កាលណាដែលអំពើនេះត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុងក្របខណ្ឌនៃមុខងារឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន" ។[20]

ខាងលើយើងបានបកស្រាយ និងមើលឃើញអំពីឃាតកម្មទៅលើអ្នករាជការសាធារណៈនៅមាត្រា២០២ ចំណុច ២.៤ ។ ចំណែកឯមាត្រា ២០៤ វិញគឺជនល្មើសជាអ្នករាជការ សាធារណៈវិញម្តងដែលនៅក្នុងក្របខណ្ឌនៃមុខងាររបស់គាត់ ឬក្នុងឱកាសនៃការបំពេញមុខងារ របស់គាត់ហើយគាត់ក៏បានទៅធ្វើឃាតកម្មលើរូបគេ។

- ប្រព្រឹត្តអំពើនៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន

ករណីមានដូចជាមន្ត្រីមួយដែលចុះទៅប្រតិបត្តិច្បាប់ ដោយសារតែក្នុងឱកាសនៃការបំពេញមុខងារនេះ ឬក៏ក្នុងក្របខណ្ឌនៃមុខងាររបស់គាត់នេះ គាត់បានទៅសម្លាប់ជនណាម្នាក់ដោយមិនមែនចូលទៅក្នុងស្ថានភាពនៃការកាពារស្របច្បាប់នោះទេ។[21] ប៉ុន្តែដោយសារតែគាតខឹងសម្បារនឹងជនល្មើសខ្លាំងពេក ដូចជាមន្ត្រីនគរបាលយុត្តិធម៌ទៅដេញចាប់ជនល្មើសពេលចាប់បានហើយ ជនល្មើសហាក់បីដូចជាតវ៉ាខ្លាំងពេកទៅ មន្ត្រីនគរបាលយុត្តិធម៌នោះក៏ថាយើងខំដេញឯងហត់សឹងស្លាប់ ហេតុអីឯតវ៉ាខ្លាំងម្លេះហ៎ា? បន្ទាប់មកក៏សម្លាប់ជនល្មើសចោលតែម្តងទៅបែបនេះគឺគេហៅថាឃាតកម្មដែលប្រព្រឹត្តិដោយអ្នករាជការសាធារណៈក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន។[22]

- ប្រព្រឹត្តនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន

នៅក្នុងករណីមួយទៀតគឺ ប្រសិនបើជាមន្ត្រីរាជការដែលទៅជួយសហការបំពេញការងាចាប់ជនល្មើស ដោយមិនស្ថិតនៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួននោះទេ តែខ្លួនបែរជាទៅសម្លាប់ជនល្មើសនោះហេតុដូចច្នេះហើយនេះគឺ ជាឃាតកម្មដែលបានប្រព្រឹត្តទៅដោយអ្នករាជការសាធារណៈនៅក្នុង ឱកាសនៃការបំពេញមុខងាររបស់ខ្លួន។ ឃាតកម្មប្រភេទនេះត្រូវទទួលស្ថាន

---

[19] ដូចលេខ១៥

[20] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៤

[21] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៤

[22] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៤

ទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២០៤ គឺត្រូវជាប់គុកចន្លោះពី ១៥ (ដប់ប្រាំ) ឆ្នាំ ៣០ (សាមសិប) ឆ្នាំ[23]។

### ២.៦. បទល្មើសឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើ រំលោភសេពសន្ថវ:

បទល្មើសឃាតកម្មដែលកើតក្នុងពេល ឬក្រោយពេលប្រព្រឹត្តិអំពើទារុណកម្មដែលមានអំពើឃោឃៅ ឬអំពើរំលោភសេពសន្ថវៈ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[24]។

- ករណីឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោឃៅ

"ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោឃៅ គឺមានន័យថានៅពេលដែលធ្វើទារុណកម្មទៅលើជនរងគ្រោះគឺសម្លាប់ជនរងគ្រោះតែម្តង ឬមួយក្រោយពេលដែលធ្វើទារុណកម្មលើជនរងគ្រោះរួចហើយក៏សម្លាប់ជនរងគ្រោះចោលតែម្តងទៅ។ ទាំងនេះគឺជាឃាតកម្មនៅក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តិអំពើទារុណកម្ម អំពើឃោឃៅ ។ រាល់ករណីដែលកើតឡើងបែបនេះជនល្មើសត្រូវតែទទួលនៅស្ថានទម្ងន់ទោសតាមបទបញ្ញាត្តិនៃមាត្រា ២០៥ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាគឺ ត្រូវដាក់គុកអស់មួយជីវិត។

- ឃាតកម្មដោយមានអំពើរំលោភសេពសន្ថវៈ

អំពើឃាតកម្មដោយមានអំពើរំលោភសេពសន្ថវៈ គឺនៅពេលរំលោភសេពសន្ថវៈរួចទៅហើយក៏សម្លាប់ជនរងគ្រោះតែម្តង ឬមួយក៏ក្រោយពេលដែលរំលោភរួចហើយ ក៏សម្លាប់ជនរងគ្រោះចោលតែម្តងទៅ ទាំងនេះសុទ្ធតែគឺជាឃាតកម្មនៅក្នុងពេលប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈ ឬក្រោយពេលប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈ[25] ។ ករណីនេះក៏ត្រូវទទួលស្ថានទម្ងន់ទោសតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ ដែរគឺត្រូវដាក់គុកអស់មួយជីវិតដូចគ្នា។

យើងគួរតែកត់សម្គាល់ត្រង់ចំណុចខ្លះៗ៖ ប្រហែលជាមានពេលខ្លះភ្លេចគិតមើលមាត្រា ២០៥។ នៅពេលដែលមានអំពើរំលោភហើយសម្លាប់ ប្រហែលជាយើងខំទៅបើកមើលក្រម ដែលនៅក្នុងមាត្រា ២៣៩ (បទរំលោភសេពសន្ថវៈ) ដល់មាត្រា ២៤៥ (ទោសបន្ថែម ប្រភេទ និងរយៈពេលនៃបទរំលោភសេពសន្ថវៈ) ហើយមើលទៅ ! ដោយគិតថាជារឿងនេះគឺជាបទល្មើសរំលោភ ហើយសម្លាប់ទៀត ដូចច្នេះហើយប្រសិនជាយើងមិនបានក្រឡេកមើលមាត្រា ២០៥ (បទឃាតកម្មដោយមាន

[23] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៤

[24] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៥

[25] កៅ សីហា, "ក្រមព្រហ្មទណ្ឌពិសេស"

អំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ)ទេ នោះយើងនឹងទៅចោទពីរមាត្រាខុសគ្នាស្រឡះតែម្តង ពីព្រោះទោសដែលបានចោទប្រកាន់ខុសគ្នាឆ្ងាយណាស់(ទោសដាក់ពន្ធនាគារ)។ ប្រសិនជាចោទពី បទឃាតកម្មមួយ និងចោទពីរបទរំលោភសេពសន្ថវៈមួយទៀតនៅក្នុងអំពើនេះដែរគឺដាក់ពន្ធនាគារ យ៉ាងច្រើនបំផុតបានត្រឹមតែ ១៥ (ដប់ប្រាំ) ឆ្នាំ នោះទេ លើកលែងតែយើងរកភស្តុតាងបញ្ជាក់ថា បទល្មើសនេះជាបទឃាតកម្មគិតទុកជាមុន។ ប៉ុន្តែអំពើរំលោភសេពសន្ថវៈនេះយើងគួរគប្បីចងចាំ ថាមាត្រា ២០៥ (បទឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ) បានតែងច្បាស់ហើយថាទោះបីជាគ្មានការគិតទុកជាមុនក៏ដោយ ឱ្យតែរំលោភហើយសម្លាប់ ឬក៏ ក្នុងពេលរំលោភហ្នឹងដោយសាតែជនរងគ្រោះប្រតាយប្រតប់ជាមួយជនល្មើសខ្លាំងពេក ជនល្មើស ក៏ច្របាច់កជនរងគ្រោះឱ្យស្លាប់តែម្តងហើយក៏បាត់បង់ជីវិតទៅ ។ ទង្វើបែបនេះគឺជាឃាតកម្មក្នុង ពេលរំលោភសេពសន្ថវៈ ឬឃាតកម្មនៅក្រោយពេលដែលរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតាមបញ្ញត្តិមាត្រា ២០៥[26]។

ដូច្នេះហើយសូមកុំយល់ច្រឡំទៅចោទចំនួនពីរបទល្មើសពីផ្សេងគ្នា រឺក៏បូកបទល្មើសពីរចូលគ្នានោះទេ ដែលរួមមាន សម្លាប់ផង និងរំលោភផង ពីព្រោះបទឃាតកម្មតាមបញ្ញត្តិមាត្រា ១៩៩ បើអត់មានស្ថានទម្ងន់ទោសទេ គឺជាប់គុកបានតែចន្លោះពី ១០ (ដប់) ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំប៉ុណ្ណោះ និងរំលោភសេពសន្ថវៈតាមបញ្ញត្តិមាត្រា ២៣៩ បើមិនមានស្ថានទម្ងន់ទោសទេគឺអាចដាក់ពន្ធនាគារ(គុក) បានតែចន្លោះពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំទេ។ ហេតុនេះបទល្មើសចំនួនពីរនៅក្នុងអំពើដែលយើងបានចោទនេះ តុលាការមិនអាចប្រកាសទោសលើសពី ១៥ (ដប់ប្រាំ)ឆ្នាំនោះទេ ពីព្រោះមាត្រា ២៣៩ គឺអតិបរមានៃទោសរបស់វាស្មើនិង ១០ ឆ្នាំ និងមួយទៀតត្រង់មាត្រា ១៩៩ គឺអតិបរិមានៃទោសរបស់វាស្មើនិង១៥ឆ្នាំ។បើមានករណីដូច្នេះមែនតុលាការអត់មែនទៅផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ ដែលមានស្ថានទម្ងន់ទោស ១០ឆ្នាំ និង បទឃាតកម្ម ១៥ ឆ្នាំ បើយើងបូកចូលគ្នា ២៥ ឆ្នាំ នោះគឺខុសទៅហើយ ដែលយោងទៅតាមគោលការណ៍ក្នុងបញ្ញត្តិមាត្រា ១៣៧ "ការចោទប្រកាន់តែមួយ" នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

ហេតុដូច្នេះគឺមិនអាចទៅយកបទល្មើសដែលយើងចោទចំពោះជននោះច្រើន បែរជាយើងទៅផ្តន្ទាទោសម្តងមួយៗ រួចសរុបចេញចំនួនទោសទាំងអស់ដូចនៅប្រទេសអាមេរិចនោះទេ។

---

[26] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៦

**កថាខណ្ឌទី៤ ទោសបន្ថែមនៃបទឃាតកម្មៈ ប្រភេទ និង រយៈពេល**

ក្រៅពីមូលទោសដែលមានកំណត់នៅក្នុងបញ្ញត្តិនីមួយៗ ទៅតាមស្ថានទម្ងន់របស់វាគឺថា សម្រាប់បទឃាតម្មនេះក៏មាន "ទោសបន្ថែម" ដូចមានចែងនៅក្នុងមាត្រា ២០៦ គឺៈ

មាត្រា ២០៦ "ទោសបន្ថែម"ៈ ប្រភេទ និង រយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាសៈ

1. ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
2. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈកាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំយ៉ាងច្រើន។
3. ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន។
4. ការហាមឃាតដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថានពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
5. ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀតដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើសឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។
6. ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់បែកគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
7. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២(ពីរ) ខែយ៉ាងច្រើន។
8. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។
9. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យាបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងច្រើន។

ចំពោះគោលការណ៍នៃទោសបន្ថែមនេះ គឺទាល់តែមានការបែងចែកជាក់លាក់នៅក្នុងច្បាប់ ដូចជាករណីដែលមានចែងនៅក្នុងមាត្រា ២០៦ដែរ។ ផ្ទុយទៅវិញប្រសិនបើគ្មានការបែងចែកជាក់លាក់នៅក្នុងច្បាប់បែបនោះទេ តុលាការនឹងមិនអាចនឹកឃើញថាច្បាប់មានការចែងទោសបន្ថែមដើម្បីបន្ថែមទៅលើមូលទោស (ទោសដាក់ពន្ធនាគារ និង ទោសពិន័យ)បាននោះទេ។ ពីព្រោះថាក្រៅពីប្រកាសមូលទោស តុលាការប្រសិនជាពិនិត្យឃើញថាច្បាប់មានចែងអំពីទោសបន្ថែម តុលាការអាចប្រកាសទោសបន្ថែម ដើម្បីបន្ថែមទៅលើមូលទោសក៏បាន ឬមួយមិនប្រកាសក៏បាន ដែរលើកលែងតែច្បាប់បានចែងកំណត់ជាកាតព្វកិច្ចឱ្យមានការប្រកាសជាដាច់ខាតជាគំរូ គឺគេប្រើភាគច្រើនចំពោះនីតិបុគ្គល។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងមាត្រា ២០៦ នេះគេប្រើពាក្យ ថា "អាចត្រូវបាន

ប្រកាស "ទេតើគឺមិនមានន័យថា" ត្រូវតែប្រកាស" នោះឡើយ។ ដូច្នេះតុលាការ អាចប្រកាសបន្ថែមទៅលើមូលទោសនេះទៀតក៏បានដែរ។ គួរយ៉ាងក្នុងចំណុចនេះដែរយើងគួរគប្បីស្វ័យសិក្សាឱ្យបានល្អិតល្អន់ចាប់ពីមាត្រា ៥៣ ដល់មាត្រា ៧១ ព្រមទាំងមាត្រា ៩៩ និងមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាជាដើម។

យើងសូមបញ្ចប់ការបកស្រាយជំពូកទី១ នៅត្រង់ចំណុចនេះ នឹងសូមបន្តទៅការបកស្រាយជំពូកទី២ "រាជឃាតកម្ម" បន្ថែមទៀតដែលមានដូចតទៅៈ

# ជំពូកទី២

# បទរាជឃាតកម្ម

# ជំពូកទី២

# បទរាជឃាតកម្ម

## កថាខណ្ឌទី១ និយមន័យនៃបទរាជឃាតកម្ម

បទរាជឃាតកម្មគឺជាបទឃាតកម្មមួយចំពោះព្រះមហាក្សត្រ (សម្លាប់ស្ដេច)។ ដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់អំពីនិយមន័យ នៃបទល្មើសខាងលើយើងគួតប្បីយល់អំពីពាក្យគន្លឹះ ជាមុនសិនដែលក្នុងនោះមានពាក្យថា "ឃាតកម្ម" ឃាតកម្មគឺជាអំពើសម្លាប់មនុស្សដោយចេតនា ឬ អចេតនា ដោយប្រើអាវុធ ឬមិនបានប្រើអាវុធក្ដី (និយមន័យនៃពាក្យអាវុធនៅក្នុងមាត្រា ៨១ អាវុធនិង វត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ)។ ចំណែកឯពាក្យថា "រាជ" គឺមានន័យថាគឺជាព្រះរាជា (ក្សត្រីយ៍ទ្រង់រាជ)។ ឯពាក្យថា "មហាក្សត្រ" គឺជាក្សត្រធំ, ក្សត្រីយ៍ដ៏ប្រសើរថ្លៃថ្លា។ រីឯពាក្យថា "អង្គ" មានន័យថាគឺជារូបកាយ ខ្លួនប្រាណ តួខ្លួន តួរូបប្រាណ តួខ្លួនប្រាណ។[27] និងពាក្យថា "ព្រះមហាក្សត្រ" គឺជាក្សត្រធំ ប្រសើរ ខ្ពង់ខ្ពស់ ជាចម្បងគេបង្អស់ក្នុងប្រទេសមួយៗ។

សរុបសេចក្ដីមក បទរាជឃាតកម្ម គឺជាអំពើសម្លាប់មនុស្សដែលបុគ្គលម្នាក់នោះគឺជាស្ដេចផែនដី ឬក៏ជាព្រះរាជា ឬក្សត្រធំជាងគេបង្អស់ និងមានតែមួយនៅក្នុងប្រទេសកម្ពុជា ដោយចេតនា ឬអចេតនាក្ដី បើទោះជាមានការប្រើអាវុធក្ដី មិនប្រើអាវុធក្ដី ទៅលើរូបរាងកាយរបស់ទ្រង់ ដែរជាព្រះមហាក្សត្រ ហើយអំពើនោះអាចបណ្ដាលឱ្យទ្រង់ចូលទិវង្គត។
នាពេលបច្ចុប្បន្ននេះយើងបានស្គាល់យ៉ាងច្បាស់ថាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាគឺជាព្រះកុរណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហាមុនី។[28]

## កថាខណ្ឌទី២ ធាតុផ្សំនៃបទរាជឃាតកម្ម

ដូចដែលយើងបានដឹងហើយជាស្រាប់ថាធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌមាន៣ធំៗគឺ៖

- ធាតុផ្សំនីត្យានុកូល (ធាតុច្បាប់)
- ធាតុសត្យានុម័ត (ធាតុសម្ភារ:)
- ធាតុអត្តនោម័តិ (ធាតុចិត្តសាស្ត្រ)

យើងសូមធ្វើការបកស្រាយរាល់ចំណុចខាងលើនេះឱ្យបានជាក់លាក់បន្តិចនៅខាងក្រោមនេះ៖

---

27 សម្ដេចព្រះសង្ឃរាជ ជួនណាត

28 យោងតាមសេចក្ដីសម្រេចស្ដីពីការជ្រើសរើសព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០០៤

**១ ធាតុផ្សំនីត្យានុកូលនៃបទរាជឃាតកម្ម**

ដោយផ្អែកលើមាត្រា៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាច្រកកម្ពុជា ដែលបានចែងអំពីគោលការណ៍នីត្យានុកូលភាព ដែលអាចធ្វើឱ្យយើងបានយល់ថា "មានច្បាប់គឺមានទោសពីព្រោះមានច្បាប់ដែលត្រូវបានចែងរួចជាស្រេច" អាស្រ័យហេតុដូច្នេះទើបនៅក្នុងមាត្រា ៤៣៣ មានចែងយ៉ាងច្បាស់ពី "បទរាជឃាតកម្ម" ដែលមានក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជណាច្រកកម្ពុជា ឆ្នាំ២០០៩ នៅត្រង់គន្ថីទី៤ បទល្មើសប្រឆាំងនឹងជាតិ, ក្នុងមាតិកាទី១ ការប៉ះពាល់ដល់ស្ថាប័នចម្បងរបស់រដ្ឋ, ជំពូកទី១ ការរំលោភបំពានដល់អង្គព្រះមហាក្សត្រ ការបង្កើតឱ្យមានច្បាប់នេះមកដើម្បីកុំឱ្យមានភាពចន្លោះនៃច្បាប់ និងកុំឱ្យមានការបំពានដល់អង្គព្រះមហាក្សត្រពីជនដែលទទួលបានផលប្រយោជន៍ បន្ថែមពីនេះទៀតគឺភាពងាយស្រួលសម្រាប់ចៅក្រមយកទៅសម្អាងជាហេតុផ្អែកអង្គច្បាប់ "ធាតុនីត្យានុកូល" ងាយស្រួលនឹងដាក់ទោសជនល្មើសនឹងផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់។

**២ ធាតុផ្សំសត្យានុម័តនៃបទរាជឃាតកម្ម**

ធាតុផ្សំសត្យានុម័តនៅក្នុងករណីនេះយើងអាចបែងចែកចេញជារូបរាងនៃអំពើ និងជនរងគ្រោះ យើងនឹងធ្វើការបកស្រាយរាល់ចំណុចលម្អិតខាងក្រោមនេះ៖

**២.១ អំពើដែលអាចធ្វើឱ្យបាត់នូវអត្ថិភាពនៃជីវិតរបស់អង្គព្រះមហាក្សត្រ**

ធាតុផ្សំសត្យានុម័តនៃបទល្មើសរាជឃាតកម្មនេះជាអំពើសកម្ម ដែលអាចប្រល័យ ឬផ្តាច់ ឬប្រហារ ឬក៏ធ្វើឱ្យក្ស័យដល់ជីវិតរបស់អង្គព្រះមហាក្សត្រ ឬមួយធ្វើឱ្យបាត់នូវ អត្ថិភាព (ការកើតមាន) នៃជីវិតរបស់ព្រះករុណាជីវិតតម្កល់លើត្បូង ដែលជាម្លប់ដ៏ត្រជាក់នៃប្រជារាស្ត្រក្នុងប្រទេសខ្មែរ។

អំពើដែលយើងបានរៀបរាប់ខាងលើនេះអាចជាការបាញ់សម្លាប់ ការកាប់សម្លាប់ ការឆក់ឱ្យស្លាប់ ការដាក់ថ្នាំពុលដើម្បីបំពុលឱ្យពុលស្លាប់ ឬការបាញ់ថ្នាំពុលឱ្យ ស្លាប់ ឬក៏ការប្រើប្រាស់សត្វដើម្បីជាឧបករណ៍សម្លាប់អង្គព្រះមហាក្សត្រ។ល។

អំពើដូច្នេះគឺ សុទ្ធតែជាអំពើដែលផ្ទុកនូវលទ្ធភាពនៃការដកហូតយកជីវិតមនុស្ស ហើយជាជីវិតរបស់អង្គព្រះហាក្សត្រផងដែរដោយផ្ទុយពីច្បាប់។ ក៏ប៉ុន្តែបច្ច័យឬការខូចខាតនៃបទល្មើសនេះ មិនអាចទាមទារដាច់ខាតថាត្រូវតែព្រះមហាក្សត្រសុគតបាត់បង់ជីវិតនោះទេតែផ្ទុយទៅវិញ បើបទល្មើសមិនបានសម្រេចដោយហេតុអង្គព្រះមហាក្សត្រមិនបានយាងចូលទិវង្គតនោះទេ គឺក្លាយទៅជាបទល្មើសប៉ុនប៉ងដែលត្រូវផ្តន្ទាសទោសដាក់ពន្ធនាគារដែលមានចែកក្នុងមាត្រា២៧ នៃក្រមព្រហ្មទណ្ឌ។

## ២.២ លក្ខណៈសម្បត្តិរបស់ជនរងគ្រោះ

ដោយផ្អែកតាមប្រធានបទ និងមាត្រាដែលយើងត្រូវបានបកស្រាយខាងលើនេះ យើងមានសំនួរសួរថាតើជនរងគ្រោះប្រភេទណាដែលត្រូវបានច្បាប់ត្រង់មាត្រានេះការពារះ

– ទ្រង់គឺជាអង្គព្រះមហាក្សត្រដែលត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិ ក្នុងករណីនោះយើងនឹងធ្វើការបកស្រាយត្រង់ចំណុចនេះ ជនរងគ្រោះគឺជាព្រះអង្គគឺជាស្តេចផែនដីដែលកំពុងតែគ្រងរាជសម្បត្តិ ហើយត្រូវបានបោះឆ្នោតជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិដែលស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ នៅត្រង់មាត្រា១៣ ថ្មី និងព្រះរាជក្រម នស/រកម/១០០៤/០០៣ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិនៃក្រុមប្រឹក្សារាជ្យ សម្បត្តិ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០៤ ព្រមទាំងធ្វើសម្បថដូចដែលបានចែងក្នុងឧបសម្ព័ន្ធទី៤ ផងដែរ។

– ជនរងគ្រោះមិនមែនជាសម្តេចដែលតែជាខ្សែរាជវង្សានុវង្សអត់សោយរាជសម្បត្តិ ទោះបីជាខ្សែរាជវង្សានុវង្សខ្មែរ ដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ អង្គឌួងឬព្រះមហាក្សត្រ អង្គឌួង ឬព្រះមហាក្សត្រ នរោត្តម ឬក៏ព្រះមហាក្សត្រ ស៊ីសុវត្ថិ (មាត្រា ១៤ នៃរដ្ឋធម្មនុញ្ញ ១៩៩៣) ក៏ដោយឱ្យតែគាត់មិនបានជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិ និងមិនបានជ្រើសតាំងជាព្រះមហាក្សត្រដើម្បីគ្រងរាជសម្បត្តិនោះទេ ក៏មិនអាចចាត់ចូលជាបទល្មើសរាជឃាតកម្មនេះបាន ទេតែយើងត្រូវក្រឡេកមើលក្នុងមាត្រ ១៩៩ បទឃាតកម្ម ធម្មតាវិញ។

ឧទាហរណ៍ះ សម្តេចក្រុងព្រះនរោត្តមរាណារិទ្ធ, សម្តេចស៊ីសុវត្ថិធម្មិកោ, សម្តេចចក្រពង្ស............. ករណីពួកគាត់មិនអាចចាត់ចូលក្នុង មាត្រា៤៣៣ (បទរាជឃាតកម្ម) បានទេត្រូវចាត់ចូលទៅមាត្រ ១៩៩ (បទឃាតកម្ម) ធម្មតាវិញ។

– ជនរងគ្រោះមិនមែនជារាស្ត្រសុទ្ធសាធឬ មិនមែនជាសង្ឃដែលមានងារជាសម្តេចនោះទេ ជនរងគ្រោះដែលជារាស្ត្រសុទ្ធសាធ ឬព្រះសង្ឃដែលមានងារជាសម្តេចនៅក្នុងប្រទេសកម្ពុជានេះក៏មាត្រានេះក៏មិនមានវិសាលភាពលើបុគ្គលនេះដែរ បើមានករណីសម្លាប់អ្នកទាំងនោះគឺជាបទឃាតកម្មធម្មតា ដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មិនមែន មាត្រា ៤៣៣ បទរាជឃាតកម្មនោះទេ។ [29]

បុគ្គលទាំងនោះ យើងមើលឃើញថានៅក្នុងប្រទេសកម្ពុជាយើងរួមមាន ៖ រាស្ត្រសុទ្ធសាធដែលមានដូចជា សម្តេចអគ្គធម្មពោធិសាល, សម្តេចអគ្គមហាសេនាបតីតេជោ, សម្តេចអគ្គមហា

---

[29] កៅ សីហា, ២០០៧. *នីតិព្រហ្មទណ្ឌពិសេស*. ភ្នំពេញ. ៦៦

ពញាចក្រី, សម្តេចអគ្គធម្មពោធិសាល, សម្តេចជវារាំង, សម្តេចបរសេដ្ឋា។ល។ រីឯ ព្រះសង្ឃ មាន ដូចជា សម្តេចព្រះមហាសង្ឃរាជ, សម្តេចព្រះមហាសុមេធាធិបតី។ ល ។[30]

**៣ ធាតុផ្សំអន្តនោម័តនៃបទរាជឃាតកម្ម**

ជនលើសមានចេតនា និងមានបំណងធ្វើគុតចំពោះអង្គព្រះមហាក្សត្រដែលកំពុងតែគ្រងរាជសម្បត្តិ នោះឱ្យយាងចូលទិវង្គត លាចាកពីលើលោកនេះទៅ។

ចំណាំ៖ ជននេះគឺជាមនុស្សមានស្មារតីល្អ!

**កថាខណ្ឌទី៣ ទោសដែលត្រូវអនុវត្តចំពោះបទរាជឃាតកម្ម**

ទោសដែលយកមកអនុវត្តនៅក្នុងនៅក្នុងបទរាជឃាតកម្ម ចាប់ពីមាត្រា ១៩៩ ទៅមុខនេះ រួមមានដូចខាងក្រោម៖ មូលទោស និង ទោសបន្ថែម យើងនិងធ្វើការមកស្រាយរាល់ចំណុចលម្អិតឱ្យបានក្បោះក្បាយដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា៖

**១ មូលទោស**

មូលទោសត្រូវបានបែងចែកជា២គឺ ទោសដែលត្រូវដាក់ពន្ធនាគារ និង ជាទោសដែលត្រូវផាកពិន័យជាសាច់ប្រាក់ ហើយយើងនឹងធ្វើការបែងចែកចំពោះ៖ ករណីចូលក្នុងបទរាជឃាតកម្ម នៅក្នុងមាត្រា ៤៣៣, ករណីចូលក្នុងបទធ្វើទារុណកម្ម ឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រ ចែងក្នុងមាត្រា ៤៣៤ និងករណីចូលក្នុងបទហិង្សាចំពោះអង្គព្រះមហាក្សត្រ ដែលមានចែងក្នុងមាត្រា ៤៣៥ យ៉ាងណាមិញយើងមិនបានធ្វើការបកស្រាយស្រាយឱ្យលម្អិតនូវរាល់ បទល្មើសក្នុងករណីនីមួយៗ យើងបានត្រឹមតែមានការបកស្រាយនូវមូលទោសដែលពាក់ព័ន្ធតែ ប៉ុន្នោះ

ព្រោះតែចំនុះចខ្លះមិនមានការពាក់ព័ន្ធជាមួយប្រធានបទឃាតកម្ម (រាជឃាតកម្ម)។ ដូច្នេះយើងមកបកស្រាយតាមករណីខាងក្រោម៖

**១.១ ករណីចូលក្នុងបទរាជឃាតកម្ម**

មូលទោសក្នុងករណីចូលក្នុងបទរាជឃាតកម្មនេះដែរ ច្បាប់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬអាចហៅបានថាជាប់គុកអស់មួយជីវិត។

**១.២ ករណីចូលក្នុងបទធ្វើទារុណកម្ម ឬអំពើឃោរឃៅចំពោះព្រះមហាក្សត្រ**

មូលទោសដែលបានកំណត់ក្នុងករណីចូលក្នុងបទធ្វើទារុណកម្ម ឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រ ច្បាប់ត្រូវបានកំណត់ថាជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគាពី១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ។

---

[30] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៣៣

## ១.៣ ករណីចូលក្នុងបទហិង្សាចំពោះអង្គព្រះមហាក្សត្រ

មូលទោសដែលបានកំណត់នូវក្នុងករណីដែលចូលក្នុងបទហិង្សាចំពោះអង្គព្រះមហាក្សត្រ អំពើហិង្សានេះដែលគឺជនល្មើសប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ ឆ្នាំ (ដប់ប្រាំ) ឆ្នាំ។

ជាមួយគ្នានេះផងដែរ បើមានការប្រើហិង្សា ដោយការកាត់អវៈយវៈ ឬបណ្តាលឱ្យមានពិការភាពកើតឡើងចំពោះអង្គព្រះមហាក្សត្រ និងមានការចូលទិវង្គត ករណីនេះនឹងមានស្ថានទម្ងន់ទោសដូចបានកំណត់ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយយើងនឹងធ្វើការបកស្រាយអំពីស្ថានទម្ងន់ទោសដូចខាងក្រោម៖

- ស្ថានទម្ងន់ទោសដោយសាការកាត់អវៈយវៈ ឬពិការភាព

អំពើហិង្សាប្រព្រឹត្តិដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំកាលបើអំពើទាំងអស់នោះនាំឱ្យមានការកាត់អវៈយវៈ ឬពិការភាពជា អចិន្ត្រៃយ៍ដល់អង្គព្រះមហាក្សត្រ[31]។

ទាក់ទងជាមួយនឹងការកាត់អវៈយវៈនេះ ខ្ញុំសូមបញ្ជាក់បន្តិចត្រង់ពាក្យថា "អវៈយវៈ" នេះគឺនៅក្នុងក្រមព្រហ្មទណ្ឌ មិនមែនមានតែមាត្រា ៤៣៦ មួយនេះទេ។ នៅត្រង់កន្លែងបទល្មើសពាក់ព័ន្ធជាមួយនឹងអំពើហិង្សា, អំពើដែលពាក់ព័ន្ធជាមួយអំពើទារុណកម្ម និង អំពើឃោរឃៅក៏មានការប្រើប្រាស់ពាក្យ "អវៈយវៈ" ដែរ។

"អវៈយវៈ" បើតាមន័យក្នុងវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត គឺបានប្រើនៅក្នុងន័យទូលាយ ឬន័យទូទៅដែលប្រើច្រើនបំផុតនោះគឺសំដៅទៅលើសរីរាង្គកាយយើងទាំងមូល ដូចជា ស្បែក ត្រចៀក ច្រមុះ ភ្នែក មាត់ និងកន្លែងណាក៏ដោយក៏ជាអវៈយវៈដែរ។ ហើយអវៈយវៈ នេះអាចបែងចែកបន្តទៅទៀតមាន អវៈយវៈចម្បងឬសំខាន់រួមមានដូចជា ស្បែក ត្រចៀក ច្រមុះ ភ្នែក។ ក្នុងការប្រើហិង្សា មានការចាប់ធ្វើទារុណកម្មហើយក៏យកកាំបិតមកអារស្បែកម្តងបន្តិចឬ អង្គន់យកស្បែកម្តងបន្តិចៗ ក៏ប៉ុន្តែឥតមានដាច់ដៃនោះទេ តើចាត់ទុកជាការកាត់អវៈយវៈដែរឬទេ?

ករណីនេះយើងសូមលើកការឧទាហរណ៍មកបញ្ជាក់ឱ្យបានកាន់តែច្បាស់៖

ឧទាហរណ៍៖ ការកាត់ដៃ កាត់ជើង កាត់ត្រចៀក កាត់ច្រមុះ កាត់អណ្តាត របស់អង្គព្រះមហាក្សត្រ។

- ស្ថានទម្ងន់ទោសដោយសារការចូលទិវង្គត

[31] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៣៦

អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការចូលទិវង្គត ដោយគ្មានចេតនា នឹងធ្វើ ឱ្យមានការចូលទិវង្គតទេ[32]។ យើងសូមលើកយកឧទាហរណ៍មកបញ្ជាក់ឱ្យបានកាន់តែច្បាស់៖ ឧទាហរណ៍៖ ជនល្មើសបានវាយធ្វើបាបអង្គព្រះមហាក្សត្រខ្លាំងពេក រហូតដល់ទ្រង់ក៏ទ្រាំនឹងការឈឺ ចាប់លែងបានទៀត ក៏ទាញថ្នាំពុលមកលេប ឬធ្វើឃាតខ្លួនឯងគ្រប់វិធី ឱ្យសុគតបាត់ទៅតែជននោះមិនចង់ឱ្យព្រះអង្គលាចាលោកនោះទេ គឺព្រះអង្គសម្លាប់ខ្លួនឯងប៉ុណ្ណោះ។

**២ ទោសបន្ថែម ៖ ប្រភេទទោស និង រយៈពេល**

អនុលោមតាមមាត្រា ៤៣៨ ទោសបន្ថែមមាន ១០ ចំណុចដែលអាចប្រកាសមួយ ឬច្រើន ក្នុង ចំណោមទាំង ១០ ចំណុចនេះ គឺអាស្រ័យទៅលើឆន្ទានុសិទ្ធរបស់ចៅក្រម។

យើងសូមបញ្ចប់ការបកស្រាយជំពូកទី២ នៅត្រង់ចំណុចនេះនឹងសូមបន្តទៅការបកស្រាយជំពូកទី៣ ″ការប្រៀបធៀបបទល្មើសទាំង២″ ក្នុងនោះដែរយើងក៏បានរៀបរាប់ក្នុងជំពូកទី១ និងជំពូកទី២៖រួចមកហើយដូច្នេះយើងចូលមកមើលការបកស្រាយដូចតទៅ៖..........

[32] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៣៧

# ជំពូកទី៣

# ការប្រៀបធៀបបទល្មើសទាំង២

# បទឃាតកម្ម និង បទរាជឃាតកម្ម

# ជំពូកទី៣

# ការប្រៀបធៀបបទល្មើសទាំង២ (បទឃាតកម្ម និង រាជឃាតកម្ម)

បន្ទាប់ពីយើងបានធ្វើការបកស្រាយអំពី បទល្មើសទាំងពីរខាងលើដែលបានបកស្រាយយ៉ាង លម្អិតដែលនៅក្នុងជំពូកទី១ គឺ បទឃាតកម្ម និងជំពូកទី២ គឺ បទរាជឃាតកម្ម រួចមកហើយយើងអាចសិក្សាទៅលើប្រភេទនៃបទល្មើសទាំងពីរនេះដោយអាចទាញយកនូវចំណុចជាច្រើន ដើម្បីយកមកធ្វើ ការប្រៀបធៀបជាមួយគ្នា។ បើធ្វើការពិនិត្យចំពោះការប្រៀបធៀបទៅលើបទល្មើសទាំងពីរខាងលើនេះ ត្រូវបានយកមកធ្វើការបកស្រាយនៅក្នុងជំពូកទី៣នេះ ដោយធ្វើការបែងចែងជាពីរចំណុចធំៗ គឺទី១ យើងនឹងធ្វើការបកស្រាយទៅលើចំណុចដូចគ្នានៃបទល្មើសទាំងពីរ និង ទី២គឺបកស្រាយត្រង់ទៅលើ ចំណុចខុសគ្នានៃបទល្មើសទាំងពីរនេះ។

## កថាខណ្ឌទី១ ចំណុចដូចគ្នា

ការបកស្រាយទៅលើចំណុចដូចគ្នានៃបទល្មើសទាំងពីរ អាចធ្វើឡើងទៅបានដោយឆ្លងកាត់ ការសិក្សា នឹង ការវិភាគ បន្ថែមពីនេះគឺការពិនិត្យយ៉ាងស៊ីជម្រៅទៅលើការបកស្រាយដែលលើក ឡើងអំពីបទល្មើសមួយៗ នៅក្នុងជំពូកទាំងពីរខាងលើនេះតែម្តង។ បន្ទាប់ពីបានធ្វើការសិក្សាយ៉ាង យកចិត្តទុកដាក់ទៅលើការបកស្រាយក្នុងជំពូកទី១ បទឃាតកម្ម និងជំពូកទី២ បទរាជឃាតកម្ម យើងអាចលើកយកចំណុចមួយចំនួនដែលមានលក្ខណៈដូចគ្នា ដើម្បីយកមកធ្វើការបកស្រាយដោយបែងចែកជាចំណុចធំៗ។ ដូច្នេះហើយយើងធ្វើការបកស្រាយរាល់ចំណុចលម្អិតដូចខាងក្រោមនេះ៖

### ១ ប្រភេទនៃបទល្មើស

នៅត្រង់ចំណុចនេះដែរ យើងធ្វើការបកស្រាយទៅលើប្រភេទនៃបទល្មើសទាំង២ (បទឃាតកម្ម និង បទរាជឃាតកម្ម) ដើម្បីឱ្យដឹងថាបទល្មើសទាំងពីរនេះស្ថិតនៅក្នុងប្រភេទនៃបទល្មើសណាមួយ។ បទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ត្រូវបែងចែងជាបីប្រភេទ គឺរួមមានជា បទលហុ បទមជ្ឈិម និង បទឧក្រិដ្ឋ។ ដើម្បីឱ្យយើងអាចធ្វើការកំណត់ប្រភេទនៃបទល្មើសចំពោះបទល្មើសទាំងពីរ យើងត្រូវធ្វើការពិនិត្យទៅលើនិយមន័យប្រភេទនៃបទល្មើសនីមួយៗដូចខាងក្រោមនេះ៖

បទលហុ សំដៅទៅលើបទល្មើសទាំងឡាយណាដែលបានបំពេញទៅតាមលក្ខខណ្ឌដូចខាងក្រោមនេះ៖

- អតិបរិមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលក្រោម ឬស្មើនឹង ៦ ថ្ងៃ។ ហើយទោសដាក់ពន្ធនាគារ អាចត្រូវបានបន្ថែមនូវទោសពិន័យជាសាច់ប្រាក់ ក៏បានផងដែរ។
- បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ[33]។

បទមជ្ឈិម សំដៅទៅលើបទល្មើសទាំងឡាយណាដែលអតិបរិមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនេះមានរយៈពេលលើសពី ៦ ថ្ងៃ និងក្រោម ឬស្មើនឹង ៥ ឆ្នាំ ហើយអាចត្រូវបានបន្ថែមនូវទោសពិន័យជាប្រាក់បន្ថែមទៀតផង[34]។

បទឧក្រិដ្ឋ សំដៅទៅលើបទល្មើសទាំងឡាយណាដែលមានអតិបរិមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនេះរួមមានៈ

- ជាទោសដាក់ពន្ធនាគារអស់មួយជីវិត
- ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ ឆ្នាំ។

ហើយក្រៅពីទោសដាក់ពន្ធនាគារ ក៏អាចត្រូវបានបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[35]។

បន្ទាប់ពីបានពិនិត្យមើលនិយមន័យនៃប្រភេទទាំង៣ នៃបទល្មើសខាងលើនេះហើយ យើងសង្កេតឃើញថា បទល្មើសឃាតកម្ម និង បទរាជឃាតកម្ម គឺស្ថិតនៅក្នុងបទឧក្រិដ្ឋតែមួយ។ ដូច្នេះហើយទើបយើងអាចសន្និដ្ឋានបាន ពីព្រោះតែអតិបរមានៃទោសដាក់ពន្ធនាគារដែលមានចែង ក្នុងបទល្មើសទាំងពីរ ដែលស្របតាមលក្ខខណ្ឌនៃបទឧក្រិដ្ឋ គឺបទឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ (ករណីនេះចូលក្នុងលក្ខខណ្ឌទី២ នៃមាត្រា ៤៦ ព្រោះអតិបរមានៃទោសដាក់ពន្ធនាគារគឺ ១៥ (ដប់ប្រាំ) ឆ្នាំ) និងបទរាជឃាតកម្ម ត្រូវផ្តន្ទាទោសពន្ធ នាគារអស់មួយជីវិត ( ករណីនេះត្រូវចូលក្នុងលក្ខខណ្ឌទី១ នៃមាត្រា ៤៦ ក្រមព្រហ្មទណ្ឌ)។

## ២ បុគ្គលដែលពាក់ព័ន្ធនៅនឹងបទល្មើស

នៅក្នុងករណីមួយដែលជាបទល្មើស គឺបង្កើតឡើងដោយបុគ្គលទៅលើបុគ្គលផ្សេងទៀតដែលដែលបង្ករការខូចខាតដល់បុគ្គលដែលរងគ្រោះ។ ចំពោះបុគ្គលដែលជាប្រធាននៃបទល្មើសត្រូវបានបែងចែកជាពីរប្រភេទគឺ រូបវន្តបុគ្គល និង នីតិបុគ្គលដោយយោងទៅតាមក្រមព្រហ្ម

[33] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៨

[34] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៧

[35] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៦

ទណ្ឌ ឆ្នាំ ២០០៩ បានធ្វើការកំណត់ឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះនីតិបុគ្គលដែល ជាសញ្ញាណថ្មីមួយដែលមិនមកពុំមានការកំណត់នៅក្នុងច្បាប់ចាស់ឡើយ។

ចំពោះប្រធាននៃបទល្មើស នៅក្នុងបទឃាតកម្ម និង បទរាជឃាតកម្ម គឺមានតែរូបវន្តបុគ្គលតែប៉ុណ្ណោះដែលត្រូវទទួលខុសត្រូវ ពុំមាននីតិបុគ្គលនោះទេ ហេតុដូច្នេះនៅក្នុងចំណុចនេះយើងសូមលើកយកតែរូបវន្តបុគ្គលតែប៉ុណ្ណោះមកធ្វើការបកស្រាយ។ រូបវន្តបុគ្គលដែលជាប្រធាននៃបទល្មើសទាំងពីរនេះ នឹងដោយមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបទល្មើសគឺ ជនល្មើស។

កំណត់ចំណាំ៖ ករណីជនរងគ្រោះគឺយើងនិងបកស្រាយត្រង់ចំណុចទី ២ (ចំណុចខុសគ្នា)។

### ២.១ ជនល្មើស

ជនល្មើស ឬយើងអាចហៅបានម្យ៉ាងទៀតថាជា ចារីគឺសំដៅទៅលើបុគ្គលដែលមានលក្ខណៈដូចខាងក្រោមនេះ៖

- បុគ្គលដែលប្រព្រឹត្តបទល្មើស ដែលត្រូវចោទប្រកាន់ស្របច្បាប់
- បុគ្គលដែលប៉ុនប៉ងប្រព្រឹត្តិបទឧក្រិដ្ឋ
- បុគ្គលដែលប៉ុនប៉ងប្រព្រឹត្តិបទមជ្ឈឹមក្នុងករណីដែលច្បាប់បានចែងទុក[36]។

ជនល្មើស ឬចារី អាចជាបុគ្គលតែម្នាក់ ហើយក៏អាចមានបុគ្គលច្រើននាក់ដែរ។ បុគ្គលច្រើនផ្សេងទៀតបានចូលរួម នោះយើងក៏អាចហៅបានថាជា សហចារី។ ក្រៅពីនេះពេលខ្លះអាចមានទាំងអ្នកផ្តើមគំនិត ឬអ្នកផ្សំគំនិតផងដែរ។

## ៣ អំពើ និង បច្ច័យ

អំពើ និង បច្ច័យ គឺជាចំណុចសំខាន់ដែលយើងត្រូវពិចារណានៅក្នុងបទល្មើសឃាតកម្ម និង រាជឃាតកម្ម ហើយទាំងពីរចំណុចនេះមានលក្ខណៈផ្ទុយគ្នាដូចខាងក្រោម៖

អំពើ ៖ នៅក្នុងបទល្មើសទាំងពីរនេះ អំពើ គឺជាធាតុដ៏សំខាន់បំផុតដែលត្រូវតែមាន ហើយអំពើនោះត្រូវតែជាអំពើសម្លាប់មនុស្ស ឬផ្តាច់ជីវិតមនុស្ស ឬប្រល័យជីវិតមនុស្ស ឬការប្រល័យជីវិតនាមជា(អង្គព្រះមហាក្សត្រ) ដែលមានន័យថាជាអំពើដែលផ្ទុកនូវលទ្ធភាពដកហូតជីវិតមនុស្ស ឬជាអង្គព្រះមហាក្សត្រ។ អំពើសម្លាប់ គឺជាសញ្ញាណដាច់ខាតនៅក្នុងបទល្មើសទាំងពីរនេះ ប្រសិនបើពុំមានអំពើណាមួយដែលផ្ទុកនូវលទ្ធភាពដកហូតជីវិតមនុស្សទេគឺ ពុំមានបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងពីរកើតឡើងនោះទេ។

---

[36] យោងតាមសទ្ទានុក្រមពាក្យច្បាប់ក្រមព្រហ្មទណ្ឌទីស្តីការដ្ឋមន្ត្រី, ២០០១, ៣៨

បច្ច័យ ៖ សំដៅទៅលើផលដែលបានកើតចេញពីបទល្មើស ប៉ុន្តែចំពោះបទល្មើសទាំងពីរនេះមិនទាមទារថាទាល់តែជនរងគ្រោះស្លាប់បាត់បង់ជីវិតនោះទេ។ បច្ច័យ នៅក្នុងបទល្មើសទាំងពីរនេះគឺជាសញ្ញាណមិនដាច់ខាតទេ មានន័យថាការស្លាប់បាត់បង់ជីវិតរបស់ជនរងគ្រោះមិនមែនជាធាតុសំខាន់ក្នុងការកំណត់នូវបទល្មើសោះឡើយ។ សរុបសេចក្តីមក នៅក្នុងបទល្មើសទាំងពីរនេះគឺទាមទារឱ្យមានអំពើ ដែលផ្ទុកនូវលទ្ធភាពដកហូតជីវិតមនុស្ស ឬ ជីវិត(អង្គព្រះមហាក្សត្រ) ដោយផ្ទុយនឹងច្បាប់ជាដាច់ខាត ហើយក៏មិនបានតម្រូវឱ្យមានការស្លាប់បាត់បង់ជីវិតកើតឡើងនោះទេ។

### ៤ អាជ្ញាយុកាល

អាជ្ញាយុកាលមានន័យថា ជារយៈពេលដែលមានសិទ្ធប្តឹង រយៈពេលដែលដើម បណ្តឹងព្រហ្មទណ្ឌមានសិទ្ធិប្តឹងពីជនល្មើស ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី[37]។ អាជ្ញាយុកាលនៃ បណ្តឹងអាជ្ញានៅក្នុងរឿងព្រហ្មទណ្ឌត្រូវបានបែងចែកជាពីរប្រភេទ គឺអាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស។ យើងសូមធ្វើការបកស្រាយចំណុចទាំងពីរនៅខាងក្រោមនេះ៖

#### ៤.១ អាជ្ញាយុកាលនៃបទល្មើស

អាជ្ញាយុកាលនៃបទល្មើស ឬក៏យើងអាចហៅបានម្យ៉ាងទៀតថាអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានន័យថាជារយៈពេលដែលកំណត់អំពីអត្ថិភាព នៃបទល្មើសដែលបានកំណត់អំពីអត្ថិភាព នៃបទល្មើសដែលបានកើតឡើងហើយដោយសារតែរយៈពេលនេះអាចឱ្យអ្នកដែលមានសិទ្ធិប្តឹងអាចធ្វើការប្តឹងទៅលើ អំពីបទល្មើសណាមួយចំពោះបុគ្គលដែលខ្លួនដែលខ្លួនចង់ប្តឹង បន្ទាប់ពីមានបទល្មើសកើតឡើង។ បន្ទាប់ពីមានបទល្មើសមួយកើតឡើងរយៈពេលនៃសិទ្ធិក្នុងការ ដាក់ពាក្យបណ្តឹង ត្រូវគិតចាប់ពីពេលនោះមក ហើយប្រសិនបើអ្នកដែលមានបណ្តឹងអាជ្ញាត្រូវរលត់ សិទ្ធិប្តឹងមិនបានដាក់ពាក្យបណ្តឹងនៅក្នុងរយៈពេលនោះទេ បណ្តឹងអាជ្ញាត្រូវរលត់នៅពេលដែល បណ្តឹងអាជ្ញាត្រូវរលត់សិទ្ធិប្តឹងក៏ត្រូវរលត់ដែរ ហើយការប្តឹងមិនអាចធ្វើទៅបានទៀតឡើយ។ ថិរវេលា នៃអាជ្ញាយុកាលត្រូវបានកំណត់ទៅតាមប្រភេទ ឬចំណាត់ថ្នាក់នៃបទល្មើសដែលមានរយៈពេល ខុសៗគ្នា។ ប្រភេទ ឬចំណាត់ថ្នាក់នៃបទល្មើសមានបីប្រភេទគឺ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ហើយថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ៖

- ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ ឆ្នាំ ចំពោះបទមជ្ឈិម

[37] យោងតាមសទ្ទានុក្រមពាក្យច្បាប់ក្រមព្រហ្មទណ្ឌទីស្តីការរដ្ឋមន្ត្រី, ២០០៦, ២៣៧

– ១ ឆ្នាំ ចំពោះបទលហុ[38]

បើយើងពិនិត្យទៅលើអាជ្ញាយុកាលនៃបទល្មើសខាងលើយើងនឹងសង្កេតឃើញថាបទឃាតកម្ម និងបទរាជឃាតកម្ម មានអាជ្ញាយុកាលដូចគ្នា គឺថិរវេលា ១៥ ឆ្នាំ ពីព្រោះតែបទល្មើសទាំងពីរនេះស្ថិតនៅក្នុងប្រទេស ឬចំណាត់ថ្នាក់នៃបទឧក្រិដ្ឋ។

### ៤.២ អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោស គឺមានន័យថាជារយៈពេលដែលបានកំណត់អំពីអត្ថិភាពនៃទោសដែលអាចយកទៅអនុវត្តបានចំពោះ ទណ្ឌិតដែលត្រូវបានប្រកាសទោសដោយតុលាការ។ នៅពេលដែលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរហើយ ទោះបីជាតាមរូបភាពជាសាលក្រម ឬក៏ជាសាលដីការក៏ដោយ ទោសដែលត្រូវបានសម្រេចប្រកាសដោយតុលាការនោះត្រូវតែយកមកអនុវត្ត។ នៅក្នុងរយៈពេលដែលជាអត្ថិភាពនៃទោស តុលាការអាចចាប់ខ្លួនពិរុទ្ធជនឱ្យមកទទួលទោសបាន ប៉ុន្តែប្រសិនបើមិនបានចាប់ខ្លួន ឬជននោះបានរត់គេចខ្លួនរហូតដល់ផុតរយៈពេលនេះតុលាការមិនអាចចាប់ខ្លួនជននោះមកទទួលទោសបានទៀតឡើយ។ ហើយទោសនោះទុកជាសារសូន្យ ឬអសារបង់។

ថេរវេលានៃអាជ្ញាកាលនៃទោស ក៏មិនខុសពីអាជ្ញាយុកាលនៃបទល្មើសដែរ គឺត្រូវបានកំណត់ទៅតាមចំណាត់ថ្នាក់នៃបទល្មើសនីមួយៗ។ ថិរវេលានៃអាជ្ញាយុកាលនេះត្រូវបានកំណត់ដូចខាងក្រោម៖

– ទោសដែកប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ ឆ្នាំ
– ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ ឆ្នាំ
– ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ ឆ្នាំ[39]។

បើពិនិត្យទៅលើថិរវេលានេះ បទឃាតកម្ម និងបទរាជឃាតកម្ម មានថិរវេលានៃអាជ្ញាយុកាលនេះដូចគ្នាគឺ ២០ ឆ្នាំ ពីព្រោះបទល្មើសទាំងពីនេះសុទ្ធតែជាបទឧក្រិដ្ឋដូចគ្នា។

## ៥ ទោសបន្ថែម និងការប៉ុនប៉ង

ក្រៅពីចំណុចដូចគ្នាជាច្រើនខាងលើក៏នៅមានចំណុចដូចគ្នាចំនួនពីរផ្សេងទៀត គឺចំណុចដែលពាក់ព័ន្ធទៅនឹងទោសបន្ថែម និងការប៉ុនប៉ង។ យើងអាចពិនិត្យទៅលើចំណុចដូចគ្នា

[38] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១០

[39] ព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៥៥

ទាំង ពីរបានតាមរយៈមាត្រាជាក់ស្តែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា ដូច បានរៀបរាប់ដូចខាងក្រោម៖

- ទោសបន្ថែម អាចប្រកាសបានដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២០៦ នៃក្រម ព្រហ្មទណ្ឌ
- ការប៉ុនប៉ង ដោយសារតែបទល្មើសទាំងពីរជាបទល្មើសឧក្រិដ្ឋដូចគ្នា ហេតុនេះ ហើយទើបការប៉ុនប៉ងនៃបទល្មើសទាំងពីរនេះ គឺត្រូវយោងតាមមាត្រា ២៧ នៃក្រម ព្រហ្មទណ្ឌ ហើយការប៉ុនប៉ងនេះពុំមានចែងនៅក្នុងផ្នែកនៃបទល្មើសទាំងពីនេះទេ។

**កថាខណ្ឌទី២ ចំណុចខុសគ្នា**

ស្រដៀងគ្នាទៅនឹងការបកស្រាយ រាល់ចំណុចដូចគ្នានៃបទល្មើសទាំងពីរខាងលើនេះផង ដែរ ការបកស្រាយអំពីចំណុចខុសគ្នានៃប្រភេទទោស អាចធ្វើឡើងតាមរយៈការសិក្សាទៅលើការ បក ស្រាយអំពីបទល្មើសនីមួយៗផងដែរ។ បន្ទាប់ពីបានពិនិត្យដោយយកចិត្តទុកដាក់ទៅលើការ រៀប រាប់នូវបទល្មើសទាំងពីររួចហើយ យើងអាចធ្វើការកត់សម្គាល់នូវចំណុចខុសគ្នាមួយចំនួនរវាង បទល្មើ សទាំងពីរ។ ហើយការបកស្រាយទៅលើចំណុចខុសគ្នានៃបទល្មើស ត្រូវបានបង្ហាញតាមរ យៈការបក ស្រាយទៅលើចំណុចធំៗដូចខាងក្រោម៖

**១ ការបែងចែកក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩**

ការបកស្រាយចំពោះការបែងចែកនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នេះគឺសំដៅ ទៅលើការបកស្រាយដែលធ្វើការប្រៀបធៀបរវាងបទល្មើសទាំងពីរ ផ្តោតសំខាន់ទៅលើការសិក្សា អំពីទីតាំងនៃបទល្មើសនៅក្នុងក្រមនេះ។ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នេះត្រូវបង្កើតឡើង ក្រោមការរៀបចំនូវរចនាសម្ព័ន្ធ ដោយធ្វើការបែងចែកជាបួនចំណុចទៅតាមលំដាប់លំដោយ គឺមាន គន្ថី មាតិការ ជំពូក និង ផ្នែក។

បទឃាតកម្ម និងបទរាជឃាតកម្ម ទីតាំងនៃបទល្មើសទាំងពីរនេះគឺមិនបានស្ថិតនៅ ក្នុងចំណុចទាំង៤ នៃរចនាសម្ព័ន្ធក៏ដោយ ដែលធ្វើការបែងចែកជាបួនផ្សេងគ្នាទៅតាមចំណុចដូចជា គឺ គន្ថី មាតិកា ជំពូក និង ផ្នែក។ ហើយយើងសូមយកនូវចំណុចទាំងបួននេះមកធ្វើការបកស្រាយ ដោយ ភ្ជាប់ទៅនឹងបទល្មើសទាំងពីរ ដោយបែងចែកជាបួនចំណុចផ្សេងគ្នាដូចខាងក្រោម៖

**១.១ ការបែងចែងនៅក្នុងគន្ថី**

នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នេះត្រូវបានបង្កើតឡើងដោយធ្វើកាបែង ចែកជា ០៦ គន្ថី ដោយគិតចាប់ពីគន្ថីទី ០១ បទប្បញ្ញត្តិទូទៅរហូតដល់គន្ថីទី ០៦ អវសានប្បញ្ញត្តិ។ ទោះបីជាមានការកំណត់ដល់ទៅ ០៦ គន្ថី ប៉ុន្តែគន្ថីដែលនិយាយពីបទល្មើសមានតែ ០៣ គន្ថី

ប៉ុណ្ណោះគឺ គន្ថីទី២ បទល្មើសប្រឆាំងនឹងបុគ្គល គន្ថីទី៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និង គន្ថីទី៤ បទល្មើសប្រឆាំងនឹងជាតិ។ ចំពោះបទល្មើសឃាតកម្ម គឺមានចែងនៅក្នុងគន្ថីទី២ បទល្មើសប្រឆាំងនឹងបុគ្គល ចំណែកឯ បទល្មើសរាជឃាតកម្មវិញគឺមានចែងនៅក្នុងគន្ថីទី៤ បទល្មើសប្រឆាំងនឹងជាតិ។

មូលហេតុដែលបទល្មើសទាំងពីរនេះមិនមានចែងនៅក្នុងគន្ថីតែមួយ ព្រោះបទឃាតកម្មត្រូវបានលើកឡើងអំពីបទល្មើសដែលប្រឆាំងនឹងបុគ្គល ហើយបទរាជឃាតកម្មត្រូវបានលើកឡើងអំពីបទល្មើសដែលប្រឆាំងនឹងជាតិ ដោយសារតែបែបនេះហើយទើបបទល្មើសទាំងពីរខុសគ្នាព្រោះបទឃាតកម្ម គឺជាការសម្លាប់មនុស្ស ឬបុគ្គល ចំណែកឯបទរាជឃាតកម្មគឺការសម្លាប់ស្តេចដែលមានការពាក់ពាន់ជាមួយនឹងជាតិ។

### ១.២ ការបែងចែកនៅក្នុងមាតិកា

មាតិកា គឺជាចំណុចមួយដែលស្ថិតនៅក្នុងលំដាប់បន្ទាប់ពីគន្ថី ហើយនៅក្នុងគន្ថីនីមួយៗ អាចមានការកំណត់នូវមាតិកាច្រើន ឬតិចវាអាស្រ័យទៅតាមវិលាលភាពនៃគន្ថីនោះ។ គន្ថីទី ២ នេះមានការបែងចែងជាបីមាតិកា ហើយបទល្មើសឃាតកម្ម ត្រូវបានកំណត់នៅក្នុងមាតិកាទី២ ការប៉ះពាល់ដល់មនុស្ស ចំណែកឯបទរាជឃាតកម្ម នៅក្នុងគន្ថីទី៤ ដែលនៅក្នុងមានការបែងចែកជា ៤មាតិការ ហើយបទរាជឃាតកម្មត្រូវបានកំណត់នៅក្នុងមាតិកាទី១ ការប៉ះពាល់ដល់ចម្បងរបស់ស្ថាប័នរដ្ឋ។

ចំពោះមូលហេតុដែលបទល្មើសទាំងពីរ មិនត្រូវបានបែងចែងនឹងកំណត់នៅក្នុងមាតិកាតែមួយ ពីព្រោះតែបទល្មើសទាំងពីរខុសគ្នាដែលស្រដៀងទៅនឹងការរៀបរាប់ខាងលើនេះដែរ ចំពោះបទល្មើសឃាតកម្ម ជាអំពើសម្លាប់នេះគឺត្រូវធ្វើឡើងទៅលើមនុស្ស មិនអាចធ្វើទៅលើអ្វីផ្សេងដូចជា សត្វ ទ្រព្យ ឬ សត្វបានទេ រីឯ បទរាជឃាតកម្មវិញគឺជាអំពើ សម្លាប់នេះគឺត្រូវតែធ្វើឡើងទៅលើអង្គព្រះមហាក្សត្រតែមួយគត់ មិនអាចធ្វើឡើងទៅលើបុគ្គលធម្មតាបាននោះទេ។

### ១.៣ ការបែងចែកក្នុងជំពូក

ជំពូក គឺជាចំណុចមួយដែលស្ថិតនៅក្នុងលំដាប់បន្ទាប់ពីមាតិកា ហើយនូវក្នុង មាតិកាទី២ ការប៉ះពាល់ដល់មនុស្ស ត្រូវបានបែងចែងជា ៦ ជំពូក ហើយបទល្មើសឃាតកម្មត្រូវបានបែងចែកនៅក្នុងជំពូកទី១ ការប៉ះពាល់ដល់ជីវិតមនុស្ស។ យើងក្រឡេកមើល បទរាជឃាតកម្មវិញម្តង គឺនៅក្នុងមាតិកាទី ១ ការប៉ះពាល់ចម្បងដល់ស្ថាប័នរបស់រដ្ឋ ត្រូវបានបែងចែកជា ៤ ជំពូក បទរាជឃាតកម្មត្រូវបានចែងនៅក្នុងជំពូកទី១ការរំលោភបំពានដល់អង្គព្រះមហាក្សត្រ។

បានជាបទល្មើសទាំងពីរមិនមានការបែងចែកនៅក្នុងជំពូកតែមួយនេះព្រោះ តែបទល្មើសឃាតកម្មវាបណ្តាលឱ្យមានការប៉ះពាល់ដល់ជីវិតមនុស្ស តាមរយៈអំពើសម្លាប់មនុស្ស ឬ ផ្តាច់ជីវិតមនុស្ស ឬ ប្រល័យជីវិតមនុស្ស ដោយឡែក បទរាជឃាតកម្ម គឺវាបណ្តាលឱ្យមានការប៉ះពាល់ ដល់ជីវិតអង្គព្រះមហាក្សត្រ តាមរយៈការសម្លាប់ដែលជាហេតុធ្វើឱ្យមានផលប៉ះពាល់ដល់សង្គមទាំងមូលតែម្តង។

### ១.៤ ការបែងចែកនៅក្នុងផ្នែក

ផ្នែក គឺជាចំណុចចុងក្រោយនៃរចនាសម្ព័ន្ធដែលមាននៅក្នុងក្រមនេះ ហើយនៅក្នុងជំពូកទី ១ (បទឃាតកម្ម) ការប៉ះពាល់ដល់ជីវិតមនុស្សនេះត្រូវបានបែងចែងជា ២ ផ្នែក ហើយបទឃាតកម្មនេះមានបែងចែកជា២ ផ្នែក បទល្មើសឃាតកម្មនៅក្នុងផ្នែកទី១នៃជំពូលទី១នេះរឺង ជំពូកទី១ (បទរាជឃាតកម្ម) ការរំលោភបំពានដល់អង្គព្រះមហាក្សត្រ មានចែងតែមួយផ្នែកក្នុងជំពូកទី១ តែប៉ុណ្ណោះ គឺផ្នែកទី១។

បទល្មើសទាំងពីរមិននៅក្នុងផ្នែកតែមួយវាមិនខុសគ្នាពីចំណុចមុនៗ ខាងលើដែលយើងបាន បកស្រាយនេះទេព្រោះតែវាកើតឡើងពីឆន្ទៈផ្សេងគ្នារបស់ចារី ឬជនល្មើសដែលមានចេតនាក្នុងការ ចង់សម្រេចឱ្យមានបទល្មើសកើតឡើង។ ដោយឡែកការដែលបានលើកឡើងបែបនេះ គឺមានន័យថាអំពើណាមួយអាចចាត់ទុកថាជាបទល្មើស លុះត្រាតែអំពើនោះត្រូវបានអំពើនេះត្រូវបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ហើយកើតចេញពីចេតនាដោយផ្ទាល់របស់ចារីផងដែរ បើមិនកើតឡើង ដោយចេតនានោះទេ វានឹងក្លាយជាបទល្មើសមួយផ្សេងទៀត(បទឃាតកម្ម) ចំពោះបទរាជឃាត កម្មមិនបានសំដៅទៅលើចេតនាឬ អចេតនានោះទេទោសមានចែងតែមួយតែប៉ុណ្ណោះ។

## ២ បុគ្គលដែលពាក់ព័ន្ធនឹងបទល្មើស

នៅត្រង់ចំណុចបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសនេះយើង ក៏បានរៀបរាប់បានខ្លះៗផងដែរនៅត្រង់ចំណុច ១.២ ខាងលើនេះ

### ២.១ ជនរងគ្រោះ

យើងសូមលើកយើងនូវអត្ថន័យនៃជនរងគ្រោះមកបង្ហាញ មុននឹងឈានទៅដល់ការបញ្ជាក់ផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងបទល្មើសឃាតកម្ម និង បទរាជឃាតកម្ម។ សម្រាប់បទឃាតកម្មជនល្មើសជនល្មើសមានន័យថា៖

- តាមន័យក្រមព្រហ្មទណ្ឌ ជនទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌ។

- តាមន័យទូទៅ ជនដែលទទួលបានការឈឺចាប់ដោយអំពើខុសច្បាប់ដែលនាំឱ្យខូចសេចក្តីថ្លៃថ្នូ កិត្តិយស បញ្ញាស្មារតី រូបរាង ឬទ្រព្យសម្បត្តិរបស់ខ្លួន។[40]

ប៉ុន្តែនៅក្នុងការបកស្រាយចំណុចនេះ យើងត្រូវពិនិត្យទៅលើអត្ថន័យតាមក្រមព្រហ្មទណ្ឌ។ នៅក្នុងបទល្មើសទាំងពីរខាងលើនេះ យើងត្រូវធ្វើការពិនិត្យទៅលើលក្ខខណ្ឌមួយចំនួនដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះនេះ ពីព្រោះលក្ខខណ្ឌនេះអាចជួយឱ្យយើងធ្វើការកំណត់នូវអតិភាពនៃបទល្មើសឃាតកម្ម និង បទរាជឃាតកម្ម នេះបានដែលលក្ខខណ្ឌត្រង់ចំណុចខុសគ្នាទាំងនោះមានដូចជា៖ លក្ខខណ្ឌសម្រាប់បទល្មើសទូទៅគឺ៖

- ត្រូវមានអត្ថិភាពនៃជនល្មើសនៃជនរងគ្រោះ គឺត្រូវរកឱ្យថាមានជនរងគ្រោះពិតប្រាកដ។
- ជនរងគ្រោះ គឺជាអ្នកដទៃដែលផ្សេង ឬក្រៅពីជនល្មើស ទោះបីជាសាច់ញ្ញាតិក៏ដោយមានន័យថា ជនរងគ្រោះមិនអាចជាជនល្មើសនោះទេ ពីព្រោះប្រសិនបុគ្គលម្នាក់បានប្រ ព្រឹត្តនូវអំពើសម្លាប់ទៅលើខ្លួនឯង នេះមិនចាត់ទុកថាជាបទល្មើសទាំងពីរនេះទេ។
- ជនរងគ្រោះត្រូវតែមានជីវិតនៅពេលមានបទល្មើសកើតឡើង ប្រសិនបើអំពើសម្លាប់បានធ្វើឡើងទៅលើបុគ្គលដែលគ្មានជីវិត ដែលយើងហៅសាកសពនោះ អំពើស្លាប់នោះមិនមែនជាបទល្មើសទាំងពីរនេះទេ វាបានក្លាយទៅជាបទល្មើសមួយ វាបានក្លាយទៅជាបទល្មើសមួយផ្សេងដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ[41]។

សម្រាប់លក្ខខណ្ឌក្នុងបទល្មើសរាជឃាតកម្មគឺវាប្រហាក់ប្រហែលគ្នានឹង បទឃាតកម្មទូទៅខាងលើដែរប៉ុន្តែខុសនៅត្រង់សមាសភាពរបស់ជនរងគ្រោះតែម្តងយើងនឹងធ្វើការរៀបរាប់ពីជនរងគ្រោះក្នុងបទល្មើសរាជឃាកម្មនៅខាងក្រោមដូចតទៅ៖

- ទ្រង់គឺជាអង្គព្រះមហាក្សត្រដែលត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិ

ក្នុងករណីនោះយើងនឹងធ្វើការបកស្រាយត្រង់ចំណុចនេះ ជនរងគ្រោះគឺជាព្រះអង្គគឺជាស្តេចផែនដីដែលកំពុងតែគ្រងរាជសម្បត្តិ ហើយត្រូវបានបោះឆ្នោតជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិដែលស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ត្រង់មាត្រា១៣ ថ្មី និងព្រះរាជ

[40] យោងតាមសទ្ទានុក្រមពាក្យច្បាប់ក្រមព្រហ្មទណ្ឌទីស្តីការរដ្ឋមន្ត្រី បោះពុម្ពលើកទី ១ ឆ្នាំ ២០០១ , ៨០

[41] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៦១

ក្រម នស/រកម/១០០៤/០០៣ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារាជ្យសម្បត្តិ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០៤ ព្រមទាំងធ្វើសម្បថដូចដែលបានចែងក្នុងឧបសម្ព័ន្ធទី៤ ផងដែរ។

– ជនរងគ្រោះមិនមែនជាសម្តេចដែលតែជាខ្សែរាជវង្សានុវង្សអត់សោយរាជសម្បត្តិ ទោះបីជាខ្សែរាជវង្សានុវង្សខ្មែរ ដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ អង្គឌួងឬព្រះមហាក្សត្រ អង្គឌួង ឬព្រះមហាក្សត្រ នរោត្តម ឬក៏ព្រះមហាក្សត្រ ស៊ីសុវត្ថិ (មាត្រា ១៤ នៃរដ្ឋធម្មនុញ្ញ ១៩៩៣) ក៏ដោយឱ្យតែគាត់មិនបានជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិ និងមិនបានជ្រើសតាំងជាព្រះមហាក្សត្រដើម្បីគ្រងរាជសម្បត្តិនោះទេ ក៏មិនអាចចាត់ចូលជាបទល្មើសរាជឃាតកម្មនេះបាន ទេតែយើងត្រូវក្រឡេកមើលក្នុងមាត្រ ១៩៩ បទឃាតកម្ម ធម្មតាវិញ។

ឧទាហរណ៍៖ សម្តេចក្រុងព្រះនរោត្តមរណឫទ្ធិ, សម្តេចស៊ីសុវត្ថិធម្មិកោ, សម្តេចចក្រពង្ស......... ករណីពួកគាត់មិនអាចចាត់ចូលក្នុង មាត្រា៤៣៣ (បទរាជឃាតកម្ម) បានទេត្រូវចាត់ចូលទៅ មាត្រ ១៩៩ (បទឃាតកម្ម) ធម្មតាវិញ។

– ជនរងគ្រោះមិនមែនជារាស្ត្រសុទ្ធសាធឬ មិនមែនជាសង្ឃដែលមានងាជាសម្តេចនោះទេ ជនរងគ្រោះដែលជារាស្ត្រសុទ្ធសាធ ឬព្រះសង្ឃដែលមានងាជាសម្តេចនៅក្នុងប្រទេសកម្ពុជានេះក៏មាត្រានេះក៏មិនមានវិសាលភាពលើបុគ្គលនេះដែរ បើមានករណីសម្លាប់អ្នកទាំងនោះគឺជាបទឃាតកម្មធម្មតា ដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មិនមែន មាត្រា ៤៣៣ បទរាជឃាតកម្មនោះទេ។

បុគ្គលទាំងនោះ យើងមើលឃើញថានៅក្នុងប្រទេសកម្ពុជាយើងរួមមាន ៖ រាស្ត្រសុទ្ធសាធដែលមានដូចជា សម្តេចអគ្គធម្មពោធិសាល, សម្តេចអគ្គមហាសេនាបតីតេជោ, សម្តេចអគ្គមហាពញ៉ាចក្រី, សម្តេចអគ្គធម្មពោធិសាល, សម្តេចជវាវាំង, សម្តេចបវរសេដ្ឋា។ល។ រីឯ ព្រះសង្ឃ មានដូចជា សម្តេចព្រះមហាសង្ឃរាជ, សម្តេចព្រះមហាសុមេធាធិបតី។ ល ។

### ៣ និយមន័យនៃបទល្មើសទាំងពីរ

បទល្មើសឃាតកម្ម គឺជាអំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធក្តី ដោយគ្មានស្ថានទម្ងន់ទោស ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ដល់មាត្រា ២០៥ (បទឃាតកម្ម ដោយមានទារុណកម្មអំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ) នៃក្រមនេះគឺជាឃាតកម្ម។

បទរាជឃាតកម្ម គឺជាអំពើសម្លាប់មនុស្សដែលបុគ្គលម្នាក់នោះគឺជាស្តេច ផែនដី ឬក៏ជាព្រះរាជា ឬក្សត្រធំជាងគេបង្អស់ និង មានតែមួយនៅក្នុងក្នុងប្រទេសកម្ពុជា ដោយ ចេតនា ឬអ

ចេតនាក្តី បើទោះជាមានការប្រើអាវុធក្តី មិនប្រើអាវុធក្តី ទៅលើរូបរាងកាយរបស់ទ្រង់ ដែលជាព្រះមហាក្សត្រ ហើយអំពើនោះអាចបណ្តាលឱ្យទ្រង់ចូលទិវង្គត។

### ៤ ធាតុផ្សំនៃបទល្មើសទាំងពីរ

ដោយយោងតាមមូលដ្ឋានគ្រឹះនៃនីតិវិធីព្រហ្មទណ្ឌទូទៅ យើងអាចយកមកធ្វើការសិក្សានៅក្នុងនីតិព្រហ្មទណ្ឌពិសេសដោយផ្អែកទៅលើធាតុផ្សំចំនួន ០៣ (បី) គឺរួមមាន ធាតុនីត្យានុកូល ឬ ធាតុផ្អែកច្បាប់, ធាតុសត្យានុម័ត ឬធាតុសម្ភារៈ និង ធាតុអត្តនោម័តិ ឬធាតុផ្សំចិត្តសាស្ត្រ៖

#### ៤.១ ធាតុនីត្យានុកូល

ធាតុនីត្យានុកូល ឬធាតុច្បាប់ សំដៅទៅលើការចែងអំពីបទល្មើសនីមួយៗនៅក្នុងច្បាប់ជាធរមាន ចំពោះបទល្មើសទាំងពីរនេះ ត្រូវបានបែងចែកយ៉ាងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

- បទឃាតកម្មមានចែងនៅក្នុងមាត្រា ១៩៩
- បទល្មើសរាជឃាតកម្មមានចែងក្នុងមាត្រា ៤៣៣

#### ៤.២ ធាតុសត្យានុម័ត

ធាតុសត្យានុម័តនេះបើយើងហៅជាភាសាសមញ្ញថាជាធាតុសម្ភារៈ ដែលមានន័យថាជាសកម្មភាពដែលកើតចេញរួចធ្វើឱ្យគេអាចសង្កេតឃើញថាជាសម្ភារៈខាងក្រៅ។ ហេតុដូច្នេះហើយបានជានៅក្នុងទ្រឹស្តី គេហៅថាជាធាតុសត្យានុម័ត គឺជាធាតុសម្ភារៈនៅក្នុងបទល្មើសនីមួយៗ។

- អំពើនៃការគិតទុកជាមុន និង ការពួនស្ទាក់

សម្រាប់បទឃាតកម្មបានន័យថា ជនល្មើសសម្លាប់គេគឺមិនបាននឹងរៀបចំគម្រោងអ្វីទុកជាមុននោះទេ ឬមិនបានទៅចាំអ្នកណាម្នាក់ក្នុងពេលមួយរយៈដើម្បីសម្លាប់ជនរងគ្រោះនោះឡើយ។ ដោយឡែកចំពោះបទរាជឃាតកម្ម បានសេចក្តីថាជនល្មើសអាចនឹងមិនបានរៀបចំគម្រោងទុកជាមុនក្នុងការសម្លាប់អង្គព្រះមហាក្សត្រ ប៉ុន្តែបើជនល្មើសមុននឹងសម្លាប់អង្គព្រះមហាក្សត្រគឺគាត់បានរៀបចំគម្រោង រៀបចំផែនការ រៀបចំសកម្មភាព ជាមុនយ៉ាងច្បាស់លាស់ ឬពួនស្ទាក់នៅកន្លែងនៅកន្លែងណាមួយក្នុងពេលណាមួយ មួយរយៈដោយស្គាល់ពីដំណើរអង្គព្រះមហាក្សត្រយ៉ាងច្បាស់ថាត្រូវតែសម្លាប់អ្នកនោះចោលតែម្តង ក៏បានចាត់ចូលក្នុងបទល្មើសរាជឃាតកម្មនេះដែរ។ សរុបមកបទរាជឃាតកម្មទោះបីជាមានការគិតទុក និង ការពួនស្ទាក់ ឬគ្នាក់ដោយ ក៏ត្រូវតែចាត់ចូលក្នុងបទរាជឃាតកម្មនេះដែរ។

- លទ្ធផលនៃការប្រព្រឹត្តបទល្មើស

លទ្ធផលនៃការប្រព្រឹត្តនេះគឺមានន័យថា ភាពដែរអាចទទួលបានជោគជ័យនៃការប្រព្រឹត្តបទល្មើស ហើយខាងក្រោមនេះគឺ យើងនឹងលើកឡើងនូវភាពខុសគ្នាចំពោះលទ្ធភាពនៃការប្រព្រឹត្តនេះរវាង បទល្មើសឃាតកម្ម និង បទរាជឃាតកម្ម។

បទឃាតកម្ម ចំពោះអំពើដែលបានប្រព្រឹត្តនេះអាចមិនទទួលបានលទ្ធផលជោគជ័យ ឬ សម្រេចបាន ១០០%នោះទេពីព្រោះតែនៅក្នុងបទឃាតកម្ម ពេលខ្លះដោយសារតែមិនបានគិតទុកជាមុនក៏បណ្តោយឱ្យលទ្ធផលអត់បានសម្រេចដូចក្តីបំណងប្រាថ្នានៃជនល្មើសចង់បានឡើយ។ ឧទាហរណ៍ៈជនល្មើសដកកាំភ្លើងបាញ់ក្បាលជនរងគ្រោះដោយសារតែមិនបានពិនិត្យគ្រាប់កាំភ្លើងជាមុនឱ្យបានត្រឹមត្រូវ នៅមុនពេលបាញ់ចេញទៅស្រាប់តែគ្រាប់កាំភ្លើងនោះស្ទុះទើបបាញ់ មិនចេញគ្រាប់ ហេតុនេះមិនបណ្តាលឱ្យជនរងគ្រោះស្លាប់ឡើយ។

ចំណែកឯបទរាជឃាតកម្មវិញ គឺជាអំពើដែលបានប្រព្រឹត្តប្រសិនបើអាចទទួលបានលទ្ធផលសម្រេច ១០០% ក្នុងការធ្វើឃាតអង្គព្រះមហាក្សត្រ ឬ អចេតនាក្នុងការធ្វើឃាតព្រះមហាក្សត្របណ្តាលឱ្យមានលទ្ធផលប៉ះពាល់ធ្ងន់ដល់ប្រទេសជាតិទាំងមូលតែម្តង នឹងមានផលប៉ះពាល់ យ៉ាងខ្លាំងដល់ប្រជារាស្ត្រដែលរស់នៅក្នុងប្រទេសនឹងក្រៅប្រទេស នឹងធ្ងន់ធ្ងរបំផុតគឺប៉ះពាល់ដល់ របបនយោបាននៅក្នុងប្រទេសតែម្តង។

- ពេលវេលានៃការប្រព្រឹត្តបទល្មើស

ពេលវេលានៃការប្រព្រឹត្តនេះ គឺចង់សំដៅទៅលើរយៈពេលដែលបានឈានទៅដល់ការប្រព្រឹត្តបទល្មើស ហើយបទល្មើសឃាតកម្ម និងបទល្មើសរាជឃាតកម្មមានរយៈពេលដូចគ្នា និង មិនដូចគ្នា យើងនឹងធ្វើការបកស្រាយដូចខាងក្រោមៈ

បទឃាតកម្ម រយៈពេលនៃអំពើសត្យានុម័តអាចកើតឡើងភ្លាមៗ ឬប្រព្រឹត្តភ្លាមៗតែម្តងមិនបានកើតឡើងដោយឆ្លងកាត់រយៈពេលដែលសមស្របនោះទេ។

ឧទាហរណ៍ៈ នៅក្នុងឋានៈពេលដែលរាំក្នុងក្លឹបកំសាន្តនាពេលរាត្រី កើតមានការជាន់ជើងគ្នា គ្រាន់តែប៉ុណ្ណឹងក៏ទាស់ទែងនឹងគ្នា ហើយនៅពេលដែលជនល្មើសឃើញហើយដបស្រាដែលនៅក្បែរនោះក៏ស្រាប់តែទាញយកមកគប់ជនរងគ្រោះបណ្តាលឱ្យស្លាប់មួយរំពេចបាត់ទៅ។

បទរាជឃាតកម្ម រយៈពេលនៃអំពើសត្យានុម័តរបស់វាអាចកើតឡើងដោយការត្រៀមទុកជាមុន ឬក៏អាចកើតឡើងភ្លាមៗ តែម្តងគឺអាស្រ័យទៅលើចេតនារបស់ជនល្មើសដែលប៉ងអាក្រក់លើអង្គព្រះមហាក្សត្រ។

- មូលហេតុនៃការប្រព្រឹត្តបទល្មើស

ការបកស្រាយទៅលើមូលហេតុនៃការប្រព្រឹត្តនេះ គឺចង់សំដៅទៅលើការលើកឡើងនូវស្ថានភាព ដែលអាចបង្កឱ្យបុគ្គលណាមួយឈានទៅដល់ការប្រព្រឹត្តបទល្មើសជាពិសេស គឺពាក់ព័ន្ធទៅនឹងស្មារតី និងការគិតរបស់បុគ្គលនោះ។ បើយើងពិនិត្យទៅលើបទឃាតកម្ម និង បទរាជឃាតកម្មចំពោះមូលហេតុនេះគឺមានលក្ខណៈដូចខាងក្រោម៖

នៅក្នុងបទឃាតកម្ម ជនល្មើសប្រព្រឹត្តនូវអំពើសម្លាប់នេះដោយសារតែកំហឹងខឹងមួយពេលតែប៉ុណ្ណោះ ឬក៏មួយឆាវក៏ជ្រុលខ្លួនប្រព្រឹត្តបទល្មើសទៅតែម្តង។ យោងតាមទ្រឹស្តីឧក្រិដ្ឋវិទ្យាបានលើកឡើងថា អ្នកខ្លះធ្លាក់ខ្លួនប្រព្រឹត្តគឺ ដោយសារកំហុសនៃជនរងគ្រោះបានន័យថា ជនរងគ្រោះគឺជាដើមចមនៃបទល្មើសដូចជា ការប្រើអំណាចគាបសង្កត់ទៅលើគេខ្លាំងពេកទើបគេទ្រាំលែងបានក៏ប្រព្រឹត្តបទល្មើសមកលើខ្លួនទៅ ឬជនរងគ្រោះជាអ្នកបង្កហេតុមុនក៏ថាបានឬមួយអាចស្រដៀងនឹងការការពារស្របច្បាប់តែជាការការពារហួសព្រំដែន។

ឧទាហរណ៍១៖ អ្នកមានអំណាចខ្លះ បានបំពានរំលោភយកដីស្រែរបស់ប្រជាពលរដ្ឋ ហើយដោយសារតែពួកគាត់អត់មានដីស្រែប្រៀបដូចជាគ្មានអ្វីចិញ្ចឹមជីវិតនោះ គិតខុសមួយពេលក៏ជ្រុលទៅសម្លាប់អ្នកនោះចោលទៅ ដើម្បីយកដីនោះមកចញ្ចឹមជីវិតខ្លួនឯងវិញ។

ចំណែកឯបទរាជឃាតកម្ម គឺជាអំពើដែលមានចេតនាបំផ្លាញជាតិ និង បង្កភាពចលាចលក្នុងសង្គមតែម្តង អាចថាបានគឺនឹងផ្លាស់ប្តូរបបគ្រប់គ្រងប្រទេសតែម្តង។

- លទ្ធភាពក្នុងការកែខ្លួនរបស់ជនល្មើស

នៅក្នុងការបកស្រាយអំពីលទ្ធភាពក្នុងការកែប្រែខ្លួនរបស់ជនល្មើសនេះ គឺមានគោលបំណងដើម្បីធ្វើការប្រៀបធៀបនូវចំណុចខុសគ្នារវាងបទល្មើសឃាតកម្ម និង បទរាជឃាតកម្មដោយពាក់ព័ន្ធទៅនឹងកម្រិតនៃការកែខ្លួនរបស់ជនល្មើសដែលមានកម្រិតខុសគ្នាដូចខាងក្រោម៖

នៅក្នុងបទឃាតកម្ម ជនល្មើសគឺជាបុគ្គលដែលអាចនៅកែខ្លួនបាន គឺសំដៅដល់ជនដែលគាត់ខុសខ្លួនតែមួយភ្លែតទេ ក៏បានប្រព្រឹត្តបទល្មើសផ្ទុយទៅវិញ ប្រសិនបើជាទុកឱ្យគាត់បានពិចារណាក្នុងរយៈពេលយូបន្តិចនោះគាត់នឹងមិនអាចទៅសម្លាប់គេឡើយ ហើយនៅពេលដែលគាត់សម្លាប់គេរួចក៏ភ័យខ្លួនឯងញ័រដៃញ័រជើង និងទើបតែដឹងថាស្តាយក្រោយខ្លាំងណាស់ ដូច្នេះជនប្រភេទនេះ គឺគាត់អាចនឹងកែខ្លួនបាន បើសិនជាយើងផ្តល់ឱ្យកាសដល់គាត់នោះ។

ផ្ទុយទៅនឹងបទល្មើសឃាតកម្មខាងលើ បទរាជឃាតកម្មជនល្មើសដែលប្រព្រឹត្តនូវអំពើនេះកម្រិតក្នុងការកែខ្លួនរបស់ជនល្មើសមានកម្រិតទាបណាស់ ហើយក៏អាចនិយាយបានថាជាបុគ្គលដែលអស់ផ្លូវកែប្រែ នឹងទទួលរងការស្អប់ខ្ពើមពីសង្គមជាខ្លាំងដល់ថ្នាក់មានការជ្រួលច្របល់ក្នុង

សង្គម។ អ្នកដែលប្រព្រឹត្តអំពើបែបៗនេះ គឺជាប្រភេទដែលមានចរិកលក្ខណៈឃោរឃៅ យង់ឃ្នង ព្រៃផ្សៃ និង បំផ្លាញសង្គមជាតិ មើលងាយជាតិ មើលងាយព្រះកេត្តិនាមអង្គព្រះមហាក្សត្រ។

**៤.៣ ធាតុអត្តនោម័តិ**

នៅក្នុងធាតុផ្សំអត្តនោម័តិ ក៏មានចំណុចខុសគ្នាខ្លះៗដែររវាងបទឃាតកម្ម និង រាជឃាតកម្ម មិនមែន មានតែធាតុនីត្យានុកូល និង ធាតុផ្សំសត្យានុម័តតែប៉ុណ្ណោះនោះទេ។ ចំណុចដែលខុសគ្នានៅក្នុង ធាតុអត្តនោម័តិរវាងបទល្មើសទាំងពីរនេះ គឺសំដៅទៅលើចេតនាទុច្ចរិតរបស់ជនល្មើសនៅក្នុងការ ដែលបានប្រព្រឹត្តនូវបទល្មើស ហើយដែលចេតនានេះវាពាក់ព័ន្ធទៅនឹងពេលវាលានឹងកាពិចារណា របស់ជនល្មើស ដែលមានចំណុចខុសគ្នាដូចខាងក្រោម៖

ចំពោះបទល្មើសឃាតកម្ម ជនល្មើសមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសដើម្បីដកហូតយកជីវិតជនរងគ្រោះដោយផ្ទុយនឹងច្បាប់ ប៉ុន្តែចេតនាទុច្ចរិតក្នុងការប្រព្រឹត្តមិនបានឆ្លងកាត់កាតាំងចិត្តទុកជាមុនដែលធ្វើឱ្យជនរងគ្រោះស្លាប់នោះទេ។

ចំណែកឯបទរាជឃាតកម្មវិញ ជនល្មើសមានចេតនាទុច្ចរិកដែលមានគោលបំណងប្រព្រឹត្តអំពើដែលផ្ទុកលទ្ធភាពពិសេសដើម្បីប្រល័យជីវិតអង្គព្រះមហាក្សត្រដែលកំពុងតែគ្រងរាជសម្បត្តិ។

**៥ ទោសដែលត្រូវបានអនុវត្ត**

បើយើងធ្វើការពិនិត្យទៅលើការបកស្រាយចំពោះទោសដែលត្រូវអនុវត្តនេះ យើងអាចសង្កេតឃើញថា បទល្មើសឃាតកម្ម នឹង បទរាជឃាតកម្ម មានចំណុចខុសគ្នាដោយពាក់ព័ន្ធនឹងទោសនេះចំនួន២ចំណុច ២.៥.១ មូលទោស និង ២.៥.២ ទោសបន្ថែម យើងនឹងធ្វើការបកស្រាយ ឱ្យបានក្បោះក្បាយដូចខាងក្រោម៖

**៥.១ មូលទោស**

មូលទោស ដែលយើងបានស្គាល់ថាជាទោសដែលត្រូវដាក់ទណ្ឌកម្មទៅលើជនល្មើសដោយមានការពន្ធនាគារ និង ពិន័យជាសាច់ប្រាក់ នោះក៏ជាចំណុចខុសគ្នាមួយដែររវាងបទ ល្មើសទាំងពីរនេះ។ ប៉ុន្តែចំណុចខុសគ្នាងាយស្រួលក្នុងការពិនិត្យ ដោយមានការបែងចែកនៅក្នុង ក្រមព្រហ្មទណ្ឌយ៉ាងច្បាស់លាសតែម្តងដោយមានការកំណត់នៅក្នុងមាត្រាយ៉ាងជាក់ស្តែង។

មូលទោសនៃបទឃាតកម្ម គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌនៅត្រង់មាត្រា ១៩៩។

ចំណែកឯមូលទោសនៃបទរាជឃាតកម្មវិញ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៅត្រង់មាត្រា ៤៣៣។

### ៥.២ ស្ថានទម្ងន់ទោស

ស្ថានទម្ងន់ទោស គឺសំដៅទៅលើការបន្ថែមនូវកម្រិតនៃទោសឱ្យកាន់តែធ្ងន់ជាងមុនទៅទៀត ហើយចំណុចនេះក៏មានលក្ខណៈខុសគ្នាមួយចំនួនដែររវាងបទល្មើសឃាតកម្ម និង បទរាជឃាតកម្ម។

នៅក្នុងបទឃាតកម្មទោសដែលត្រូវដាក់ទៅលើជនល្មើស អាចដាក់ស្ថានទម្ងន់ទោសបាន ប្រសិនបើប្រព្រឹត្តចូលក្នុងករណីនៃស្ថានទម្ងន់ទោសជាក់លាក់ដូចមានចែងក្នុងមាត្រា ២០០ ដល់ មាត្រា ២០៥។ ប៉ុន្តែបទល្មើសនេះគ្មានស្ថានទម្ងន់ទោសទេ ប្រសិនបើជនល្មើសមិនបានប្រព្រឹត្តនូវអំពើសម្លាប់ចូលទៅក្នុងក្នុងមាត្រា ២០០ ដល់ ២០៥ ដោយបានន័យថា ជនល្មើសមិនបានប្រព្រឹត្តបទឃាតកម្មដោយគ្មានការគិតទុកជាមុន, គ្មានការប្រើថ្នាំពុល, គ្មានទាក់ទងទៅនឹងជនរងគ្រោះ, គ្មានដោយសារគោលដៅ, មិនមែនប្រព្រឹត្តដោយអ្នករាជការសាធារណៈ និងមិនមានទារុណកម្ម អំពើ ឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈនោះទេ។ សរុបមកគឺ ជនល្មើសប្រព្រឹត្តតែអំពើដែលចូលត្រឹម មាត្រា ១៩៩ "បទឃាតកម្ម" តែប៉ុណ្ណោះ។

បើយើងក្រឡេកមកពិនិត្យទៅលើបទរាជឃាតកម្មវិញ មូលទោសដែលដាក់ទៅលើជនល្មើសមិនអាចដាក់ស្ថានទម្ងន់ទោសថែមទៀតបានទេ គឺពីព្រោះបទរាជឃាតកម្ម គឺជាបទល្មើសដែលមានស្ថានទម្ងន់ទោសខ្ពស់ជាងគេណាស់ទៅហើយ ពីព្រោះត្រូវដាក់ពន្ធនាគារអស់មួយជីវិត។

នាងខ្ញុំបានបញ្ចាប់នូវការបកស្រាយចំណុចទាំង៣ ជំពូករួចមកហើយ។ ប៉ុន្តែមុននឹងបញ្ចប់សៀវភៅមួយក្បាលនេះនាងខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានវាយតម្លៃចំណុចខ្លាំងនិងចំណុចខ្សោយរួចនឹងផ្ដល់អនុសាសន៍បញ្ចប់តែម្ដងសូមអរគុណ។

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាទៅលើបទឃាតកម្ម និងបទរាជឃាតកម្ម យើងសង្កេតឃើញថា បទល្មើសទាំងពីមានចំណុចដូចគ្នាជាច្រើន ចំណែកឯចំណុចខុសគ្នាក៏មានច្រើនផងដែរ។ ចំណុចដូច និង ខុសគ្នាក៏ត្រូវបានបង្ហាញនៅក្នុងការប្រៀបធៀបរវាងបទល្មើសទាំងពីរ ហេតុនេះហើយមុននឹង ឈានទៅដល់ការប្រៀបធៀប យើងនឹងធ្វើការសិក្សាទៅលើបទល្មើសនីមួយៗជាមុនសិន។

បទឃាតកម្មសំដៅទៅលើអំពើសម្លាប់មនុស្ស ដែលកើតឡើងដោយចេតនារបស់ជនល្មើស ដោយប្រើអាវុធ ឬក៏មិនបានប្រើអាវុធក្តី។ បទល្មើសនេះត្រូវបានបែងចែកនៅក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ហើយនៅក្នុងធាតុជាសម្ភារៈនៃបទល្មើសនេះ គឺទាមទាឱ្យមានត្រឹមតែអំពើដែលផ្ទុកនូវលទ្ធភាពក្នុងការដកហូតជីវិតមនុស្សតែប៉ុណ្ណោះមិនអាចទាមទារឱ្យមានព្យសនកម្មកើតឡើងនោះទេ។ ចំណែកឯធាតុអត្តនោម័តិវិញ គឺសំដៅទៅលើចេតនារបស់ជនល្មើសនៅក្នុងពេលប្រព្រឹត្តអំពើសម្លាប់ ហើយចេតនានេះអាចកើតចេញពីបុគ្គលផ្ទាល់ ករណីមានការយល់ព្រមពីជនរងគ្រោះការការពារខ្លួនស្របច្បាប់ និងការកើតចេញពីការភ័ន្តច្រឡំ។ លើសពីនេះទៅទៀត បទឃាតកម្មមាននូវស្ថានទម្ងន់ទោសផងដែរ ប្រសិនបើអំពើសម្លាប់មនុស្សដែលកើតឡើងនៅក្នុង ករណីមួយចំនួនដូចជាការប្រើប្រាស់ថ្នាំបំពុល ស្ថានភាពជនរងគ្រោះទន់ខ្សោយ ឬជាមន្ត្រីរាជការសាធារណៈ និងមានអំពើឃោរឃៅ ឬរំលោភសេពសន្ថវៈគឺ មានស្ថានទម្ងន់ទោស។ ចំពោះទោសបន្ថែមវិញមានចែងនៅក្នុងមាត្រា ២០៦ នៃក្រមព្រហ្មទណ្ឌដែលមានចំនួន ៥ចំណុច។

បើយើងពិនិត្យទៅលើបទរាជឃាតកម្ម គឺចង់សំដៅទៅលើអំពើសម្លាប់អង្គព្រះមហាក្សត្រដោយចេតនា ឬអចេតនាក្តី ដោយប្រើអាវុធ ឬមិនបានប្រើអាវុធ ឬមានការគ្រោងទុកជាមុន ឬការពួនស្ទាក់។ បទល្មើសនេះមានចែងក្នុងមាត្រា ៤៣៣ នៃក្រមព្រហ្មទណ្ឌ ហើយធាតុសម្ភារៈនៃបទល្មើសនេះមានបែងចែកជារូបរាងពីរគឺមានជាអំពើ និង ជនរងគ្រោះ។ អំពើ គឺចង់សំដៅទៅលើអំពើសកម្មដែលស្តែងចេញពីការប្រល័យ ឬផ្តាច់ជីវិត ឬប្រហារ ឬក៏ធ្វើឱ្យក្ស័យដល់ជីវិតអង្គព្រះមហាក្សត្រជីវិតតម្កល់លើត្បូង ដែលជាម្លប់ត្រជាក់នៃប្រជារាស្ត្រក្នុងប្រទេសខ្មែរ។ រីឯជនរងគ្រោះគឺសំដៅទៅលើអង្គព្រះមហាក្សត្រដែលត្រូវបាន បោះឆ្នោតជ្រើសតាំងឡើងដោយក្រុមប្រឹក្សារាជសម្បត្តិដែលស្របតាមរដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា១៣ ថ្មី។ ហើយម្យ៉ាងវិញទៀតជនរងគ្រោះមិនមែនគ្រាន់តែខ្សែរាជវង្ស ឬសម្តេចសង្ឃនោះទេ ហើយមិនមែនជារាស្ត្រដាច់ខាត។ ត្រូវតែជាព្រះមហាក្សត្រតែមួយតែប៉ុណ្ណោះពោលគឺអង្គព្រះមហាក្សត្រដែលគ្រងរាជសម្បត្តិ។ បន្ថែមពីនេះបទរាជឃាតកម្មមិនមាននូវស្ថានទម្ងន់ទោសនោះទេ។

បន្ទាប់ពីបានធ្វើការសិក្សាទៅលើប្រធានបទទាំងពីរនេះរួចមកហើយ យើងអាចទាញនូវបាន ចំណុចមួយចំនួនយកមកធ្វើការប្រៀបធៀប ដោយលើកឡើងនៅចំណុចដូចគ្នា និងចំណុចខុសគ្នា។

បទឃាតកម្ម និងបទរាជឃាតកម្មមានចំណុចដូចគ្នាមួយចំនួន។ បទល្មើសទាំងពីរគឺជាបទឧក្រិដ្ឋដូចគ្នា។ ចំណែកឯបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសទាំងពីរ មានដូចជាចារី ឬក៏សហចារី អ្នកផ្តើមគំនិត អ្នកផ្សំគំនិត និងជនរងគ្រោះ (តែបែងចែកសមាសភាពជនរងគ្រោះ) ហើយអំពើ និងបច្ច័យក៏មិនសូវខុសគ្នាដែរ គឺទាមទាឱ្យមាននៅអំពើ នឹងទាមទារឱ្យមានព្យសនកម្មកើតឡើង។ ជារួមមកបទល្មើសទាំងពីរនេះ មានចែងក្នុងក្រមព្រហ្មទណ្ឌថ្មីហើយក៏មាននូវគុណាសម្បត្តិ និងគុណាវិប្បត្តិផងដែរ។

ផ្ទុយទៅវិញបទឃាតកម្ម និងបទរាជឃាតកម្មមានចំណុចមួយចំនួនខុសគ្នាផងដែរ។ និយមន័យនៃបទល្មើសទាំងពីរខុសគ្នាត្រង់ថា បទរាជឃាតកម្មជាបទល្មើសសម្លាប់ព្រះមហាក្សត្រមិនមែនជាប្រជារាស្ត្រ ឬសម្តេចទេ។ បទល្មើសទាំងពីរត្រូវបានបែងចែកនៅក្នុងរចនាសម្ព័ន្ធនៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ខុសគ្នាយ៉ាងដាច់ស្រលាស់។ ចំណែកឯជនរងគ្រោះក៏បានចែកដាច់ពីគ្នាយ៉ាងច្បាស់ដែរ បទរាជឃាតកម្ម ជនរងគ្រោះគឺជាជាអង្គព្រះមហាក្សត្រជាដាច់ខាត រីឯបទឃាតកម្មជនរងគ្រោះគឺជាជនទូរទៅ។ ធាតុផ្សំនៃបទល្មើសក៏មិនដូចគ្នាដែរ គឺធាតុនីត្យានុកូលមានចែងនៅក្នុងមាត្រា ១៩៩ ចំពោះបទឃាតកម្មមានចែងក្នុងមាត្រា ៤៣៣ ចំពោះបទរាជឃាតកម្ម។ ចំណែកឯធាតុសត្យានុម័តខុសគ្នាត្រង់ថា មានចែងចែកសមភាពជនរងគ្រោះដូចដែលបានរៀបរាប់ដូចខាងលើរួចមកហើយ។ បន្ថែមពីនេះទៀតធាតុអត្តនោម័តិក៏មិនសូវខុសគ្នាដែរ ប៉ុន្តែ បទរាជឃាតកម្មជនល្មើសគឺមានចេតនាធ្វើគុតចំពោះអង្គព្រះរាជា ដែលកំពុងតែគ្រងរាជសម្បត្តិនោះឲ្យសោយទិវង្គត។

បទល្មើសទាំងពីរនេះ មាននូវអត្ថប្រយោជន៍មួយចំនួនដែលជាគោលបំណងនៃការបែងចែកសម្រាប់បទល្មើសទាំងពីរនេះ។ បទល្មើសទាំងពីរនេះ ត្រូវបានបែងចែកឡើងទៅតាម ៣២ នៃរដ្ឋធម្មនុញ្ញមាត្រានេះបានធានានូវសិទ្ធិរស់រានមានជីវិត និងហាមឃាត់មិនឱ្យមាននូវទោសប្រហារជីវិតដោយហេតុបទល្មើសទាំងពីរនេះបានចែងនៅក្នុងគោលបំណងហាមឃាត់ និងទប់ស្កាត់បង្ការកុំឱ្យមាននូវអំពើសម្លាប់មនុស្ស ឬសម្លាប់អង្គព្រះមហាក្សត្រដែលមានផលវិបាកធ្ងន់ធ្ងរដល់សង្គម។ ត្រូវដាក់ទោសទៅលើបុគ្គលដែលបានប្រព្រឹត្តនូវអំពើសម្លាប់នេះ ត្រឹមតែហាមឃាតសេរីភាពមិនអាចមានការប្រហាជីវិតបាននោះទេ ទោះបីជាវាប៉ះពាល់ដល់អាយុជីវិតមនុស្ស ឬអង្គព្រះមហាក្សត្រក៏ដោយប៉ុន្តែនៅក្នុងច្បាប់ចាស់សម័យមុនវិញ គឺមានទោសប្រហារជីវិតតែម្តង។ លើសពីនេះទៅ

ទៀតបទឃាតកម្ម និងបទរាជឃាតកម្ម ត្រូវបានចែងដោយកំណត់នូវទោសដាក់ពន្ធនាគារយ៉ាងច្បាស់លាស់ ដែលបានសមមូលទៅនឹងអំពើដែលខ្លួនបានប្រព្រឹត្តទៅលើជនរងគ្រោះ បន្ថែមពីនេះទៀតការដែលកំណត់បែបនេះគឺ ផ្តល់ផលប្រយោជន៍ក្នុងការគំរាមជនដែលមានគំនិតប្រព្រឹត្តបទល្មើសឱ្យមានការខ្លាចរអា និងជៀសវាងក្នុងការធ្វើសកម្មភាពផ្ទុយនឹងច្បាប់។ បើពិនិត្យមើលទៅលើបទឃាតកម្មមិនត្រឹមតែដាក់ទោសទៅលើ អំពើសម្លាប់ធម្មតានោះទេថែមទាំងបានពង្រីកវិសាលភាពដល់អំពើសម្លាប់ដែលកើតឡើងក្នុងស្ថានភាពពិសេសៗ មួយចំនួនទៀតដូចដែលបានរៀបរាប់ខាងលើ និងបានចាត់ទុកជាអំពើមនុស្សឃាតមានស្ថានទម្ងន់ទោស។ ដោយឡែកបទរាជឃាតកម្មគ្មានស្ថានទម្ងន់ទោសនោះទេព្រោះត្រូវផ្តន្ទនាទោសដាក់ពន្ធនាគារអស់មួយជីវិតរួចជាស្រេច ប៉ុន្តែករណីនេះអាចមានការប៉ះពាល់ខ្លាំងដល់នយោបាយនឹងសង្គម(កំហឹងប្រជាជន)។

បទល្មើសទាំងពីរនេះត្រូវបានចែងឡើងដោយផ្តល់អត្ថប្រយោជន៍ជាច្រើនក្នុងសង្គម ប៉ុន្តែនៅក្នុងនោះក៏មាននូវចំណុចអវិជ្ជមានមួយចំនួនផងដែរ។ បទល្មើសទាំងពីរមានលក្ខណៈស្រដៀងគ្នាខ្លះដែរ ខុសគ្នាត្រង់បទរាជឃាតកម្ម ជាការធ្វើឃាតអង្គព្រះមហាក្សត្រតែម្នាក់គត់មិនមែនជាប្រជារាស្ត្រធម្មតានោះទេ ឬងារជាសម្តេចនោះទេ។ បទល្មើសទាំងពីរមិនសូវមានការពិបាកក្នុងការបែងចែកនោះទេព្រោះបទល្មើសទាំងពីរនេះមិនស្ថិននៅក្នុងគន្លឹ មាតិការ នឹង ជំពូកតែមួយទេហើយម្យ៉ាងវិញទៀតជនរងគ្រោះមានការបែងចែកយ៉ាងជាក់លាក់តែម្តង។

បន្ទាប់ពីបានធ្វើសេចក្តីសន្និដ្ឋានរួចមក នាងខ្ញុំសូមបញ្ចេញនូវមត្តិយោលបល់ផ្ទាល់ខ្លួនមួយចំនួនផងដែរ ដែលមានភាពពាក់ព័ន្ធទៅនឹងចំណុចខ្វះខាតមួយចំនួននៃបទល្មើសទាំងពីរខាងលើនេះនៅចំណុចដែលបានលើកឡើងជាអនុសាសន៍នៅក្នុងទំព័របន្ទាប់នេះ។

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាយ៉ាងច្រើនក្នុងពេលកន្លងមកទៅលើបទល្មើសនីមួយៗ និង ការប្រៀបធៀបរវាងបទល្មើសទាំងពីររួចមក យើងក៏បានសង្កេតឃើញនូវចំណុចខ្វះខាតដែលជាគុណវិបត្តិមួយចំនួន និងចំណុចល្អដែលជាគុណសម្បត្តិមួយចំនួនផងដែរ គឺដូចដែលបានរៀបរាប់នៅក្នុងសេចក្តីសន្និដ្ឋានខាងលើផងដែរ។

ដោយសង្កេតឃើញនូវចំណុចអវិជ្ជមាននៃបទឃាតកម្ម និង បទរាជឃាតកម្មគិតទុកជាមុនខាងលើនេះ ដើម្បីឱ្យការអនុវត្តន៍នូវបទល្មើសទាំងពីរខាងលើនេះប្រកបដោយភាពរលូន នាងខ្ញុំសូមធ្វើការផ្តល់នូវមតិយោបល់មួយចំនួន ដោយបែងចែកជាចំណុចសំខាន់ៗដូចរៀបរាប់ខាងក្រោម៖

- **ចំណុចខ្សោយ**
  - ការផ្សព្វផ្សាយច្បាប់ គឺមិនសូវបានទូលំទូលាយដល់សាធារណៈជនទូរទៅដូចនេះ ទើបធ្វើឱ្យបុគ្គលមួយចំនួនបានប្រព្រឹត្តបទល្មើសកើតឡើង
  - មិនសូវស្គាល់ពីបទល្មើសច្បាស់លាស់
  - ការចែងរំលែកនូវចំណេះដឹង ឬឯកសាររបស់ស្ថានប័នអនុវត្តច្បាប់គឺនៅមានកម្រិត
  - តុលាការមានយុត្តិសាស្ត្រអនុវត្តនៅមានកម្រិត
  - បទល្មើសទាំងពីរខាងលើគួរមានការពិន័យឱ្យធ្ងន់បន្តិចលើសពីការជាប់ពន្ធនាគារ
- **ចំណុចខ្លាំង**
  - បទល្មើសទាំងពីមានការយកចិត្តទុកដាក់ពីស្ថាប័នដែលពាក់ព័ន្ធក្នុងការស្រាវជ្រាវរកជនល្មើសដែលប្រព្រឹត្តបទល្មើស
  - បទល្មើសទាំងពីរបានចែងក្នុងក្រមព្រហ្មទណ្ឌយ៉ាងច្បាស់លាស់
  - បានបង្កើតសាលាដំបូង និង អយ្យការអមសាលាដំបូងគ្រប់ខេត្ត ក្រុង និងរាជធានី ដើម្បីបង្កើតការងាយស្រួលក្នុងការដាក់ពាក្យបណ្តឹង។
- **ដំណោះស្រាយ**
  - ស្ថាប័ននីមួយៗ ត្រូវមានការយកចិត្តទុកដាក់ នឹងចែករំលែកចំណេះដឹងដើម្បីកាត់បន្ថយក្នុងការប្រព្រឹត្តិបទល្មើស
  - អប់រំ និង ផ្សព្វផ្សាយច្បាប់ឱ្យបានច្រើនជាពិសេសនៅតំបន់ដាច់ស្រយាល
  - បើកវគ្គសិក្សាអំពីចិត្តសាស្ត្រក្នុងការរំងាប់អារម្មណ៍ដែលមានកំហឹង ដែលបណ្តាលឱ្យកើតមានបទល្មើស។

# ឯកសារយោង

# ឯកសារយោង


- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ក្រមព្រហ្មទណ្ឌអត្តរកាលគ្មានលេខ, ១០ កញ្ញា ១៩៩២។
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៥/០០១, ១៥ កុម្ភៈ ២០០៨។
- ច្បាប់ស្តីពីការរៀបចំ និងកាប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ, លេខ នស/រកម/១០០៤/០០៣, ១១ តុលា ២០០៤។
- សន្ទានុក្រមច្បាប់ព្រហ្មទណ្ឌ
- សម្តេចព្រះសង្ឃរាជ ជួន ណាត. ២០០៩. *វចនានុក្រម,* វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ. ភ្នំពេញ
- កៅ សីហា. ២០០៤. *នីតិព្រហ្មទណ្ឌពិសេស*, បោះពុម្ពលើកទី៧. ភ្នំពេញ។
- ហ៊ី សោភា. ២០០៩. *នីតិព្រហ្មទណ្ឌ*. ភ្នំពេញ។
- យឹម សារី. ២០០៧. *នីតិព្រហ្មទណ្ឌ*. ភ្នំពេញ។
- សុខ រឿន. ២០០៦. *បទល្មើស និង ការផ្តន្ទាទោសក្នុងក្រមព្រហ្មទណ្ឌ*.បោះពុម្ពលើកទី១. ភ្នំពេញ ។
- វុណ្ណ រិទ្ធ. ២០១០. *ក្រមព្រហ្មទណ្ឌទូទៅ*, ភ្នំពេញ។
- អ្នកនិពន្ធអនាមិក.២០១៧. *នីតិព្រហ្មទណ្ឌ*, ភ្នំពេញ។
- https://www.interior.gov.kh
- http://khmerfamous.com

# ឧបសម្ព័ន្ធ